ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

# ឆ្នាំ២០១៨ - ២០៣០

## គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

## ក្រសួងកិច្ចការនារី

ខែកុម្ភៈ ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

ADB

# ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ
# ឆ្នាំ២០១៨-២០៣០

## គណៈកម្មាធិការដឹកនាំ និង សម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

## ក្រសួងកិច្ចការនារី

ខែកុម្ភៈ ឆ្នាំ ២០១៨

UN-HABITAT FOR A BETTER URBAN FUTURE FORUMSYD NDF CLIMATE INVESTMENT FUNDS

# បុព្វកថា

ខ្ញុំសូមស្វាគមន៍ ចំពោះផែនការមេ ស្តីពី **យេនឌ័រ និងការប្រែប្រួលអាកាសធាតុ** (MOGCCC) ឆ្នាំ២០១៨-២០៣០ ដែលនឹងត្រូវអនុវត្តក្នុងរយៈពេល១២ឆ្នាំខាងមុខ ដើម្បីឆ្លើយតបទីនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងពង្រឹងភាពធនរបស់ស្ត្រីទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា ។ គោលដៅចម្បងរបស់ផែនការមេនេះ គឺគាំទ្រដល់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងវិស័យឯកជន ពាក់ព័ន្ធនានា ក្នុងការបញ្ជ្រាបយេនឌ័រ ដែលជាផ្នែកមួយយ៉ាងសំខាន់នៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការបន្ធូបន្ថយ និងគំនិតផ្តួចផ្តើមនានា ក្នុងការវិនិយោគលើការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅប្រទេសកម្ពុជា ។

ផែនការមេមានគោលបំណង ដើរតួនាទីជាផែនទីបង្ហាញផ្លូវ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងគម្រោងនានា ដើម្បីចូលរួមចំណែក ដោយផ្ទាល់ទៅក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់ ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការកាត់បន្ថយភាពងាយរងគ្រោះផ្នែកអាកាសធាតុ ។

កិច្ចសហប្រតិបត្តិការប្រកបដោយជោគជ័យ នៃការរៀបចំផែនការមេនេះ គឺតម្រូវឲ្យមានសមត្ថភាពផ្នែកបច្ចេកទេស និងការផ្តល់ធន់ធានគ្រប់គ្រាន់ពីអន្តរក្រសួង ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជននានា ។ ខ្ញុំលើកទឹកចិត្តឱ្យក្រសួង ស្ថាប័ន ពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ នៅតែបន្តកិច្ចសហការណ៍ និងផ្តល់ធនធានគ្រប់គ្រាន់ ដើម្បីជួយសម្រួលដល់ការអនុវត្តការងារបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោងវិនិយោគឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៃក្រសួងកិច្ចការនារី និងបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ក្នុងការដោះស្រាយបញ្ហាយេនឌ័រ និងតម្រូវការយេនឌ័រ ដល់ដៃគូសហការពាក់ព័ន្ធនានា ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា កិច្ចសហការរួមគ្នាយ៉ាងសកម្មនេះ នឹងជំរុញឱ្យមានការលើកកម្ពស់សមភាពយេនឌ័រ និងសុខដុមរមនាសង្គម ព្រមទាំងពន្លឿនកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាប្រកបដោយបរិយាប័ន្ន ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ស៊ីវណ្ណ បុទុម រដ្ឋលេខាធិការ និងជាប្រធានគណកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងក្រុមការងារបច្ចេកទេសរបស់គម្រោង ក៏ដូចជាតំណាង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលចំពោះកិច្ចសហការប្រកបដោយប្រសិទ្ធិភាព និងធនាគារអភិវឌ្ឍន៍អាស៊ីADB សម្រាប់ការចូលរួមគាំទ្រក្នុងការអភិវឌ្ឍន៍ផែនការនេះ ។

ថ្ងៃសុក្រ៩រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

# សេចក្តីថ្លែងអំណរគុណ

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៨-២០១៩ (MPGCC) ត្រូវបានបង្កើតឡើងដោយផ្អែកលើបទដ្ឋាន ដែលបានរៀបចំក្រោមកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ដំណាក់កាលទី១ ក្នុងឆ្នាំ២០១៣។ ផែនការមេ (MPGCC) ផ្តល់នូវចក្ខុវិស័យ បេសកកម្ម គោលបំណង និងគោលដៅរួមច្បាស់លាស់ជាមួយផែនការសកម្មភាពជាអាទិភាពសម្រាប់ក្រសួងកិច្ចការនារី ក្រសួងតាមវិស័យ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ ផែនការមេ (MPGCC) នេះផ្តល់នូវការណែនាំសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការបន្ធូរបន្ថយ និងគំនិតផ្តួចផ្តើមនានាក្នុងការវិនិយោគលើការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងបរិស្ថាន ដែលជាស្ថាប័នប្រតិបត្តិនូវគំនិតផ្តួចផ្តើមមួយនេះ។ ទន្ទឹមនឹងនេះ ក៏សូមថ្លែងអំណរគុណដល់គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCC) ដែលបានដឹកនាំក្នុងការរៀបចំផែនការមេនេះ រួមជាមួយក្រសួងពាក់ព័ន្ធដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងសារធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧត្តុនិយម និងវិស័យដទៃជាច្រើនទៀត ព្រមទាំងមានការគាំទ្រពីអង្គការសង្គមស៊ីវិលផងដែរ។

ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់ការកៀរគរធនធានគ្រប់គ្រាន់ពីភ្នាក់ងារផ្សេងៗដូចជា មូលនិធិវិនិយោគអាកាសធាតុ និងមូលនិធិអភិវឌ្ឍន៍ Nordic សម្រាប់ការគាំទ្រដ៏សប្បុរសដល់ប្រទេសកម្ពុជា។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកបណ្ឌិត Ancha Srinivasan អ្នកឯកទេសផ្នែកការប្រែប្រួលអាកាសធាតុនៃធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការគាំទ្រដ៏គួរឱ្យកត់សម្គាល់ចំពោះប្រទេសកម្ពុជា ជាពិសេសចំពោះក្រសួងកិច្ចការនារី (MoWA) ដើម្បីលើកកម្ពស់ការបញ្ជ្រាបបញ្ហាយេនឌ័រ ក្នុងគំនិតផ្តួចផ្តើមនានានៃការវិនិយោគលើការប្រែប្រួលអាកាសធាតុ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីរាជការក្រសួងកិច្ចការនារី គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាពិសេស **លោកជំទាវ យ៉យ នីតា ឯកឧត្តម ម៉ី ហ៊ុល កញ្ញា ឆន រដ្ឋា លោកស្រី ស៊ាវ គឹមសឿន លោក រឹម ចាន់រ៉ា លោកស្រី ឃន ឱនរ៉ាវី** ទីប្រឹក្សាក្រសួងកិច្ចការនារី តំណាងក្រសួង នាយកដ្ឋានពាក់ព័ន្ធ និងតំណាងអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការរៀបចំកសាងនូវផែនការមេនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ UN-Habitat អង្គការ Forum Syd អង្គការ Save the Earth Cambodia និងក្រុមអ្នកបច្ចេកទេសរួមមាន **លោក Akhteruzzaman Sano លោក ចាប សុបញ្ញា និងលោកស្រីបណ្ឌិត សាផន សុមោលីរស្មី** ក្នុងការជួយសម្រួលដល់ដំណើរការរៀបចំផែនការមេ។

ចុងបញ្ចប់នាងខ្ញុំសូមគោរពដ៏ខ្ពង់ខ្ពស់ចំពោះ **លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្thaផាវី រដ្ឋមន្ត្រី** ក្រសួងកិច្ចការនារី សម្រាប់ភាពជាអ្នកដឹកនាំ និងគាំទ្រយ៉ាងពេញលេញ ក្នុងការណែនាំសម្របសម្រួល ដើម្បីរៀបចំកសាងផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៨-២០៣០)។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរកា នព្វស័កព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី**

**និងជាប្រធានគណៈកម្មាធិការដឹកនាំ និងសម្របសម្រួល**

**ការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ**

**ស៊ីវណ្ណា បុទុម**

# មាតិកា


**បុព្វកថា** ..... i

**សេចក្តីថ្លែងអំណរគុណ** ..... ii

**មាតិកា** ..... iii

**បញ្ជីអក្សរកាត់** ..... v

**សេចក្តីសង្ខេប** ..... vii

**១. សេចក្តីផ្តើម** ..... ១

**២. បញ្ហា និងសមាសធាតុសំខាន់ៗនៃផែនការមេ** ..... ៥

២.១. បរិបទនៃភាពងាយរងគ្រោះដោយអាកាសធាតុ ..... ៦

២.២. បរិបទសេដ្ឋកិច្ច ..... ៧

២.៣ . បរិបទប្រជាសាស្រ្ត ..... ៨

២.៤. បរិបទស្រ្តី និងការអភិវឌ្ឍ ..... ៩

២.៥ បរិបទយេនឌ័រ កសិកម្ម និងការប្រែប្រួលអាកាសធាតុ ..... ៩

២.៦. បរិបទសមធម៌យេនឌ័រ ..... ១០

ភាពប្រឈម របស់ស្រ្តីងាយរង គ្រោះចំពោះផលប៉ះពាល់នឹងការប្រែប្រួលអាកាសធាតុ១០

២.៧. បរិបទគោលនយោបាយបញ្ជ្រាបយេនឌ័រ ..... ១២

២.៨. បរិបទការកសាងសមត្ថភាពស្ថាប័ន ..... ១៤

២.៩. ការប៉ាន់ប្រមាណតម្រូវការសមត្ថភាពស្ថាប័ន ..... ២០

២.១០.ចំណុចគន្លឹះនៃផែនការមេ ..... ២៣

**៣. ដំណើរការរៀបចំផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ** ..... ២៦

៣.១. ការពិនិត្យមើលឯកសារពាក់ព័ន្ធផ្សេងៗ ..... ២៦

៣.២. ការពិគ្រោះយោបល់ ..... ២៦

៣.៣. ការទទួលស្គាល់ពីការចូលរួមចំណែកនៃគំនិតផ្តួចផ្តើមផ្សេងៗ ..... ២៧

៣.៤. ការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍន៍សមត្ថភាព ..... ២៧

៣.៥. ធាតុចូលពីក្រសួងពាក់ព័ន្ធ ធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកពាក់ព័ន្ធនានា . ២៩

**៤. ទិសដៅជាយុទ្ធសាស្ត្រ** ..................... ៣០
៤. ១. ចក្ខុវិស័យ ..................... ៣០
៤. ២. បេសកកម្ម ..................... ៣០
៤. ៣. គោលបំណងជាយុទ្ធសាស្ត្រ ..................... ៣០
៤. ៤. គោលបំណងជាក់លាក់ ..................... ៣០
៤.៥. គោលការណ៍ណែនាំ ..................... ៣៤
**៥. ការធ្វើឱ្យការបញ្ជ្រាបយេនឌ័រក្លាយជារបៀបវារៈក្នុងការអភិវឌ្ឍប្រកប ដោយចីរភាព** ..................... ៣៤
៥.១. គោលនយោបាយជាតិ និងផែនការ ..................... ៣៤
៥.២. ការគិតគូរពីការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគការប្រែប្រួលអាកាសធាតុ ៣៥
៥.៣. ទិន្នន័យ និងលទ្ធផលស្តីពីសមភាពយេនឌ័រ ..................... ៣៧
**៦ ប្រតិបត្តិការរបស់ផែនការមេ** ..................... ៣៧
៦.១. ប្រតិបត្តិការរបស់ផែនការមេ ..................... ៣៧
៦.២. ការផ្តួចផ្តើមគាំទ្រលើចំណុចអាទិភាពរបស់ក្រសួងកិច្ចការនារី ..................... ៣៧
៦.៣. ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ ..................... ៤០
**៧. សេចក្តីបញ្ចប់** ..................... ៤២
**សេចក្តីយោង និងឯកសារ** ..................... ៤៤
**ឧបសម្ព័ន្ធ ១- ពាក្យបច្ចេកទេស** ..................... ៤៧
**ឧបសម្ព័ន្ធ ២- វិស័យ និងខេត្តជាអាទិភាពសម្រាប់ការអនុវត្តផែនការមេស្តីពីយេនឌ័រ និង ការប្រែប្រួលអាកាសធាតុ** ..................... ៤៩
**ឧបសម្ព័ន្ធ ៣- ការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការសកម្មភាពនៃការវិនិយោគលើការប្រែប្រួល អាកាសធាតុតាមវិស័យ (២០១៤-២០១៨)** ..................... ៥១

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AR4 | របាយការណ៍ប៉ាន់ប្រមាណលើកទី៤ |
| ARCC | គម្រោងការបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ទន្លេមេគង្គ |
| ASPIRE | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| CBDRM | សហគមន៍គ្រប់គ្រងគ្រោះមហន្តរាយ |
| CCA | ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| CCAP | ផែនការសកម្មភាពប្រែប្រួលអាកាសធាតុ |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា |
| CCFF | ក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| CDRR | គម្រោងកាត់បន្ថយគ្រោះមហន្តរាយសហគមន៍ |
| CIF | មូលនិធិវិនិយោគអាកាសធាតុ |
| CSO | អង្គការសង្គមស៊ីវិល |
| DAP | គម្រោងជំនួយដោយផ្ទាល់ |
| DCC | នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EM-DAT | ទិន្នន័យគ្រោះមហន្តរាយអន្តរជាតិ |
| ESCAP | អង្គការសង្គមសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក |
| GCCAP | យេនឌ័រ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ |
| GCCC | គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ |
| GCM | គំរូអាកាសធាតុពិភពលោក |
| GDP | ផលិតផលក្នុងស្រុកសរុប |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍របស់មនុស្ស |
| IGES | វិទ្យាស្ថានសម្រាប់យុទ្ធសាស្ត្របរិស្ថានសកល |
| IPCC | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | ក្រសួងបរិស្ថាន |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MoWA | ក្រសួងកិច្ចការនារី |

| | |
|---|---|
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MPGCC | ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ |
| MoPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRC | គណៈកម្មការទន្លេមេគង្គ |
| MRCDP | ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុក្នុងផែនការអភិវឌ្ឍន៍ |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAPA | ផែនការសកម្មភាពជាតិសម្រាប់គម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| NCDD-S | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCSD | ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព |
| NDF | មូលនិធិអភិវឌ្ឍន៍ណ័រឌីក |
| Neary Ratanak | ផែនការយុទ្ធសាស្រ្តនារីរតនៈ |
| NIS | វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ |
| NP-SNDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NSDP | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ |
| OECD | អង្គការអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ច |
| LGCC | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ |
| PPCR | កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SIDA | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត |
| SNIF | មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ |
| SPCR | កម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ |
| STEC | អង្គការជួយសង្គ្រោះផែនដីនៃប្រទេសកម្ពុជា |
| TA | ជំនួយផ្នែកបច្ចេកទេស |
| The CCCA Trust Fund | មូលនិធិកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| TOR | លក្ខខណ្ឌយោង |
| ToT | ការបណ្តុះបណ្តាលគ្រូបង្គោល |
| UNCDF | អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍសមត្ថភាព |
| UNESCAP | គណៈកម្មាធិការសង្គម និងសេដ្ឋកិច្ចសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិកនៃសហប្រជាជាតិ |
| WACDEP | កម្មវិធីកម្មវិធីអភិវឌ្ឍន៍អាកាសធាតុ និងភាពជាដៃគូរសម្រាប់ធនធានទឹកសកល |

# សេចក្តីសង្ខេប

បច្ចុប្បន្ន ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជាមានចំនួន ១៨,០៥ ប៊ីលាន (billion) ដុល្លាអាមេរិក (យោងតាមរបាយការណ៍ស្តីពី ការព្យាករណ៍សេដ្ឋកិច្ចកម្ពុជា ទស្សនៈវិស័យឆ្នាំ ២០១៨-២០២០) ប្រទេសកម្ពុជាបានរក្សានូវកំណើនសេដ្ឋកិច្ចរយៈពេលវែងចាប់តាំងពីឆ្នាំ១៩៩៤ដែលមាន(GDP) កើនពី ៦% ទៅ ៧% ជារៀងរាល់ឆ្នាំ។ ដើម្បីរក្សាបាននូវដំណើរឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាគឺមានសូចនាករមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់ដូចជា ស្ថេរភាពនយោបាយ ស្ថេរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យនាំចេញនៅតែដើរតួនាទីសំខាន់(យោងតាមផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា [CCCSP] ឆ្នាំ២០១៤-២០២៣)។

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយរបស់កម្ពុជា ត្រូវបានអនុម័តកាលពី ខែឧសភា ឆ្នាំ២០១៥។ ច្បាប់នេះគឺជាសញ្ញាណនៃរបត់ដ៏សំខាន់មួយ ដើម្បីកែសម្រួលប្រព័ន្ធស្ថាប័នសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ ដោយផ្អែកលើឯកសារគតិយុត្តិផ្សេងៗដែលចូលជាធរមានកាលពីឆ្នាំ១៩៩៥។ ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយបានចែងពីតួនាទី និងការទទួលខុសត្រូវ ការបង្កើតស្ថាប័ន និងធានាការវិភាជន៍ធនធាននិងយន្តការសម្របសម្រួលក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល។ គោលដៅសំខាន់នៃការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា រួមមានការបង្ការទប់ស្កាត់ ការបន្សាំ និងការកាត់បន្ថយនៅមុនពេលគ្រោះមហន្តរាយ ការឆ្លើយតបជាបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និងការស្តារឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយ ដែលទាំងអស់នេះគឺរួមបញ្ចូលទាំងកត្តាធម្មជាតិ ឬកត្តាមនុស្សដែលបាន បង្កឱ្យមានគ្រោះមហន្តរាយ។

ដំណើរការនៃការអភិវឌ្ឍបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីកំណើន ១២,៥% ក្នុងមួយឆ្នាំដែលតួលេខនេះមានចំនួនលើស៤ដង ប្រៀបធៀបនឹងកំណើនទទួលបានពីភ្ញៀវទេសចរ ដែលមានតែ ២,៩% កាលពី ១២ខែ ចុងក្រោយ។ (ទស្សនៈវិស័យអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៧) ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិនៅកម្ពុជាបានជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចជាតិផងដែរ។ គ្រោះមហន្តរាយធម្មជាតិនៅ ឆ្នាំ២០១១ ធ្វើឱ្យកម្ពុជាខាតបង់សេដ្ឋកិច្ចប្រហែល៤,៣% នៃផលិតផលក្នុងស្រុកសរុប (មូលដ្ឋានទិន្នន័យ គ្រោះមហន្តរាយ អន្តរជាតិ [EM-DAT] ឆ្នាំ២០១៦) ។ ផលិតភាពកសិកម្ម ក៏ទទួលរងផលប៉ះពាល់ដែលបណ្តាលមក ពីការកើនឡើងសីតុណ្ហភាពផងដែរ។ យោងតាមវិទ្យាស្ថានស្រាវជ្រាវស្រូវអង្ករអន្តរជាតិ (IRRI) បានឱ្យដឹងថា ទិន្នផលស្រូវនឹងថយចុះចំនួន ១០% នៅពេលដែលសីតុណ្ហភាពកើនឡើង១អង្សាសេ ក្នុងរដូវដាំដុះ។ យោងតាមគម្រោងការបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ នៅតំបន់ទន្លេមេគង្គ (Mekong ARCC) បានបង្ហាញថា ទឹកភ្លៀងនឹងកើនឡើងខ្ពស់នៅរដូវវស្សានៅតាមបណ្តាខេត្តដែលមានទីតាំងនៅ តំបន់ខ្ពង់រាប ប៉ុន្តែនឹងមានភាពរាំងស្ងួតនៅរដូវប្រាំង ដែលកត្តានេះអាចរាំងស្ទះដល់ផលិតកម្មកាហ្វេ កៅស៊ូ ផលិតកម្មកសិផលផ្សេងៗ វារីអគ្គិសនី និងបរិក្ខាផ្គត់ផ្គង់ទឹកប្រចាំថ្ងៃនៅកម្ពុជា។

គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) មានគោលបំណងដោះស្រាយបញ្ហាភាពងាយរងគ្រោះ ដែលបណ្តាលមកពីអាកាសធាតុនិងលើកកម្ពស់កំណើន

សេដ្ឋកិច្ចតាមរយៈការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធនានាក្នុងប្រទេសកម្ពុជាក្នុងការដាក់បញ្ចូលបញ្ហាអាកាសធាតុទៅក្នុងផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានា។

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (MPGCC) ឆ្នាំ២០១៨-២០៣០ ដែលជាសមិទ្ធផលមួយរបស់ (MCRDP) ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCC) នៃក្រសួងកិច្ចការនារី (MoWA) ។ ផែនការមេ (MPGCC) ត្រូវបានរៀបចំឡើងនៅឆ្នាំ២០១៣ ក្រោមកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ដំណាក់កាលទី១ ដោយទទួលបានការឧបត្ថម្ភគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ហើយការងារនេះត្រូវបានចាប់ផ្តើមបន្តឡើងវិញនៅឆ្នាំ២០១៦ ក្រោមជំនួយបច្ចេកទេសលេខ ៨១៧៩ (ADB TA 8179 Package C) ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍កញ្ចប់ (គ) ការតាមដាន និងការវាយតម្លៃ (M&E) និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ។

ផែនការមេ (MPGCC) នេះមានចក្ខុវិស័យធ្វើស្ថាប័ននីយកម្មនៃការបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការវិនិយោគទៅលើការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីរួមចំណែកធ្វើឱ្យមានសមធម៌ ភាពធន់នឹងអាកាសធាតុ និងនិរន្តរភាពសង្គមនៃប្រទេសកម្ពុជា។ ដើម្បីធ្វើឱ្យការផ្លាស់ប្តូរនេះអាចសម្រេចបាន ផែនការមេ (MPGCC) នេះបានកំណត់គោលដៅរយៈពេលខ្លី (២០១៨-២០១៩) រយៈពេលមធ្យម (២០១៩-២០២៣) និងរយៈពេលវែង (២០២៣-២០៣០) ដើម្បីអាចបំពេញបន្ថែមនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ផែនការយុទ្ធសាស្ត្រនារីរតនៈ (Neary Ratanak) និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ឆ្នាំ២០១៤-២០២៣ រួមជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) គំនិតផ្តួចផ្តើមគាំទ្រចំនួន៧ ត្រូវបានអភិវឌ្ឍន៍ឡើងដើម្បីអនុវត្តផែនការមេ (MPGCC) នេះ។ ផែនការមេ (MPGCC) នេះនឹងផ្តោតការយកចិត្តទុកដាក់លើវិស័យនានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ហើយរំពឹងថានឹងទទួលបានកិច្ចសហការពីវិស័យឯកជន ដែលជាវិស័យមួយដ៏សំខាន់នៅប្រទេសកម្ពុជា ដែលបាននឹងកំពុងធ្វើការក្នុងវិស័យយេនឌ័រ និងការប្រែប្រួលអាកាសធាតុផងដែរ។

ផែនការមេ (MPGCC) នេះនឹងផ្តល់នូវទិដ្ឋភាពរួមពាក់ព័ន្ធនឹងបញ្ហា និងធាតុផ្សំសំខាន់ៗ នៃផែនការមេរួមទាំងបរិការណ៍នៃភាពងាយរងគ្រោះដែលបណ្តាលមកពីអាកាសធាតុបរិការណ៍ នៃប្រជាសាស្ត្រសេដ្ឋកិច្ច និងតួនាទីរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ជាតិ។ ផែនការមេ (MPGCC) នេះផ្តល់ផងដែរនូវការពិនិត្យឡើងវិញលើតួនាទីយេនឌ័រក្នុងវិស័យកសិកម្ម ដែលទទួលរងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ បរិការណ៍នៃសមភាពយេនឌ័រនៅកម្ពុជា និងបរិការណ៍នៃការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយនានា រួមទាំងចំណុចរបត់សំខាន់ៗផងដែរ។

ដំណើរការនៃការអភិវឌ្ឍផែនការមេ (MPGCC) នេះត្រូវបានធ្វើឡើងផ្អែកតាមការសិក្សាស្រាវជ្រាវលើឯកសារដែលមានស្រាប់ កិច្ចប្រជុំពិគ្រោះយោបល់ ការចូលរួមចំណែកពីគំនិតផ្តួចផ្តើមផ្សេងៗ ដែលបានអនុវត្តនៅកម្ពុជា និងការធ្វើការប៉ាន់ប្រមាណលើតម្រូវការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ។ ផែនការមេ (MPGCC) នេះក៏បានពន្យល់អំពីចក្ខុវិស័យ បេសកកម្ម គោលបំណងជាយុទ្ធសាស្ត្រ គោលបំណងជាក់លាក់ និងគោលការណ៍ណែនាំ ហើយបានបង្ហាញផងដែរនូវកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ជ្រាបយេនឌ័រ និងការផ្តល់កិច្ចអន្តរាគមន៍ដែលមានចែងនៅក្នុងគោលនយោបាយ និងផែនការជាតិបញ្ហាទាក់ទងនឹងការវិនិយោគយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ និងទិន្នន័យបែងចែកតាមភេទដើម្បីធ្វើការត្រួតពិនិត្យក្របខ័ណ្ឌលទ្ធផល។

# ១.សេចក្តីផ្តើម

"ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (MPGCC) ឆ្នាំ ២០១៨-២០៣០" ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCC) នៃក្រសួងកិច្ចការនារី (MoWA)។ ដំណើរការនៃការរៀបចំផែនការ ធ្វើឡើងដោយផ្អែកលើការអនុវត្តការងារកន្លងមក ក្រោមកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) របស់ក្រសួងបរិស្ថាន សហការជាមួយនឹងក្រសួងកិច្ចការនារីដែលជាដៃគូអនុវត្ត និងបានផ្តល់មូលដ្ឋានសម្រាប់ដំណើរការ នៃការពិគ្រោះយោបល់ជាបន្តបន្ទាប់ ដែលបានអនុវត្តក្នុងអំឡុងឆ្នាំ ២០១៦-២០១៨ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ៨១៧៩(ADBTA-8179)[1]។ ផែនការមេនេះមានចក្ខុវិស័យធ្វើស្ថាប័ននីយកម្ម នៃការបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុការវិនិយោគទៅលើការបន្ធូរបន្ថយនិងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីរួមចំណែកធ្វើឱ្យ សម្រេចបាននូវសមធម៌ ការបង្កើនភាពធន់នឹងអាកាសធាតុ និងនិរន្តរភាពសង្គមនៃប្រទេសកម្ពុជា ។ បេសកកម្មនេះគឺដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ ការបន្ធូរបន្ថយ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈការអភិវឌ្ឍគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងវិនិយោគនានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់ការឆ្លើយតបភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ការសិក្សាជាច្រើនបានបង្ហាញថា វិសមភាពយេនឌ័របានដាក់បន្ទុកបន្ថែមលើការចំណាយយ៉ាងពិតប្រាកដ និងមានផលប៉ះពាល់យ៉ាងខ្លាំងលើសង្គម (រូបភាពទី១) ។ នីតិវិធី និងគោលនយោបាយសាធារណៈត្រូវបានអភិវឌ្ឍន៍ឡើងដោយផ្អែកលើតម្រូវការរបស់សង្គមនិងសហគមន៍ ឬផ្អែកលើតម្រូវការរបស់អ្នកធ្វើសេចក្តីសម្រេច ដែលភាគច្រើនគឺជាបុរស។ ចលនាដើម្បីសិទ្ធិរបស់ស្ត្រី ការកើនឡើងចំនួនស្ត្រីជាអ្នកធ្វើសេចក្តីសម្រេច ការប្តេជ្ញាចិត្តដើម្បីការពារសិទ្ធិមនុស្សរបស់ស្ត្រីនៅគ្រប់កម្រិត និងការរីកចម្រើននូវការសិក្សាស្រាវជ្រាវអំពីយេនឌ័រ និងទិន្នន័យដែលបែងចែកតាមភេទ បានបង្ហាញការពិតថាគោលនយោបាយសាធារណៈមួយចំនួនមិនទាន់បានគិតគូរលើតម្រូវការ និងស្ថានភាពរបស់ស្ត្រីឲ្យបានគ្រប់គ្រាន់នៅឡើយ។

នៅក្នុងរូបភាពទី២ បានបង្ហាញថា ការដោះស្រាយវិសមភាពយេនឌ័រ ដែលជាការជួយគាំទ្រដោយផ្ទាល់ដល់ក្រុមងាយរងគ្រោះ ដែលមានចំនួនច្រើនជាងពាក់កណ្តាលនៅក្នុងបណ្តាសង្គមជាច្រើន នៅលើពិភពលោក ។ ជារួមការដោះស្រាយវិសមភាពយេនឌ័រនឹងផ្តល់ផលចំណេញជាច្រើន ។ ការបញ្ជ្រាបយេនឌ័រដែលជាយុទ្ធសាស្ត្រមួយសម្រាប់ធ្វើឱ្យប្រសើរឡើងនូវផ្នែកគុណភាពនៃ គោលនយោបាយសាធារណៈ កម្មវិធី និងគម្រោងនានា គឺជាការធានាបាននូវប្រសិទ្ធភាពនៃការវិភាជន៍ធនធាន មានន័យថា លទ្ធផលដែលទទួលបានគឺជាការលើកកម្ពស់សុខុមាលភាពទាំងបុរស និងស្ត្រីការបង្កើតយុត្តិធម៌សង្គម[2] និងនិរន្តរភាពសង្គម។

[1] ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ កញ្ចប់ (គ) ការតាមដាននិងការវាយតម្លៃ និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ។

[2] សង្គមមួយដែលប្រកបដោយសុវត្ថិភាព សមភាព និងសន្តិសុខ ។

របាយការណ៍ស្តីពីការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលត្រូវបាន ផ្សព្វផ្សាយដោយវិទ្យាស្ថាន McKinsey Global Institute (រូបភាពទី១) កាលពីខែមេសា ឆ្នាំ២០១៨ បានឱ្យដឹងថា បើសិនជាបញ្ហាវិសមភាពយេនឌ័រដែលកំពុងកើតមានបច្ចុប្បន្ន ត្រូវបានលុបបំបាត់ នោះសេដ្ឋកិច្ចនៃតំបន់អាស៊ីភាគអាគ្នេយ៍នឹងកើនឡើងខ្ពស់ ដោយកំណើន GDP ជារួមអាចកើនឡើងរហូតដល់ ៣៧០ ប៊ីលាន (370 billion) ដុល្លារអាមេរិកក្នុងមួយឆ្នាំ គិតត្រឹមឆ្នាំ២០២៥។ របាយការណ៍នេះមិនបានធ្វើការវិភាគលើប្រទេសប្រ៊ុយណេ និងសាធារណរដ្ឋប្រជាមានិតឡាវនោះទេ។ ស្ត្រីនៅតំបន់អាស៊ីអាគ្នេយ៍បានចូលរួមចំណែកបង្កើន GDP ចំនួន ៣៦,៨% សម្រាប់តំបន់ទាំងមូល ប៉ុន្តែតួលេខនេះ មិនបានបង្ហាញពីសុខុមាលភាព និងសកម្មភាពផ្នែកសេដ្ឋកិច្ចសរុបរបស់ស្ត្រីនៅក្នុងតំបន់ឡើយ រួមទាំងមិនបានបង្ហាញពីតម្លៃសេដ្ឋកិច្ចដែលស្ត្រីបានបង្កើតតាមរយៈការងារផ្ទះ ដូចជាការមើលថែទាំកូន និងមនុស្សចាស់ការដើរទិញទំនិញ ការចម្អិនម្ហូបអាហារ និងការងារសម្អាត ដែលជាការងារមិនទទួលបានប្រាក់កម្រៃ (ប្រភពឯកសារយោងពី វិទ្យាស្ថានសាកល McKinsey ឆ្នាំ២០១៨)។

*រូបភាពទី១- កម្រិតនៃវិសមភាពយេនឌ័រដែលផ្តល់ផលប៉ះពាល់ក្នុងតំបន់អាស៊ាន*




ប្រភព៖ វិទ្យាស្ថាន McKinsey Global Institute ឆ្នាំ២០១៨

ការរារាំងស្ត្រីនិងក្មេងស្រីក្នុងការទទួលបានសិទ្ធិ និងកាលានុវត្តភាពផ្សេងៗ មិនត្រឹមតែធ្វើឱ្យពួកគាត់ទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងនោះទេក៏ជាការដាក់បន្ទុកផ្នែកសេដ្ឋកិច្ចដល់គ្រួសារ សហគមន៍ និងសេដ្ឋកិច្ចជាតិទាំងមូលផងដែរ ។ តាមរយៈការវិនិយោគលើស្ត្រីនិងក្មេងស្រី និងការលុបបំបាត់វិសមភាពយេនឌ័រ យើងអាចលុបបំបាត់ផលអវិជ្ជមានទាំងនេះ និងផ្លាស់ប្តូរជោគវាសនារបស់ប្រទេសជាតិទាំងមូល។ ការធានាបានថា ស្ត្រីនិងក្មេងស្រីអាចទទួលបាននូវសិទ្ធិ និងកាលានុវត្តភាពប្រកបដោយសមធម៌ដូចបុរស និងក្មេងប្រុស គឺជាការងារចាំបាច់ដែលត្រូវចាប់ផ្តើមអនុវត្តពីចំណុចសីលធម៌ និងគុណធម៌ ហើយការងារនេះនឹងផ្តល់ផលវិជ្ជមានដល់សេដ្ឋកិច្ចផងដែរ ដែលមានតម្លៃរហូតដល់១៦០ ទ្រី លានដុល្លាអាមេរិក ។

របាយការណ៍ថ្មីមួយដែលឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលកាណាដាចេញផ្សាយ ដោយធនាគារពិភពលោកបានរកឃើញថា បើសិនជាស្ត្រីអាចស្វែងរកប្រាក់ចំណូលពេញមួយជីវិតរបស់ពួកគាត់ ដូចនឹងបុរសដែរនោះ មនុស្សម្នាក់ៗនៅក្នុងពិភពលោកនឹងទទួលបានប្រាក់បន្ថែមរហូតដល់ ២៣,៦២០ ដុល្លារអាមេរិក ដែលសរុបជាមធ្យមមានចំនួនទឹកប្រាក់ ១៦០ទ្រីលានដុល្លារអាមេរិក សម្រាប់១៤១ប្រទេស ។ ចំនួនទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់នេះ អាចយកទៅប្រើប្រាស់ក្នុងការងារផ្សេងៗដូចជា កាត់បន្ថយវិសមភាព លើកកម្ពស់អ្នកដែលមានប្រាក់ចំណូលកម្រិតមធ្យម និងកាត់បន្ថយកត្តាដែលនាំឱ្យ អស្ថេរភាពនយោបាយ និង អស្ថេរភាពសង្គម។ ទោះបីការបង្ហាញនេះ គឺជាកាលានុវត្តភាពជាក់ស្តែងយ៉ាងណាក្តី ស្ត្រីមានចំនួនតែ៣៨% ប៉ុណ្ណោះនៃទ្រព្យមូលធនសរុប (human capital wealth) របស់ប្រទេសពួកគាត់ ដែលតួលេខនេះប្រហាក់ប្រហែលនឹងតួលេខ ដែលប្រជាជនវ័យកណ្តាលរកប្រាក់ចំណូលបាននៅពេលអនាគត ។ នៅក្នុងបណ្តាប្រទេសក្រីក្រ និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ស្ត្រីមានចំនួនត្រឹម១/៣ (មួយភាគបី) ប៉ុណ្ណោះឬតិចជាងនេះ នៃទ្រព្យមូលធនសរុប (រូបភាពទី២)។

*រូបភាពទី២- ផលចំណេញដែលគិតជាដុល្លារអាមេរិក ដែលនឹងទទួលបានពីសមភាពយេនឌ័រ*




ប្រភព៖ ធនាគារពិភពលោក, ឆ្នាំ២០១៨

នៅក្នុងចំណុចដៅទី៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅមិនទាន់មានការបង្ហាញពីវិធីសាស្ត្រសម្រាប់ទិសដៅខាងមុខ ឬសូចនាករដើម្បីជួយក្នុងការវិភាគអំពីការខាតបង់ និងចំណេញផ្នែកសេដ្ឋកិច្ចតាមរយៈការកាត់បន្ថយវិសមភាពយេនឌ័រនៅឡើយទេ។ ការប៉ាន់ប្រមាណលើផលចំណេញ និងការខាតបង់ មានភាពចាំបាច់ណាស់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងការចំណាយនៅក្នុងកម្រិតទៅតាមវិស័យនីមួយៗ ដូចជា តើមានវិធីសាស្ត្របែបណាទើបការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ ឬវិស័យគ្រប់គ្រងធនធានទឹក កាន់តែមានប្រសិទ្ធភាពសម្រាប់វាស់វែងតម្លៃផ្នែកសង្គម? តើជាការសមហេតុសមផលទេសម្រាប់ការវាស់វែងបញ្ចូលគ្នា ឬប្រៀបធៀបព្រឹត្តិការណ៍ជីវិតផ្សេងៗគ្នា (ឧទាហរណ៍ ប្រៀបធៀបភាពមានការងារធ្វើ និងការរៀបអាពាហ៍ពិពាហ៍) តាមរយៈការប្រើប្រាស់ចំណូលចំណាយដែលទទួលបានពីទីផ្សារ និងថាតើតម្លៃដែលទទួលបានពីសហគមន៍មួយបណ្តុំដោយស្ថាប័ន បទដ្ឋាន និងរចនាសម្ព័ន្ធសេដ្ឋកិច្ច អាចយកមកអនុវត្តដើម្បីសម្រេចបាន

លទ្ធផលនៅក្នុងសហគមន៍មួយផ្សេងទៀតបានដែរឬទេ (Kohler ឆ្នាំ២០១២)។

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ វាស់វែងទំហំនៃគម្លាត និងតម្រូវការនៅកម្រិតវិស័យនានា នៅថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។ ផែនការមេនេះ បានបង្ហាញពីកាលានុវត្តភាពក្នុងការកាត់បន្ថយគម្លាតយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការនៃការរៀបចំផែនការពីការបន្សាំនឹងអាកាសធាតុនៅគ្រប់កម្រិត។ ហេតុដូចនេះការសម្របសម្រួលការអនុវត្តនៃផែនការមេនេះ នឹងជួយផ្តល់តម្លៃបន្ថែមដោយផ្ទាល់លើទ្រព្យមូលធនសរុបរបស់ស្ត្រីដែលមានត្រឹមតែ ៣៨% ប៉ុណ្ណោះ ប្រៀបធៀបនឹងបុរសដែលមានរហូតដល់៦២%។ នៅក្នុងប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប គម្លាតទ្រព្យមូលធនសរុបនេះ កាន់តែមានកម្រិតខ្ពស់ ដែលធ្វើឱ្យពិភពលោកមានការខាតបង់ធនធានសរុបជាទឹកប្រាក់ចំនួន២៣,៦២០ ដុល្លារអាមេរិក សម្រាប់មនុស្សម្នាក់ៗ។ គម្លាតនៅក្នុងការស្វែងរកប្រាក់ចំណូលរបស់ស្ត្រី ប្រៀបធៀបនឹងបុរស (វិសមភាពយេនឌ័រ) មានប្រមាណជា ១៦០,២ ទ្រីលាន (160.2 Trillion) ដុល្លារអាមេរិក នៃបណ្តាប្រទេសចំនួន១៤១ នៅលើពិភពលោក។ ជាឧទាហរណ៍ ទ្រព្យមូលធនសរុបនេះអាចកើនឡើងដល់ ២១,៧% នៅលើពិភពលោក ហើយទ្រព្យសរុបអាចកើនដល់ ១៤% តាមរយៈសមភាពក្នុងការស្វែងរកប្រាក់ចំណូល ។ តួលេខនេះមានចំនួនប្រហែល២ដងនៃ GDP របស់ពិភពលោក។ អាស្រ័យហេតុនេះ ការអនុវត្តផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ គឺមានសារសំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន។ ប៉ុន្តែវិស័យឯកជននៅមិនទាន់បង្កើន កិច្ចខិតខំប្រឹងប្រែងនៅឡើយក្នុងការចូលរួមដំណើរការនៃការបញ្ជ្រាបយេនឌ័រក្នុងការអនុវត្តផែនការមេនេះ។ មានគំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍគាំទ្រជាក់លាក់ចំនួន០៧ និងបណ្តុំនៃសូចនាករសម្រាប់ការត្រួតពិនិត្យ ដែលឆ្លើយតបនឹងយេនឌ័រសម្រាប់ដំណើរការផែនការមេនេះ ។

*ប្រអប់ទី១- បញ្ជីសំណួរសម្រាប់សូចនាករសមភាពយេនឌ័រ*

- តើអ្នកពាក់ព័ន្ធយល់ឬទេថា ហេតុអ្វីការប្រមូលព័ត៌មានដែលមានការបែងចែកតាមភេទ និងការវិភាគយេនឌ័រ និងសង្គមមានសារសំខាន់?
- តើសមត្ថភាពដៃគូ និងអ្នកអនុវត្តដើម្បីប្រមូល និងវិភាគព័ត៌មានដែលបែងចែកតាមភេទ ចាំបាច់ត្រូវពង្រឹងបន្ថែមដែរឬទេ?
- តើព័ត៌មាននេះសម្រាប់អ្នកណា? តើអ្នកពាក់ព័ន្ធយល់ដែរឬទេថាព័ត៌មាននេះត្រូវយកមកប្រើប្រាស់ដោយរបៀបណា? និងតើព័ត៌មាននេះឆ្លើយតបនឹងតម្រូវការឬទេ?
- តើសូចនាករនេះ ងាយស្រួលយល់ និងងាយស្រួលប្រើប្រាស់ឬទេ? តើព័ត៌មាននេះងាយស្រួលក្នុងការប្រមូលឬទេដោយប្រើប្រាស់ប្រព័ន្ធក្នុងស្រុកដែលមាន?
- តើសូចនាករដែលបានដាក់ក្នុងរបាយការណ៍ បានដាក់បន្ទុកលើដៃគូដែរឬទេឬសូចនាករនេះស៊ីចង្វាក់នឹងរបាយការណ៍ដៃគូកន្លងមកដែរឬទេ?
- តើព័ត៌មានដែលនឹងត្រូវប្រមូលនេះ បានបង្ហាញពីការអភិវឌ្ឍវត្ថុបំណងដែលត្រូវសម្រេចបានសម្រាប់បុរស និងស្ត្រីដែរឬទេ? និងតើវាមានសារសំខាន់ និងផ្តល់ផល-ប្រយោជន៍ ផ្សេងៗគ្នាឬទេសម្រាប់ស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី?
- តើសូចនាករនេះ ជួយដល់ការវាស់វែងលទ្ធផលសមភាពយេនឌ័រដែរឬទេ ដូចជាការចូលរួម អត្ថប្រយោជន៍ លទ្ធផល និងឥទ្ធិពលរបស់បុរស និងស្ត្រី ?
- តើសូចនាករនេះជួយដល់ការវាស់វែងការផ្លាស់ប្តូរ និងទំនោរក្នុងទំនាក់ទំនងយេនឌ័រកន្លងមក និងតើមូលហេតុអ្វីបណ្តាលឱ្យមានការផ្លាស់ប្តូរ និងទំនោរនេះឬទេ?
- តើត្រូវប្រើវិធីសាស្ត្រស្រាវជ្រាវទាំងបែបបរិមាណ និងគុណភាព សម្រាប់ប្រមូលព័ត៌មានឬ?
- តើការវិភាគយេនឌ័រនិងសង្គម ត្រូវបានអនុវត្តដើម្បីជួយកំណត់សូចនាករឬទេ?
- តើសូចនាករទាំងនេះ ផ្តល់ព័ត៌មានដើម្បីបង្កើនប្រសិទ្ធភាពយុទ្ធសាស្ត្រដើម្បីឆ្លើយតបនឹងវិសមភាពយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រដែរឬទេ?

ប្រភព៖ J. Hunt. 2011, សេចក្តីផ្តើមអំពីការត្រួតពនិត្យ និងវាយតម្លៃយេនឌ័រ
កំណត់បង្ហាញអំពីការបណ្តុះបណ្តាលដែលមិនសម្រាប់ការបោះពុម្ពផ្សាយ

## ២. បញ្ហា និងសមាសធាតុសំខាន់ៗនៃផែនការមេ

### សាវតា

នៅប្រទេសកម្ពុជា ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី បានផ្តោតការយកចិត្តទុកដាក់លើការបង្កើនអត្រាចូលរួមរបស់ស្ត្រីនៅក្នុងការងារ ដោយកាត់បន្ថយគម្លាតយេនឌ័រ ការលើកកម្ពស់ការងារដែលងាយរងគ្រោះរបស់ស្ត្រី ជាមួយនឹងលក្ខខណ្ឌការងារ និងប្រាក់ឈ្នួលសមរម្យ រួមជាមួយនឹងការជួយសម្របសម្រួលដល់ការចាកចេញពីវិស័យកសិកម្មដ៏ច្រើន ដែលអត្រាបុរសមានច្រើនជាងស្ត្រី និងការកើនឡើងនៃការចូលរួមរបស់ស្ត្រី ក្នុងការងារជំនួញ និងសេវាកម្ម រោងចក្រសហគ្រាស កសិកម្ម សកម្មភាពសេវាកម្មកំសាន្ត និងចំណីអាហារ ។

ប្រអប់ទី២- ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី មានន័យថា ជាសមត្ថភាពនៃការចូលរួមរបស់ស្ត្រីនិងបុរស ការរួមចំណែកនិងទទួលបានអត្ថប្រយោជន៍ពីដំណើរការកំណើននានា ដោយត្រូវទទួលស្គាល់ផងដែរពីតម្លៃនៃការ រួមចំណែករបស់ស្ត្រី គោរពនូវសេចក្តីថ្លៃថ្នូរ និងបង្កលក្ខណៈឱ្យមានការចរចារដើម្បីទទួលបាននូវការបែងចែកអត្ថប្រយោជន៍នៃកំណើនឱ្យកាន់តែមានភាពត្រឹមត្រូវ។ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចធ្វើឱ្យស្ត្រីកាន់តែទទួលបានធនធានសេដ្ឋកិច្ច និងកាលានុវត្តភាពផ្សេងៗ រួមទាំងការងារ សេវាហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ទុនសម្រាប់ផលិតកម្ម ការអភិវឌ្ឍជំនាញ និងព័ត៌មានអំពីទីផ្សារ ។ ការបង្កើនការចូលរួម និងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី គឺជាមូលដ្ឋានគ្រឹះក្នុងការពង្រឹងនូវសិទ្ធិរបស់ស្ត្រី និងផ្តល់លទ្ធភាពឱ្យពួកគាត់អាចចាត់ចែងជីវិតរស់នៅរបស់ខ្លួន និងមានឥទ្ធិពលក្នុងសង្គម ។

ប្រភព៖ អង្គការអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) ២០១៦

ប្រទេសកម្ពុជា អាចសម្រេចបាននូវកិច្ចអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់លើវិស័យជាច្រើន រួមទាំងកម្រិតនៃការចូលរួម និងកាលានុវត្តភាពរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចការលើកកម្ពស់វិស័យអប់រំ សុខាភិបាល និងការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ ។ ប្រទេសកម្ពុជាទទួលស្គាល់ថាការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាកត្តាសំខាន់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកប ដោយបរិយាប័ន្ន ។

យោងតាមឯកសារស្រាវជ្រាវជាច្រើនបានបង្ហាញថា អស់រយៈកាលជាង ២០ឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាសម្រេចបានសមិទ្ធផលគួរជាទីកត់សម្គាល់លើការចូលរួម និងកាលានុវត្តភាពរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ការលើកកម្ពស់វិស័យអប់រំ សុខាភិបាល និងការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។ ទោះជាយ៉ាងណា នៅក្នុងតារាងទី១ខាងក្រោមបានបង្ហាញថា ចំណាត់ថ្នាក់របស់ប្រទេសកម្ពុជានៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍របស់មនុស្ស (HDI) នៅមិនទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយទេ បើប្រៀបធៀបនឹងប្រទេសផ្សេងទៀតក្នុងតំបន់ ដោយសារកម្ពុជានៅមានឧបសគ្គមួយចំនួនក្នុងការបង្កើនភាព អង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ បញ្ហាសំខាន់ៗមួយចំនួនដែលត្រូវដោះស្រាយរួមមាន ៖

ក. តម្រូវការពេលវេលាដ៏ច្រើន របស់ស្ត្រីសម្រាប់បំពេញបន្ទុកការងារផ្ទះ និងការងារថែទាំផ្សេងទៀតដែលជាការងារមិនទទួលបានប្រាក់កម្រៃ ទន្ទឹមគ្នានឹងការងារនានាសម្រាប់សកម្មភាពសេដ្ឋកិច្ច ឧទាហរណ៍: ការងារកសិកម្ម សុខភាព ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍអាជីវកម្ម និងការងារដែលមានប្រាក់ចំណូល។

ខ. ចំណេះដឹង ការអប់រំ និងជំនាញរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយ

គ. ការទទួលបានធនធាន រួមមាន ធនធានផលិតកម្ម/អាជីវកម្ម ហិរញ្ញវត្ថុ ព័ត៌មាន និងការទទួលបានទីផ្សារក៏នៅមានកម្រិតទាប

*តារាងទី ១- បរិបទអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសកម្ពុជាប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់សម្រាប់ផ្នែកសុខភាព អប់រំ យេនឌ័រ ការងារ និងភាពងាយរងគ្រោះ*

| HDI (២០១៦) | ចំណាត់ថ្នាក់សាកល | | ផ្នែកសុខភាព | | | | អប់រំ | | | យេនឌ័រ | | | | ការងារ និងភាពងាយរងគ្រោះ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ | ចំណាត់ថ្នាក់ | អាយុកាល (ឆ្នាំ) | អត្រាមរណៈស្ត្រី ១ក្នុង ១០០០ នាក់ | អត្រាមរណៈបុរស ១ក្នុង ១០០០ នាក់ | អត្រាមរណៈកុមារអាយុ ៥ ឆ្នាំ (១ នាក់ក្នុង ១០០០ នាក់) | ការរំពឹងទុកឆ្នាំនៃការសិក្សា | អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យអាយុ ១៥ ឆ្នាំ និងលើស ១៥ឆ្នាំ | ភាគរយកុមារបោះបង់ការសិក្សាបឋមសិក្សា | សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) | កម្រិតចូលរួមក្នុងកំលាំងពលកម្មរបស់ស្ត្រី (% អាយុ១៥ឆ្នាំ និងលើសពី ១៥ឆ្នាំ) | កម្រិតចូលរួមក្នុងកំលាំងពលកម្មរបស់បុរស (% អាយុ១៥ ឆ្នាំ និងលើសពី ១៥ឆ្នាំ) | ភាគរយស្ត្រីកាន់តំណែងនយោបាយ អ្នកគ្រប់គ្រង | អត្រាមានការងារ ប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋ (អាយុ ១៥ឆ្នាំ និងលើសពី ១៥ ឆ្នាំ) | អត្រាមានការងារក្នុងវិស័យកសិកម្ម |
| សិង្ហបុរី | 0.925 | 5 | 83.2 | 39 | 71 | 2.7 | 15.4 | 96.8 | 1.3 | 0.985 | 58.2 | 76.4 | 33.9 | 65.0 | មិនមាន |
| ម៉ាឡេស៊ី | 0.789 | 59 | 74.9 | 80 | 167 | 7.0 | 13.1 | 94.6 | 5.8 | មិនមាន | 49.3 | 77.6 | 25.0 | 61.5 | 12.2 |
| ថៃ | 0.740 | 87 | 74.6 | 105 | 207 | 12.3 | 13.6 | 96.7 | 6.5 | 1.001 | 62.9 | 80.2 | 25.1 | 70.6 | 41.9 |
| ចិន | 0.738 | 90 | 76.0 | 72 | 98 | 10.7 | 13.5 | 96.4 | មិនមាន | 0.954 | 63.6 | 77.9 | 16.8 | 67.6 | 2.5 |
| ឥណ្ឌូនេស៊ី | 0.689 | 113 | 69.1 | 147 | 205 | 27.2 | 12.9 | 93.9 | 18.1 | 0.926 | 50.9 | 83.9 | 23.2 | 63.4 | 34.3 |
| វៀតណាម | 0.683 | 115 | 75.9 | 68 | 186 | 21.7 | 12.6 | 94.5 | 10.4 | 1.010 | 73.8 | 83.2 | មិនមាន | 76.7 | 46.8 |
| ឥណ្ឌា | 0.624 | 131 | 68.3 | 145 | 217 | 47.7 | 11.7 | 72.1 | មិនមាន | 0.819 | 26.8 | 79.1 | 13.8 | 51.9 | 49.7 |
| ឡាវ | 0.586 | 138 | 66.6 | 176 | 217 | 66.7 | 10.8 | 79.9 | 22.4 | 0.924 | 77.7 | 77.0 | មិនមាន | 76.1 | 71.3 |
| **កម្ពុជា** | **0.563** | **143** | **68.8** | **145** | **210** | **28.7** | **10.9** | **77.2** | **53.1** | **0.892** | **75.5** | **86.7** | **21.0** | **80.5** | **54.1** |
| ភូមា | 0.556 | 145 | 66.1 | 173 | 229 | 50.0 | 9.1 | 93.1 | 25.2 | មិនមាន | 75.1 | 81.1 | មិនមាន | 74.3 | មិនមាន |

ប្រភពទិន្នន័យ: Human Development Index, http://hdr.undp.org/en/countries accessed 15 August 2018

ដោយផ្អែកទៅតាមបរិបទ តម្រូវការ បញ្ហាប្រឈម ចំណុចខ្សោយនានា និងសមាសធាតុផ្សេងទៀត នឹងត្រូវបានលើកយកមកពិចារណា និងពិពណ៌នាក្នុងផែនការមេនេះ ទៅតាមផ្នែកជាបន្តបន្ទាប់ដូចខាងក្រោម៖

## ២.១ បរិបទនៃភាពងាយរងគ្រោះដោយអាកាសធាតុ

### ការប៉ាន់ប្រមាណពីការប្រែប្រួលអាកាសធាតុនៅកម្ពុជាពីឆ្នាំ២០០០ ដល់ ឆ្នាំ២០៥០

យោងតាមការសិក្សាស្រាវជ្រាវរបស់លោក ថូម៉ាស[3] ដែលបានផ្តល់ទិន្នន័យគោល ទាក់ទងនឹងការប៉ាន់ប្រមាណពីការប្រែប្រួលប្រួលអាកាសធាតុនៅកម្ពុជាពីឆ្នាំ២០០០ ដល់ឆ្នាំ២០៥០ បានបង្ហាញពីការប្រែប្រួលយ៉ាងខ្លាំងនូវទំហំនៃទឹកភ្លៀងប្រចាំឆ្នាំរបស់កម្ពុជា។ ជាក់ស្តែងបរិមាណទឹកភ្លៀងមានការថយចុះចំនួន ១,១៥០មីលីម៉ែត្រ នៅតំបន់ភាគខាងជើងប្រទេស ជាង៣,០០០មីលីម៉ែត្រនៅតំបន់ឆ្នេរសមុទ្រ និងចន្លោះពី ២,៦០០ ដល់ ៣,០០០មីលីម៉ែត្រនៅតំបន់ភាគឦសាន។

នៅក្នុងអំឡុងពេលដូចគ្នានេះ ទិន្នន័យគោលក៏បានផ្តល់អំពីការកើនឡើងខ្ពស់នៃសីតុណ្ហភាពគិតជាមធ្យមប្រចាំឆ្នាំសម្រាប់ខែដែលក្តៅជាងគេ។ តួលេខដែលទាបជាងគេបង្ហាញថា នៅតំបន់ខ្ពង់រាបភាគខាងលិចនៃប្រទេសដែលនៅជិតមាត់សមុទ្រ មានសីតុណ្ហភាព២៧ អង្សាសេ និងជាង៣៦អង្សាសេ នៅភាគពាយព្យដែលនៅជិតព្រំដែនកម្ពុជា-ថៃ ។

---

[3] Thomas, T. et al (2013), កសិកម្មកម្ពុជា៖ ផលប៉ះពាល់នៃការបន្សុាំការប្រែប្រួលអាកាសធាតុ, IFPRI កិច្ចពិភាក្សានៅទំព័រទី ០១២៨៥ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ, ភ្នំពេញ

ការសិក្សាដូចគ្នានេះប្រើប្រាស់គំរូអាកាសធាតុពិភពលោក (GCMs) ចំនួន៤ផ្សេងគ្នា ក្នុងចំណោម GCMs ចំនួន២៣ហើយត្រូវបានទទួលស្គាល់ដោយក្រុមការងារអន្តររដ្ឋាភិបាល ស្តីពី ការប្រែប្រួលអាកាសធាតុ (IPCC) សម្រាប់របាយការណ៍ប៉ាន់ប្រមាណលើកទី៤ (AR4)។ ទោះបីជាមិនទទួលបានការឯកភាពជាឯកច្ឆន្ទទៅលើការប៉ាន់ប្រមាណ និងផលប៉ះពាល់ផ្នែកប្រជាសាស្ត្រ ប៉ុន្តែនិន្នាការជាទូទៅមួយចំនួនត្រូវបានកំណត់។ គំរូអាកាសធាតុពិភពលោកទាំង៤នេះបានបង្ហាញពីការកើនឡើងនូវសីតុណ្ហភាពប្រចាំឆ្នាំ ដោយមានការប្រែប្រួលតិចតួចនៅតំបន់ភាគខាងលិច ប៉ុន្តែឡើងក្តៅនៅតំបន់ភាគខាងកើត និងការកើនឡើងសីតុណ្ហភាពមធ្យម ទៅជាក្តៅ ឬក្តៅខ្លាំងនៅទូទាំងប្រទេស។ ពាក់ព័ន្ធនឹងបរិមាណទឹកភ្លៀង គំរូអាកាសធាតុពិភពលោកចំនួន៣ បានបង្ហាញថា មានសំណើមខ្លាំងនៅរដូវវស្សា ហើយគំរូអាកាសធាតុពិភពលោកចំនួន២ក្នុងចំណោម GCMs ទាំង៣នេះ បង្ហាញថា មិនមានការផ្លាស់ប្តូរបរិមាណទឹកភ្លៀងប្រចាំឆ្នាំនោះឡើយ ដូច្នេះធ្វើឱ្យបរិយាកាសកាន់តែស្ងួតហួតហែងនៅរដូវប្រាំង។ គំរូអាកាសធាតុពិភពលោកទី៣ បានបង្ហាញថា នៅរដូវវស្សាតំបន់ផ្នែកនិរតី និងតំបន់ កណ្តាលភាគខាងត្បូងមានសំណើមកាន់តែខ្ពស់។ គំរូអាកាសធាតុពិភពលោកទី២ បង្ហាញថា នៅរដូវវស្សាតំបន់ភាគឦសានស្ងួតហួតហែង រីឯគំរូអាកាសធាតុពិភពលោកទី៤ បង្ហាញថាភាពហួតហែងមានរយៈពេលវែងរហូតដល់រដូវវស្សា ទោះបីបរិមាណទឹកភ្លៀងមានចំនួនកើនឡើងតិចតួចនៅតំបន់ពាយព្យ។

## ២.២ បរិបទសេដ្ឋកិច្ច

ប្រទេសកម្ពុជា ទទួលបានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ តាមរយៈកំណែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ចផ្អែកលើទីផ្សារ ទទួលបានជំនួយសំខាន់ៗពីខាងក្រៅ និងស្ថេរភាពនយោបាយរបស់ប្រទេស។ ប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ជាមួយនឹងចំណូលសម្រាប់មនុស្សម្នាក់ៗ ១,០៧០ដុល្លារអាមេរិក។ កម្ពុជាអាចធានាបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមរង្វង់៧,៦% ចាប់តាំងពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៥ ធ្វើឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ទី៦លើពិភពលោក ដែលពឹងផ្អែកលើវិស័យកសិកម្ម ការនាំចេញ វិស័យវាយនភ័ណ្ឌ និងទេសចរ (ធនាគារពិភពលោកប្រចាំនៅកម្ពុជាឆ្នាំ២០១៨)។ កំណើនផលិតផលក្នុងស្រុកសរុប រក្សាបាននូវកំណើនដ៏រឹងមាំនេះ ដោយមានចំនួន៧,១% សម្រាប់ឆ្នាំ២០១៨(សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ធៀបនឹងកំណើនក្នុងតំបន់ដែលមានចំនួន ៦,៣% (ចក្ខុវិស័យធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៧) ។ យោងទៅតាមឯកសាររបាយការណ៍របស់ស្ថាប័នស្ថិតិជាតិ (NIS) បានឲ្យដឹងថា ចំណូលប្រចាំឆ្នាំជាមធ្យមសម្រាប់មនុស្សម្នាក់ៗ មានចំនួន ១,៣៣០ ដុល្លាអាមេរិក ក្នុងឆ្នាំ២០១៦។

ជាងនេះទៀត អង្គការ**សង្គមអាស៊ី និងប៉ាស៊ីហ្វិក** (ESCAP) បានបញ្ជាក់អំពីការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់ក្នុងវិស័យការងារសម្រាប់បុរស និងស្ត្រី ដែលមានទំនោរចាកចេញពីវិស័យកសិកម្ម។ អ្វីដែលជាការកត់សម្គាល់នោះ គឺចំនួនរបស់បុរសដែលធ្វើការងារក្នុងវិស័យកសិកម្មបានធ្លាក់ចុះពី ៨៣,៣% មកនៅ ៧៦,៥% ក្នុងឆ្នាំ១៩៩១ រីឯចំនួនស្ត្រីក្នុងវិស័យកសិកម្មពី ២៦,២% មកនៅ ២៧,២% ក្នុងឆ្នាំ២០១៧។ ក្នុងរយៈពេលដូចគ្នានេះ ហើយការចូលរួមរបស់ស្ត្រីក្នុងវិស័យឧស្សាហកម្ម បានកើនឡើងពី ៣,១% ទៅ ២៣,១%។ និងវិស័យទីផ្សារសម្រាប់ស្ត្រីបុរសមានការកើនឡើងពីចំនួន ៨,៦% ដល់៣០,៥%។ [4]

---

UNESCAP (គណៈកម្មាធិការសង្គម និងសេដ្ឋកិច្ចសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិកនៃសហប្រជាជាតិ),
http://data.unescap.org/escap_stat/#data/ នៅថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៨
(២០១៣), របាយការណ៍ចុងក្រោយនៃការអង្កេតចន្លោះជំរឿនកម្ពុជា ២០១៣ របស់ក្រសួងផែនការ, ភ្នំពេញ

យោងតាមទិន្នន័យនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាក្នុងឆ្នាំ២០១៧ ចាប់តាំងពីឆ្នាំ២០០៩ មកទល់ឆ្នាំ២០១៧ ការងារក្នុងវិស័យកសិកម្មមានការថយចុះគួរអោយកត់សម្គាល់ ខណៈដែលការងារវិស័យឧស្សាហកម្ម និងសេវាកម្មមានកើនឡើងជាប់ក្នុងរយៈពេល៨ឆ្នាំចុងក្រោយនេះ។ ទោះបីជាការងារកំពុងងាកចេញពីវិស័យកសិកម្ម និងឈានចូលក្នុងវិស័យកម្មន្តសាល និងសំណង់យ៉ាងឆាប់រហ័សក៏ដោយវិស័យកសិកម្មនៅតែមានចំនួន៣៩,០% នៃការងាររបស់ស្ត្រី និង៣៥,១% នៃការងាររបស់បុរសនៅកម្ពុជានៅឡើយ។

## ២.៣. បរិបទប្រជាសាស្ត្រ

ទោះបីជាមានការធ្វើទេសន្តរប្រវេសន៍ពីតំបន់ជនបទ ដែលនាំមកនូវនគរូបនីយកម្មយ៉ាងឆាប់រហ័ស ប៉ុន្តែប្រជាជនកម្ពុជាចំនួន៧៨% នៅកំពុងបន្តរស់នៅទីជនបទ។ ប្រជាជនដែលមានអាយុពី ១៥-៦៤ ឆ្នាំបានកើនពី៨,៣លាននាក់ក្នុងឆ្នាំ២០០៨ ដល់ ៩,៦លាននាក់ក្នុងឆ្នាំ២០១៣ ហើយចំនួនប្រជាជនក្នុងវ័យកម្លាំងពលកម្មកើនពី ៦២% ដល់ ៦៥,៦% ក្នុងនោះស្ត្រីមានចំនួន៥២% នៃប្រជាជនក្នុងវ័យកម្លាំងពលកម្មសរុប។ ជាការចាប់អារម្មណ៍ ល្បឿននៃនគរូបនីយកម្មធ្វើឱ្យបំណែងចែកនៃអាយុក្នុងវ័យកម្លាំងពលកម្មនៅតំបន់ទីប្រជុំជនមានការកើនឡើង (៧០,៥%នៅតំបន់ទីប្រជុំជន និង ៦៤,៣%ក្នុងតំបន់ជនបទ)។ ទោះបីជាចំនួនប្រជាជនវ័យចំណាស់មានការធ្លាក់ចុះ ប៉ុន្តែការបង្កើនចំនួនការងារដែលមានលក្ខខណ្ឌការងារសមរម្យនៅតែជាតម្រូវការចាំបាច់ ហើយតម្រូវការនេះនឹងអាចបង្កជាផលលំបាក ដោយប្រជាជនចំនួន១,៣លាននាក់ បន្ថែមទៀតដែលនឹងត្រូវការការងារចន្លោះពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០។[5]

ភាពខុសគ្នានៃកម្រិតជំនាញ រវាងបណ្តាប្រទេសក្នុងតំបន់នឹងផ្តល់បញ្ហាប្រឈមបន្ថែមដល់ប្រទេសកម្ពុជា ដែលចំនួនប្រជាជនកំពុងមានការកើនឡើងនេះ។ បើប្រៀបធៀបជាមួយប្រជាពលរដ្ឋក្នុងតំបន់ កង្វះខាតកម្លាំងពលកម្មជំនាញនឹងផ្តល់ផលពិបាកសម្រាប់ប្រទេស ក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង ជាពិសេសសម្រាប់កម្មករគ្មានជំនាញ និងស្ត្រីដែលពួកគាត់កំពុងជួបបញ្ហាអក្ខរកម្ម និងការទទួលបានការអប់រំទាប ។ ភាពងាយរងគ្រោះក្នុងការប្រកួតប្រជែងនេះ បានកើនឡើងដោយសារប្រទេសកម្ពុជាពឹងផ្អែកទាំងស្រុងលើវិស័យនាំចេញ ដូច្នេះហើយវិបត្តិសេដ្ឋកិច្ចពិភពលោកបានប៉ះពាល់ដោយផ្ទាល់លើឱកាសការងារសម្រាប់ស្ត្រីកម្ពុជា ដូចដែលធ្លាប់បានកើតមានពីឆ្នាំ២០០៧-២០០៨ ។ ប្រការនេះឆ្លុះបញ្ចាំងពីតម្រូវការក្នុងការអភិវឌ្ឍ និងធ្វើពិពិធកម្មទីផ្សារក្នុងស្រុក ឱ្យកាន់តែរឹងមាំដើម្បីទប់ស្កាត់ការរងឥទ្ធិពលពីនិន្នាការសេដ្ឋកិច្ចសាកល។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានបានកើតឡើងយុទ្ធសាស្ត្រក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការវិលត្រឡប់ទៅប្រកបមុខរបរកសិកម្មពិតជាមិនទទួលបានជោគជ័យឡើយដោយផលិតផលកសិកម្ម ឱកាសការងារក្នុងវិស័យកសិកម្ម ជីវភាពរស់នៅ និងផ្ទះសម្បែងនៅតំបន់ជនបទ (ជាពិសេសសម្រាប់ស្ត្រី) ទទួលរងផលប៉ះពាល់ពីបាតុភាពធម្មជាតិដ៏ខ្លាំងក្លានេះរួចទៅហើយ។[6]

[6] MacPhail.F. (២០១៥). ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅកម្ពុជា របស់ធនាគារអភិវឌ្ឍន៍អាស៊ី, ភ្នំពេញ

## ២.៤.បរិបទស្ត្រី និងការអភិវឌ្ឍ

ដូចបានរៀបរាប់ខាងលើ និងជាពិសេសក្នុងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុរបស់ក្រសួងកិច្ចការនារី(២០១៣-២០២៣) [7] ទោះបីជាចំនួននៃការចូលរួមក្នុងកម្លាំងពលកម្មរបស់បុរស មានអត្រាខ្ពស់ជាងស្ត្រី ប៉ុន្តែស្ត្រីនៅទីជនបទចូលរួមយ៉ាងសកម្មក្នុងវិស័យសេដ្ឋកិច្ច ប្រៀបធៀបនឹងស្ត្រីក្នុងទីប្រជុំជន ហើយអត្រានៃស្ត្រីធ្វើការក្នុងឧស្សាហកម្មក្នុងកម្រិតផលិតកម្ម និងកែច្នៃ មានកម្រិតខ្ពស់ជាងបុរស។ វិស័យកសិកម្ម ព្រៃឈើ និងជលផល នៅតែជាជម្រើសដ៏សំខាន់សម្រាប់ជីវភាពប្រជាពលរដ្ឋកម្ពុជានៅទីជនបទ។ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រីខ្ពស់ជាងបុរស ជាពិសេសនៅក្នុង វិស័យ៤សំខាន់ៗរួមមាន(១) កសិកម្ម ព្រៃឈើ និងនេសាទ (២)ផលិតកម្ម (៣)ការលក់ដុំ និងលក់រាយ និង(៤) បដិសណ្ឋារកិច្ច និងសេវាចំណីអាហារ ដែលភាពច្រើនពួកគាត់អាចជានយោជិត ឬធ្វើការដោយខ្លួនឯង។ ចំនួន ៦៨,៤%នៃស្ត្រីក្នុងតំបន់ជនបទធ្វើការងារក្នុងគ្រួសារដែលមិនទទួលបានប្រាក់បៀវត្ស ធៀបនឹងចំនួន ២៨,៤%នៃបុរសក្នុងតំបន់ជនបទ រីឯនៅក្នុងទីក្រុង គម្លាតនេះមានភាពតិចជាង។

គួរកត់សម្គាល់ផងដែរថា ស្ត្រីនៅគ្រប់វ័យទាំងអស់បានចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិក្នុងនោះតួលេខដ៏គួរឱ្យកត់សម្គាល់គឺភាគរយរបស់ស្ត្រីដែលមានអាយុលើសពី៦៥ឆ្នាំ ដែលកំពុងចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ(៤៥,២%)។ អត្រាចូលរួមរបស់បុរសក្នុងសកម្មភាពសេដ្ឋកិច្ចមានកម្រិតខ្ពស់ជាងស្ត្រីគ្រប់វ័យទាំងអស់ លើកលែងចន្លោះអាយុ១៥ ដល់២៤ឆ្នាំ។ នេះអាចបណ្តាលមកពីការបោះ បង់ការសិក្សារបស់ស្ត្រី(៦៣,២%)មានអត្រាខ្ពស់ជាងបុរស(៥៧,១%)។ ក្នុងតំបន់ជនបទ ស្ត្រីអាយុ ១៥ ដល់២៤ឆ្នាំ ចំនួនប្រហែលជា៥០% មានការងារធ្វើ ហើយអត្រានេះកើនដល់៩១,៩%ក្នុងចំណោមស្ត្រីអាយុពី៥០ ដល់៥៤ឆ្នាំ។ ដោយឡែក អត្រាមានការងារធ្វើចំពោះស្ត្រីនៅទីប្រជុំជនដែលមានអាយុពី៣០ ដល់៣៤ឆ្នាំ ខ្ពស់បំផុតត្រឹម៦៩,៧%។

## ២.៥.បរិបទយេនឌ័រ កសិកម្ម និងការប្រែប្រួលអាកាសធាតុ

វិស័យកសិកម្មគឺជាវិស័យផលិតកម្ម និងឧស្សាហកម្មការងារដ៏ចម្បងសម្រាប់ស្ត្រីនៅជនបទដែលបានបង្ហាញនូវការបែងចែកយេនឌ័រក្នុងកំលាំងពលកម្ម រវាងការទទួលខុសត្រូវរបស់បុរសក្នុងការភ្ជួរស្រែ និងការទទួលខុសត្រូវរបស់ស្ត្រីក្នុងការសាបព្រោះ ស្ទូង និងការថែទាំ។ សម្រាប់ការធ្វើស្រែដែលពឹងផ្អែកលើទឹកភ្លៀង និងការគ្រប់គ្រងធនធានទឹក ពិតជាមានសារសំខាន់ណាស់។ ទោះជាយ៉ាងណា ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ផ្សេងៗ បានធ្វើឱ្យរាំងស្ទះដល់សមត្ថភាពអនុវត្តទាំងក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍ និងប្រជាពលរដ្ឋ ក្នុងការព្យាករណ៍ធាតុអាកាស ការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយដោយធម្មជាតិ ការគ្រប់គ្រងធនធានទឹក បច្ចេកទេសដាំដុះដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងសកម្មភាពរកប្រាក់ចំណូល ក្រៅពីវិស័យកសិកម្ម។ ដោយសារតែប្រជាជនតាមជនបទភាគច្រើនពឹងផ្អែកលើការធ្វើស្រែ ពឹងផ្អែកលើអាកាសធាតុ ហើយពួកគាត់ប្រឈមនឹងបាតុភូតធម្មជាតិធ្ងន់ធ្ងរ ដែលមានទំនាក់ទំនងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ។

[7] កកន ២០១៣ ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុសម្រាប់យេនឌ័រនឹងការប្រែប្រួលអាកាសធាតុ (២០១៣ដល់២០២៣), ភ្នំពេញ

កសិករទាំងពីរភេទដឹងពីរដូវភ្លៀងដែលមានរយៈពេលកាន់តែខ្លី ភ្លៀងធ្លាក់កាន់តែគំហុក និងកង្វះខាតទឹក។ បញ្ហានេះជះឥទ្ធិពលជាពិសេសចំពោះស្ត្រីក្រីក្រទាំងឡាយដែលភាគច្រើន ពិបាកក្នុងការទទួលបានធនធាន សិទ្ធិ និងមិនសូវបានផ្លាស់ទី ព្រមទាំងមិនសូវមានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ នៅពេលបច្ចុប្បន្នកសិករជាស្ត្រី មិនអាចកាត់បន្ថយការពឹងផ្អែកទៅលើមុខរបរដែលប្រែប្រួល ទៅតាមធាតុអាកាសបាននៅឡើយ និងបានបង្កើននូវតម្រូវការក្នុងការប្រើប្រាស់ធនធានធម្មជាតិ (ដូចជា សកម្មភាពកែច្នៃផលិតផលជលផល និងកសិកម្ម) ហើយស្ត្រីក៏មិនអាចពង្រីកការរកប្រាក់ចំណូលបានដែរ ដោយសារតែសមត្ថភាព និងឱកាសនៅមានកម្រិត។ ទាំងអស់នេះគឺដោយសារតែការទទួលបានចំណេះដឹងនៃផលិតកម្ម និងកែច្នៃផលិតផលកសិកម្មបែបទំនើបនៅមានកម្រិតស្របពេលដែលស្ត្រីមានបន្ទុកការងារមិនបានកម្រៃនានានៅក្នុងផ្ទះកាន់តែច្រើន និងត្រូវទទួលបន្ទុកមួយចំណែកនៃការងារបានប្រាក់កម្រៃ ដូច្នេះធ្វើអោយស្ត្រីលំបាកក្នុងការជៀសផុតពីមហន្តរាយផ្សេងៗដែលពាក់ព័ន្ធនឹងអាកាសធាតុ[8]។

ការប្រែប្រួលនៃអាកាសធាតុ តម្រូវការក្នុងការកែសម្រួលការបន្សាំ និងយន្តការឆ្លើយតបនានាបានធ្វើឱ្យមានការកើនឡើងនូវការធ្វើចំណាកស្រុកពីតំបន់ជនបទ។ ជាពិសេស ចំណាកស្រុកទៅក្រៅប្រទេសរបស់បុរសតាមរដូវកាល ឬរយៈពេលវែង អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើសមាជិកគ្រួសារជាពិសេសកុមារ ស្ត្រីជាម្តាយ និងជីដូនត្រូវទទួលភារកិច្ចថែទាំក្នុងលក្ខខណ្ឌដែលខ្សត់ធនធាន។ ឧស្សាហកម្មវាយនភ័ណ្ឌ គឺជាជម្រើសទូទៅមួយសម្រាប់ស្ត្រីដែលធ្វើការចំណាកស្រុក ទោះបីជាលក្ខខណ្ឌការងារត្រូវបានចាត់ទុកថាមិនទាន់ប្រសើរ ហើយឧស្សាហកម្មនេះបានរួមចំណែកទៅនឹងការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបំពុលដី និងធនធានទឹក ដែលនាំឱ្យជះឥទ្ធិពលអវិជ្ជមានដល់សុខភាពរបស់និយោជិត។ ជាងនេះទៅទៀត ការចូលរួមរបស់ស្ត្រីក្នុងសេវាកម្ម កំសាន្តសប្បាយ ម្ហូបអាហារបដិសណ្ឋារកិច្ច និងវិស័យការងារក្រៅប្រព័ន្ធ ក៏អាចជះឥទ្ធិពលអវិជ្ជមានដល់សុខមាលភាព ពិសេសសុខភាពរបស់ស្ត្រី ខណៈដែលឧស្សាហកម្មដែលពួកគាត់បម្រើការងារនោះបានរួមចំណែកក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបំពុល[9]។

## ២.៦ បរិបទសមធម៌យេនឌ័រ

### ភាពប្រឈមរបស់ស្ត្រីងាយរងគ្រោះចំពោះផលប៉ះពាល់នឹងការប្រែប្រួលអាកាសធាតុ

ស្ត្រីមានទំនួលខុសត្រូវកាន់តែច្រើននៅក្នុងកិច្ចការថែទាំ ដែលអាចសន្មត់បានថាអត្រាមរណៈរបស់ស្ត្រី អាចមានកាន់តែខ្ពស់ក្នុងពេលអាកាសធាតុអាក្រក់ខ្លាំង ដោយសារតែស្ត្រីគិតគូរពីជីវិតអ្នកដទៃជាងជីវិតខ្លួនឯង។ ស្ត្រីមិនទាន់មានជំនាញគ្រប់គ្រាន់ពីរបៀប ឬវិធីសាស្ត្រសង្គ្រោះជីវិត ដូចជា ការឡើងដើមឈើជាដើម ទន្ទឹមនឹងនោះដែរ ពួកគាត់អាចទទួលរងការបៀតបៀនកេរ្តិ៍ខ្មាស់ និងភាពស្មុគស្មាញនានាក្នុងអំឡុងពេលមានបញ្ហាហានិភ័យពីការប្រែប្រួលអាកាសធាតុបែបនេះ។

ដូចអ្វីដែលបានបញ្ជាក់ខាងលើ សុខភាពរបស់ស្ត្រីអាចត្រូវបានប៉ះពាល់ដោយការផ្លាស់ប្តូរអាកាសធាតុ និងរបៀបក្នុងការបន្សាំ។ សម្រាប់ស្ត្រីបម្រើការក្នុងឧស្សាហកម្មផលិតកម្ម លក្ខខណ្ឌការងារបានតម្រូវឱ្យមានការប្រឈមនឹងកម្តៅថ្ងៃ និងកម្តៅផ្សេងៗ ក្នុងអំឡុងការងារច្រើនម៉ោងជាមួយនឹងហានិភ័យនៃការបាត់បង់ជាតិទឹកក្នុងខ្លួន ភាពតានតឹងនឹងកម្តៅ និងជម្ងឺផ្សេងៗបង្ករដោយទឹក ភ្នាក់ងារ

8 មូលនិធិអាកាសធាតុបៃតង (២០១៨) ការប៉ាន់ប្រមាណយេនឌ័រ៖ FP076 គម្រោងវិស័យខ្សែចង្វាក់តម្លៃកសិ-អាជីវកម្ម Climate-Friendly Agribusiness ADB, Phnom Penh
9 កកន ២០១៣ ផែនការយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុសម្រាប់យេនឌ័រនឹងការប្រែប្រួលអាកាសធាតុ (២០១៣ -២០២៣), រាជរដ្ឋាភិបាលកម្ពុជា, ភ្នំពេញ

ចម្លងផ្សេងៗ និងភាពនឿយហត់។ ទោះជាយ៉ាងណា ឧស្សាហកម្មផលិតកម្មដែលបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលស្ត្រីជាច្រើនជ្រើសរើសជាយុទ្ធសាស្ត្របន្សាំមួយនោះ ក៏អាចជះឥទ្ធិពលចំពោះសុខភាពរបស់ពួកគាត់ ក្នុងទម្រង់ជាច្រើនដូចជា ការខ្សោះដោយសារកម្តៅ ការតក់ស្លុតធ្ងន់ធ្ងរ ការឆ្លងមេរោគតាមផ្លូវបង្ហូរទឹកនោម ជម្ងឺនៅក្នុងប្រហោងក្នុងឆ្អឹងប្រអប់ដៃ ភាពថ្លង់ ការឆ្លងជម្ងឺតាមផ្លូវដង្ហើម និងការលំបាកក្នុងការមើល។ សូម្បីតែស្ត្រីដែលម្ចាស់សហគ្រាសខ្នាតតូចនៅតាមផ្ទះ ដូចជា ការកែច្នៃចំណីអាហារ ឆ្អែរត្រី ឬផលិតក្អម ឆ្នាំងនិងចង្ក្រាន ក៏អាចមានផលប៉ះពាល់ខ្លាំងទៅលើសុខភាពរបស់ស្ត្រី និងក្មេងៗផងដែរ ដោយសារតែការប្រើប្រាស់ អុស និងធ្យូងជាប្រភពថាមពលចម្បង។ បញ្ហានេះដាក់បន្ទុកឲ្យសមាជិកគ្រួសារប្រឈមនឹងការឆ្លង ជម្ងឺផ្លូវដង្ហើម ក៏ដូចជាការចំណាយពេលវេលាក្នុងការប្រមូលអុស ធ្យូង និងទឹកសម្រាប់ការផលិត និងការប្រើប្រាស់ក្នុងផ្ទះ។

ក្នុងនាមជាអ្នកទទួលរ៉ាប់រងការងារចម្បង និងអ្នកផ្គត់ផ្គង់ចំណីអាហារ ស្ត្រីកាន់តែពឹងផ្អែកលើធនធានធម្មជាតិ សម្រាប់ធ្វើជាអាហារ ថ្នាំ អុស និងទឹក។ ទោះជាយ៉ាងណា ធនធានធម្មជាតិបែបប្រពៃណី ដូចជា ព្រៃកោងកាង ជលផល និងផលិតផលនានានឹងត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងពីកំណើនកម្តៅ ការផ្លាស់ប្តូររបបទឹកភ្លៀង និងការប្រើប្រាស់ដីធ្លី។ បញ្ហានេះនឹងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការចំណាយពេលវេលាសម្រាប់ស្ត្រី ព្រោះនៅពេលធនធានធម្មជាតិកាន់តែខ្សត់ និងត្រូវបានប្រើប្រាស់ហួសកម្រិត ស្ត្រីត្រូវការធនធាន ឬចំណូលផ្សេងទៀតដើម្បីជំនួស។

កង្វះខាតការទទួលបានវត្ថុធាតុដើមសម្រាប់ផលិតកម្មចំណីអាហារសំខាន់ៗរបស់ស្ត្រីនៅតាមជនបទ ដូចជា ពូជសម្រាប់ផលិតកម្មសត្វ សម្ភារ និងជី បានធ្វើឱ្យពួកគាត់ជួបការលំបាកដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ពីទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះ និងការសឹករិចរិលដី។ បញ្ហានេះអាចមានផលប៉ះពាល់ដោយផ្ទាល់ទៅលើការផ្តល់អាហារ ការថែទាំសមាជិកគ្រួសារ ជាមួយនឹងផលវិបាកចំពោះស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងការវិវឌ្ឍផ្នែកការយល់ដឹងយូរអង្វែង និងទៅលើលទ្ធភាពរក្សានូវគុណតម្លៃវប្បធម៌។

ដោយសារការចូលរួមរបស់ស្ត្រីក្នុងវិស័យអប់រំមានការធ្លាក់ចុះពីកម្រិតបឋមទៅមធ្យមសិក្សា ជាទូទៅស្ត្រីអាចទទួលបានផលប្រយោជន៍កាន់តែតិចពីសេវាកម្ម និងព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុដូចជា ព័ត៌មានឧតុនិយម ការដឹងជាមុនពី គ្រោះមហន្តរាយ នីតិវិធីគ្រប់គ្រងគ្រោះមហន្តរាយ និងតម្លៃទំនិញនៅលើទីផ្សារ និងការប្រែប្រួលផ្សេងៗទៀតដែលពាក់ព័ន្ធ។ ទាំងអស់នេះអាចនាំឱ្យស្ត្រីប្រឈមនឹងបញ្ហាផ្នែកហិរញ្ញវត្ថុ ដែលធ្វើឱ្យស្ត្រី ស្ថិតនៅក្រោមឥទ្ធិពលបុរស ដោយសារតែស្ត្រីមានសមត្ថភាពតិចក្នុងការគ្រប់គ្រង និងកំណត់បញ្ហានានា។

លើសពីនេះការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជាផ្លូវការនៅគ្រប់លំដាប់ថ្នាក់ នៅមានកម្រិតទាបជាងបុរស ឧទាហរណ៍: នៅក្នុងតំណែងដែលបានបោះឆ្នោតជ្រើសតាំងថ្នាក់ជាតិ គណៈអភិបាលថ្នាក់ខេត្ត ស្រុក ក្រុមប្រឹក្សាឃុំសង្កាត់ គណៈកម្មការភូមិ និងគណៈកម្មាធិការអភិវឌ្ឍន៍នានា។ ស្ថានភាពនេះបញ្ជាក់ថាស្ត្រីត្រូវបានគេយល់ថាគ្រាន់តែមានតួនាទីក្នុងគ្រួសារ ឬសហគមន៍ ឬមិនមានតួនាទីសំខាន់គ្រប់កម្រិតទាំងអស់[10]។

ក្នុងនាមជាអ្នកទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ចំណីអាហារ គឺត្រូវមើលការខុសត្រូវផ្នែកចម្អិន ស្ត្រីមានតួនាទីក្នុងការធ្វើឱ្យសេដ្ឋកិច្ចដំណើរការដោយមិនមានផលប៉ះដល់បរិស្ថាន តាមរយៈការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដូចជា: ផ្នែកសេវាកម្ម និងផ្នែកផលិតកម្ម។ តាមរយៈការផ្តល់ឱកាសការងារ

[10] កកន ២០១៣ ផែនការយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុសម្រាប់យេនឌ័រនឹងការប្រែប្រួលអាកាសធាតុ (២០១៣ -២០២៣), រាជរដ្ឋាភិបាលកម្ពុជា, ភ្នំពេញ

កាន់តែប្រសើរ ការការពារផ្នែកច្បាប់និងសង្គម និងសិទ្ធិ ភាពងាយរងគ្រោះរបស់ស្ត្រីចំពោះការប្រែប្រួលអាកាសធាតុអាចត្រូវបានកាត់បន្ថយ ខណៈដែលគោលនយោបាយសេដ្ឋកិច្ចជាតិកំពុងត្រូវបានគិតគូរពីការប្រែប្រួលអាកាសធាតុ។

## ២.៧ បរិបទគោលនយោបាយបញ្ជ្រាបយេនឌ័រ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវគ្រោងការណ៍ គោលនយោបាយ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជា និងយុទ្ធសាស្ត្របង្កើនភាពអង់អាចដល់ស្ត្រី។ យុទ្ធសាស្ត្រដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ ផ្តល់អាទិភាព៤ផ្នែកសំខាន់ៗ រួមមាន ១.ការធ្វើឱ្យប្រសើរនូវវិស័យកសិកម្ម ២.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៣.ការអភិវឌ្ឍវិស័យឯកជននិងមុខរបរ និង៤.ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស។ ខណៈនោះមិនទាន់មានឯកសារយោងច្បាស់លាស់នៃសមភាពយេនឌ័រ ការលើកកម្ពស់ស្ត្រីចូលរួមក្នុងវិស័យសេដ្ឋកិច្ច និងការបង្កើនភាពអង់អាចដល់ស្ត្រី គឺការគាំទ្រការបញ្ជ្រាបយេនឌ័រដោយបញ្ចូលទៅក្នុងការអនុវត្តការងាររបស់រាជរដ្ឋាភិបាល និងចាប់ផ្តើមជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ក្រសួងកិច្ចការនារីបានចូលរួមក្នុងការបង្កើតផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ (២០១៤-២០២៣) ដោយមានការសម្របសម្រួលដោយក្រសួងបរិស្ថាន។ ក្រសួងកិច្ចការនារី និងក្រុមការងារបញ្ជ្រាបយេនឌ័រនៅតាមក្រសួងនីមួយៗ គាំទ្រការបង្កើនភាពអង់អាចដល់ស្ត្រីដោយបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យនីមួយៗ។ នៅក្នុងឆ្នាំ២០១៣ ជាមួយគោលដៅអភិវឌ្ឍន៍សហសវត្សន៍បានកំណត់យុទ្ធសាស្ត្រ និងតម្រូវការក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដើម្បីចូលរួមការសម្រេចបានគោលដៅអភិវឌ្ឍសហសវត្សក្នុងការកាត់បន្ថយភាពក្រីក្រ សុខភាព និងការអប់រំ ហើយក្រសួងកិច្ចការនារីត្រូវបានទទួលស្គាល់ក្នុងការរៀបចំក្របខ័ណ្ឌពន្លឿនផែនការសកម្មភាពប្រទេសកម្ពុជា ដើម្បីគោលដៅអភិវឌ្ឍន៍សហសវត្សរួមជាមួយនឹងការកំណត់ពីតម្រូវការដើម្បីផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីឱ្យស្របតាមតម្រូវការទីផ្សារ និងការអភិវឌ្ឍសមត្ថភាពស្ត្រីក្នុងការចូលរួមលើកកម្ពស់សេដ្ឋកិច្ច សហគ្រាសខ្នាតតូច និងមធ្យម និងការបង្កើនលទ្ធភាពក្នុងការក្លាយជាសហគ្រិនអាជីវកម្មក្នុងប្រព័ន្ធ នឹងលើកកម្ពស់ជីវភាព សហគមន៍ដែលទន់ខ្សោយ (ជាពិសេសសម្រាប់ស្ត្រី) ។

នៅក្នុងឆ្នាំ២០១៤ ក្រសួងកិច្ចការនារីបានផ្សព្វផ្សាយជាសាធារណៈនូវឯកសារការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងផែនការយុទ្ធសាស្ត្រ៥ឆ្នាំសម្រាប់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី(នារីរតនៈទី៤)។ នៅក្នុងនោះផងដែរ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីគឺជាអនុសាសន៍គោលនយោបាយគន្លឹះមួយ ដែលរួមបញ្ចូលផងដែរនូវផ្នែកស្ត្រីក្នុងវិស័យកសិកម្ម ស្ត្រីក្នុងវិស័យអប់រំ ស្ត្រីក្នុងវិស័យសុខភាព ស្ត្រីក្នុងវិស័យនយោបាយ និងបានផ្តោតជាក់លាក់ជាមួយយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ រួមទាំងមានកិច្ចព្រមព្រៀង ការប្តេជ្ញាចិត្តក្នុងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដូចជាអនុសញ្ញានៃការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលបានចុះហត្ថលេខានៅខែមករា ឆ្នាំ២០១១ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅទី៥ សមភាពយេនឌ័រ និងបានបញ្ចូលយេនឌ័រក្នុងគោលដៅនានានៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីដែលស្ថិតនៅក្រោមឱវាទក្រសួងកិច្ចការនារី ត្រូវបានផ្តួចផ្តើមបង្កើតនៅឆ្នាំ១៩៩៨ គឺជាមជ្ឈមណ្ឌលដែលផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ស្ត្រី។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីបានដំណើរការនៅខេត្តចំនួន១៤ ដែលមានមន្ត្រីប្រតិបត្តិចំនួនសរុប១៣៨ និងមានស្ត្រីដែលទទួលបានការបណ្តុះបណ្តាលចំនួនជាង ៣,០០០នាក់ជារៀងរាល់ឆ្នាំ។ ក៏ប៉ុន្តែសេវាបណ្តុះបណ្តាល ហាក់ដូចជាជះឥទ្ធិពលបន្តិចបន្តួចប៉ុណ្ណោះទៅដល់សហគមន៍។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីបានធ្វើការបញ្ជ្រាបជំនាញចំណេះដឹងអាជីវកម្មជាមូលដ្ឋាន ជំនាញចាត់ចែងថវិកា និងជំនាញបំណិនជីវិតទៅក្នុងកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើនគុណភាពដល់សិស្សមជ្ឈមណ្ឌលឈានទៅចាប់យកមុខរបរចិញ្ចឹមជីវិត និងបានសហការជាមួយអង្គការស្វីសខន់តាក់អនុវត្តកម្មវិធីអភិវឌ្ឍន៍ជំនាញសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការបណ្តុះបណ្តាលជំនាញនៅមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី។ យោងទៅតាមភាពជាក់ស្តែងនៃសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ដែលកំពុងតែផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចបែបបច្ចេកវិទ្យា ក្រសួងកិច្ចការនារីមានគោលដៅបង្កើនសមត្ថភាព និងជំនាញ របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងមន្ទីរកិច្ចការនារី ក្នុងការផ្តល់សេវាកម្មភ្ជាប់ជាមួយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ក្នុងនេះមជ្ឈមណ្ឌលចំនួន៤ ត្រូវបានរៀបចំអោយទៅជាមណ្ឌលផ្សព្វផ្សាយព័ត៌មាននិងទំនាក់ទំនងដោយប្រើបច្ចេកវិទ្យា។ មជ្ឈមណ្ឌល ផ្តល់វគ្គបណ្តុះបណ្តាល ផ្តល់ព័ត៌មាន និងសេវាផ្សេងទៀត ដើម្បីឆ្ពោះទៅរកការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅមូលដ្ឋានដោយលើកកម្ពស់ការទទួលបាន ព័ត៌មាន ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ជំនាញនិងចំណេះដឹងស្ទូល និងសហគ្រិនភាព។

ជាមួយឯកសារយោងច្បាស់លាស់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគោលនយោបាយបញ្ជ្រាបយេនឌ័រ និងយុទ្ធសាស្ត្រនៅក្នុងវិស័យកសិកម្ម ឆ្នាំ២០១៦-២០២០ មានគោលបំណងលើកកម្ពស់ការចូលរួមរបស់ស្ត្រីអោយក្លាយជាមន្ត្រីរាជការ អភិវឌ្ឍន៍សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ និងអភិវឌ្ឍន៍សមត្ថភាពស្ត្រីជនបទក្នុងការទទួលបាន និងគ្រប់គ្រងធនធានកសិកម្ម និងវត្ថុធាតុដើមនានាដោយរួមបញ្ចូលផងដែរ នូវសមភាពក្នុងការទទួលបានសេវា ក៏ដូចជាការគាំទ្រក្នុងការទទួលបានដីសម្បទានការចូលរួមក្នុងវិស័យឯកជន ការចូលរួមក្នុងក្រុមសហគមន៍ និងការទទួលបានឥណទាន[11]។

ខណៈពេលដែលប្រទេសកម្ពុជាមានសក្តានុពលយ៉ាងទូលំទូលាយក្នុងការបញ្ជ្រាបយេនឌ័រ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអន្តរវិស័យ យ៉ាងណាក៏ដោយ ក៏កម្ពុជានៅមានកង្វះខាតក្របខ័ណ្ឌណែនាំសម្រាប់ឆ្លើយតបទៅនឹងចំណុចអាទិភាព នៃការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់ផ្សេងៗសម្រាប់បុរសនិងស្ត្រី ។ ដូច្នេះ "ឧបករណ៍" សម្រាប់ធ្វើការវាស់វែង និងឆ្លើយតបគួរតែត្រូវបានរៀបចំ។ ក្នុងការសម្រេចឲ្យបានតាមគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនការចូលរួមក្នុងការលើកកម្ពស់សេដ្ឋកិច្ចទីផ្សារសេរី និងធានាឱ្យបាននូវស្ថេរភាពនយោបាយ និងសង្គម បញ្ហាការប្រែប្រួលអាកាសធាតុគួរត្រូវបានដោះស្រាយដោយមានការគិតគូរពីយេនឌ័រ ។ តម្រូវការទាំងនេះរួមបញ្ចូលការគិតគូរពីការវិនិយោគដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ រួមទាំងការធ្វើផែនការថវិកានិងការអនុវត្ត។ ផែនការមេត្រូវបានបង្កើតឡើងដើម្បីណែនាំពីការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពពាក់ព័ន្ធទាំងអស់ ក្នុងរយៈពេល ១២ឆ្នាំខាងមុខ ស្របគ្នាទៅនឹងកាលបរិច្ឆេទផុតកំណត់នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ហើយក៏នឹងធានាថា ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិនាពេលខាងមុខ (ឆ្នាំ២០១៩-២០២៣) ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ (២០១៩-២០២៣) និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀតត្រូវបានបន្សុីគ្នា។

[11] MacPhail.F. (២០១៥). ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅកម្ពុជា របស់ធនាគារអភិវឌ្ឍន៍អាស៊ី, ភ្នំពេញ

## ២.៨. បរិបទការកសាងសមត្ថភាពស្ថាប័ន

មកដល់ពេលបច្ចុប្បន្ននេះ មានគំនិតផ្តួចផ្តើមសំខាន់ៗមួយចំនួនដូចជា ផែនការសកម្មភាពជាតិសម្រាប់គម្រោងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) (២០០៩-២០១៥) និង ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០២៣ (វិច្ឆិកា២០១៣) ជាមួយគ្នានេះផងដែរក៏មានផែនការសកម្មភាពប្រែប្រួលអាកាសធាតុឆ្នាំ២០១៦-២០១៨ និងផែនការសកម្មភាពតាមវិស័យផ្សេងទៀត ។ ក្នុងនោះក៏មានគំនិតផ្តួចផ្តើមជាក់លាក់ផ្សេងទៀត ដែលទាក់ទងនឹងការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ និងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ដែលបានអនុវត្ត និងកំពុងតែអនុវត្តដោយ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) គណៈកម្មការទន្លេមេគង្គ (MRC) គណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (NCSD)គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) អង្គការសង្គមស៊ីវិលនានា ជាមួយនិងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិបរិស្ថានសកល មូលនិធិជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ កម្មវិធី បរិស្ថាន អង្គការសហប្រជាជាតិ ធនាគារពិភពលោក ដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយទ្វេរភាគីនានា។

**ការកសាងសម្ថភាព:** ស្ថាប័នដែលមានសមត្ថភាពគ្រប់គ្រាន់ គឺនាំមកនូវលទ្ធផលជោគជ័យសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះផងដែរ "សមត្ថភាព" ត្រូវបានកំណត់ដោយ (១)ភាពរឹងមាំនៃក្របខ័ណ្ឌច្បាប់ (២)ឧបករណ៍ប្រើប្រាស់ដែលងាយស្រួល (សៀវភៅព័ត៌មាន និងការណែនាំ) (៣)ជំនាញ (ដើម្បីប្រើប្រាស់ឧបករណ៍) (៤) ចំណេះដឹងទូលំទូលាយជាមូលដ្ឋាន (ក្នុងការគាំទ្រការសម្រេចចិត្តទាន់ពេលវេលា និងត្រឹមត្រូវ) និង (៥)ធនធានហិរញ្ញវត្ថុ (ដើម្បីអនុវត្តគម្រោងនានា) ។

**អាណត្តិ:** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៨ (ច្បាប់អង្គការ) ជាមូលដ្ឋានមួយរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ដែលជាកម្មវិធីជាតិមានរយៈពេល១០ឆ្នាំ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋានីយកម្ម ។ ដូច្នេះហើយ គ.ជ.អ.ប ត្រូវបានបង្កើតតាមរយៈព្រះរាជក្រឹត្យនៅខែធ្នូ ក្នុងឆ្នាំជាមួយគ្នានឹងឆ្នាំបង្កើតច្បាប់ដើម្បីអនុវត្តទៅលើច្បាប់ និងគោលនយោបាយវិមជ្ឈការ និងមូលដ្ឋានីយកម្ម ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ហើយត្រូវបានធ្វើឱ្យមានភាពរឹងមាំតាមរយៈច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ដែលបង្កើតឡើងក្នុងខែមិថុនាឆ្នាំ២០១៥ ស្របពេលជាមួយគ្នានេះផងដែរគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើតផងដែរ ។

**ឧបករណ៍:** សៀវភៅព័ត៌មាន ការណែនាំ និង ឯកសារដែលចាំបាច់មួយចំនួនត្រូវបានបង្កើត និងប្រមូលផ្តុំឡើង ដូចដែលបង្ហាញជាឧទាហរណ៍ក្នុងតារាងទី២ ខាងក្រោម។ គួរឱ្យកត់សំគាល់ផងដែរថាទោះបីជាមានឯកសារមួយចំនួនបានយកចិត្តទុកដាក់ពីបរិយាប័ន្នសង្គម ក៏ប៉ុន្តែក៏នៅមានភាពខ្វះខាតនូវឯកសារជាក់លាក់ទាក់ទងនឹងយេនឌ័រ។ បញ្ហានេះតម្រូវឱ្យមានការធ្វើឱ្យប្រសើរឡើងនូវការដាក់បញ្ចូល និងបញ្ជ្រាបការគិតគូរអំពីយេនឌ័រទៅក្នុងការរៀបចំផែនការបន្សុាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការរៀបចំផែនការថវិកា និងផែនការការអនុវត្ត។

*តារាងទី២- ឧទាហរណ៍នៃឯកសារទាក់ទងទៅនឹង កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ក្រោមជាតិ*

| អ្នកបោះពុម្ព | ចំណងជើង | គម្រោង/កម្មវិធី |
|---|---|---|
| គ.ជ.អ.ប (ខែកក្កដា ឆ្នាំ២០១៨) | គម្រោងហិរញ្ញប្បទានថ្មៃប្រឌិតសម្រាប់បញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅថ្នាក់ខេត្ត ស្រុក និងឃុំ | ជំនួយបច្ចេកទេស លេខ៨១៧៩ កញ្ចប់ (គ) |
| រាជរដ្ឋាភិបាលកម្ពុជា/ គ.ជ.អ.ប (ខែតុលា ឆ្នាំ២០១៧) | សៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិ ឃុំ សង្កាត់ | |
| គ.ជ.អ.ប (ខែកញ្ញា ឆ្នាំ២០១៧) | ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍និងផែនការវិនិយោគរបស់ខេត្ត ស្រុក និង ឃុំ | ជំនួយបច្ចេកទេស លេខ៨១៧៩ កញ្ចប់ (គ) |
| ភាពជាដៃគូរសម្រាប់ធនធានទឹកក្នុងប្រទេសកម្ពុជា (CamboWP) (ខែមករា ឆ្នាំ២០១៧) | ក្របខ័ណ្ឌ និងគោលនយោបាយសង្ខេបស្តីពីសុវត្ថិ-ភាពទឹក | កម្មវិធីអភិវឌ្ឍន៍អាកាសធាតុ និងភាពជាដៃគូរសម្រាប់ធនធានទឹកសកល (WACDEP) |
| គ.ជ.អ.ប (ខែមេសា ឆ្នាំ២០១៧) | ការបញ្ជ្រាបគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងដំណើរការកម្មវិធីវិនិយោគបីឆ្នាំរំកិល | |
| ក្រសួងមហាផ្ទៃ និងក្រសួងផែនការ (ខែមីនា ឆ្នាំ២០១៧a) | សេចក្តីណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ (ឃុំ សង្កាត់) | |
| ក្រសួងមហាផ្ទៃ និងក្រសួងផែនការ (ខែមីនា ឆ្នាំ២០១៧b) | សេចក្តីណែនាំស្តីពីការរៀបចំកម្មវិធីវិនិយោគ (ឃុំ សង្កាត់) | |
| ក្រសួងមហាផ្ទៃ និងក្រសួងផែនការ (ខែមីនា ឆ្នាំ២០១៧c) | សេចក្តីណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ស្រុក | |
| ក្រសួងមហាផ្ទៃ និងក្រសួងផែនការ (ខែមីនា ឆ្នាំ២០១៧d) | សេចក្តីណែនាំស្តីពីការរៀបចំកម្មវិធីវិនិយោគស្រុក | |
| គ.ជ.អ.ប (ខែកញ្ញា ឆ្នាំ២០១៦) | សៀវភៅណែនាំស្តីពី គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចសម្រាប់ការអនុវត្តនិងការគ្រប់គ្រងសំណង់ ការស្តារនីតិសម្បទានៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ថ្នាក់ស្រុក | គម្រោងកាត់បន្ថយគ្រោះមហន្តរាយសហគមន៍ (CDRR) សមាសភាគ (គ) |
| ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ខែកក្កដា ឆ្នាំ២០១៦) | លើកកម្ពស់ការចូលរួមរបស់វិស័យឯកជនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា | |

| | | |
|---|---|---|
| កម្មវិធីអភិវឌ្ឍន៍នៃសហ ប្រជាជាតិ ប្រចាំប្រទេស កម្ពុជា (ខែធ្នូ ឆ្នាំ២០១៤) | ឯកសារគោលការណ៍ណែនាំសម្រាប់អ្នកអនុវត្ត: ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ | |
| គណ:កម្មាធិការជាតិទន្លេមេគង្គ(ខែតុលា ឆ្នាំ២០១៤) | ការវិភាគការប្រែប្រួលអាកាសធាតុក្នុងអាងទន្លេមេគង្គ | ព្រឹត្តិបត្តិលេខ ៥២ របស់ គណ:កម្មាធិការជាតិទន្លេមេគង្គ |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ខែឧសភា ឆ្នាំ២០១៤) | ព្រះរាជាណាចក្រកម្ពុជា: ការពង្រឹងកិច្ចសម្របសម្រួលសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ | គម្រោងជំនួបច្ចេកទេសកសាងសមត្ថភាព លេខ៤៦២៣០ |
| ក្រសួងបរិស្ថាន (ខែមករា ឆ្នាំ២០១៤) | យន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងការរៀបចំផែនការរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ | កម្មវិធីបន្សាំ និងវាយតម្លៃភាពងាយរងគ្រោះរបស់ CCCA |
| ក្រសួងបរិស្ថាន (ឆ្នាំ២០១៣) | គោលការណ៍ណែនាំក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយក្នុងការរៀបចំផែនការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | PPCR សមាសភាគទី ២ |
| ក្រសួងបរិស្ថាន (ឆ្នាំ២០១៣) | វិធានក្នុងការវិភាគធាតុអាកាស | PPCR សមាសភាគទី ២ |
| គណ:កម្មាធិការជាតិទន្លេ មេគង្គ (ខែមិថុនា ឆ្នាំ២០១០) | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍចំពោះរបបទឹកទន្លេមេគង្គ | ព្រឹត្តិបត្តិលេខ ២៩ របស់ គណ:កម្មាធិការជាតិទន្លេមេគង្គ |
| គណ:កម្មាធិការជាតិទន្លេមេគង្គ(ខែកញ្ញា ឆ្នាំ២០០៩) | ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសនៃអាងទន្លេមេគង្គ: របាយការណ៍សំយោគថ្នាក់តំបន់ | ព្រឹត្តិបត្តិលេខ ២៤ របស់ គណ:កម្មាធិការជាតិទន្លេមេគង្គ |

**ការអភិវឌ្ឍជំនាញ:** គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ (LGCC) ត្រូវបានអនុវត្តដោយ គ.ជ.អ.ប ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨ ជាមួយនឹងការគាំទ្រថវិកា (៤,៥លានដុល្លាសហរដ្ឋអាមេរិក) ពីជំនួយអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍសមត្ថភាព (UNCDF) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអ៊ែត (SIDA) ។ គម្រោងនេះបានផ្តល់ជូននូវវគ្គបណ្តុះបណ្តាលទូលំទូលាយ ទាក់ទងនឹងគម្រោងកសាងចំណេះដឹង ការអភិវឌ្ឍនីតិវិធី និងគោលការណ៍ណែនាំគោលដៅហិរញ្ញវត្ថុ ការលើកទឹកចិត្តឱ្យមានកិច្ចសហប្រត្តិបត្តការរវាងក្រុមប្រឹក្សាស្រុក ក្រុង និងឃុំសង្កាត់ និងថ្នាក់រដ្ឋបាល ព្រមទាំងការអនុវត្តគម្រោងសាកល្បង។ ក្នុងពេលបច្ចុប្បន្ននេះជំនួយបច្ចេកទេសលេខ ៨១៧៩ កញ្ចប់ (គ) បាននឹងកំពុងអនុវត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ ហើយសមាសភាគមួយនៃគម្រោងនេះត្រូវបានអនុវត្តដោយ គ.ជ.អ.ប ។ សកម្មភាពទាក់ទងនឹងគម្រោងនេះរួមមានសិក្ខាសាលាបណ្តុះបណ្តាលដែលមានចំនួន ៩ម៉ូឌុល (១) ក្រុមប្រឹក្សាឃុំក្នុងប្រទេសកម្ពុជា

២)ការវិភាគពីភាពងាយរងគ្រោះនិងពិនិត្យហានិភ័យដែលជាផ្នែកមួយនៃដំណើរការរៀបចំផែនការ និងថវិកា (៣)ភាពធន់នឹងអាកាសធាតុក្នុងការបង្កើត និងអនុវត្តគម្រោង និង(៤)តាមដាន និងវាយតម្លៃសមត្ថភាពនៃការបន្សុាំ។

**មូលដ្ឋានចំណេះដឹង:** ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន្នទៅលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (UNFCCC) នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៥ និងបានយល់ស្របទៅលើពិធីសារក្យូតូ (Kyoto Protocol ) នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០២ ។ របាយការណ៍ថ្នាក់ជាតិលើកដំបូងបានផ្ញើទៅកាន់ UNFCCC ដោយក្រសួងបរិស្ថាននាខែតុលាឆ្នាំ២០០២ ហើយរបាយការណ៍ថ្នាក់ជាតិលើកទី២ត្រូវបានផ្ញើដោយគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព នាខែវិច្ឆិកា ឆ្នាំ២០១៥។ របាយការណ៍ទាំងនេះផ្តល់នូវទិដ្ឋភាពទូទៅនៃការវិវឌ្ឍរបៀបវារៈរបស់កម្ពុជាសម្រាប់ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយមានការបង្ហាញនូវព័ត៌មានលំអិតនានា។ លើសពីនេះទៅទៀត គណៈកម្មាការទន្លេមេគង្គ បានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ជាចំណេះដឹង ដើម្បីគាំទ្រការកសាងការយល់ដឹង ការបង្កើតឯកសារ ការកសាងសមត្ថភាព និងការអនុវត្តល្អៗនានា ដែលទាក់ទងនឹងភាពធន់នឹងអាកាសធាតុ និងគម្រោងបន្សុាំ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅតែមានតម្រូវការព័ត៌មានដែលទាក់ទងនឹងប្រធានបទសំខាន់ៗដូចជា (១) ប្រជាសាស្ត្រនិងជីវភាពរស់នៅ រួមបញ្ចូលទាំងនិន្នាការទាក់ទងនឹងបញ្ហាទាំងនោះ (២) ឧតុនិយមដែលមាន ដូចជាការពិនិត្យទៅលើកម្រិតទឹកភ្លៀងធម្មតា និងភ្លៀងខ្លាំង (រួមបញ្ចូលគ្នារវាងទិន្នន័យពីផ្កាយរណប ជាមួយនិងស្ថានីយ៍ដែលនៅផ្ទាល់ដី) (៣)តំបន់ ប្រើប្រាស់ដីដំណាំ រួមបញ្ចូលទាំងនិន្នាការនានា (៤) ការបំផ្លាញប្រភពទឹក ឬទឹកដែលបង្ករជាជំងឺ (៥) ស្ថានភាពទីជម្រក និងប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ រួមបញ្ចូលទាំងតំបន់ឆ្នេរ តំបន់សមុទ្រ និងនិន្នាការនានា (៦) 'តំបន់ប្រឈមខ្លាំងភ្លា' និង 'តំបន់បៃតង' (ឬធនធាន[12]) (៧) ព្រឹត្តិការណ៍នានា ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះព្រៃ ការបាក់ដី ការបំពុល ការផ្លិចបំផ្លាញដោយសត្វល្អិត និងនិន្នាការនានា ។ល។ (៨)ការប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះ រួមទាំងនិន្នាការនិងការព្យាការណ៍នានា[13] ។

វិសាលភាពនៅតែមានសម្រាប់ការពង្រីកចំណេះដឹងជាមូលដ្ឋាន ហើយទាំងនេះត្រូវមានការតាមដានជាទៀងទាត់ តាមរយៈការប្រើប្រាស់នូវទិន្នន័យបឋមដែលត្រូវបានប្រមូលយកមកប្រើប្រាស់ក្នុងគោលបំណង កសាងបណ្តាញ និងចែករំលែកនូវភាពជោគជ័យពីសកម្មភាពគម្រោងសាកល្បង និងការអនុវត្តជាក់ស្តែងផ្សេងទៀត រួមទាំងការពង្រឹងនូវសេវាកម្មផ្សព្វផ្សាយដើម្បីគាំទ្រការឆ្លើយតបទាន់ពេលវេលា និងសមស្របចំពោះព្រឹត្តិការណ៍នានា ក៏ដូចជាបញ្ហាប្រឈមនិងឱកាសដែលនឹងកើតមានក្នុងពេលអនាគត។

**ផ្តល់ហិរញ្ញប្បទានដល់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជាក់លាក់ ៖** ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងការត្រៀមបង្ការគ្រោះមហន្តរាយ ទាមទារនូវការផ្តល់ហិរញ្ញប្បទានពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅកាន់កម្រិតសហគមន៍ និងកម្រិតគ្រួសារ រួមបញ្ចូលទាំងការវិនិយោគ ការធ្វើ

[12] ទ្រព្យសកម្មគឺជាលក្ខណពិសេសដ៏មានតម្លៃ។ ទ្រព្យសម្បត្តិមួយចំនួនគឺពាក់ព័ន្ធនឹង NRE, ឧទាហរណ៍សក្តានុពលវារីអគ្គិសនី តំបន់ដីសើម តំបន់ជលផល ទឹកជ្រោះឬទន្លេនៅខាងមុខទីក្រុង។ ទ្រព្យសម្បត្តិទាំងនេះមិនអាចត្រូវបានផ្លាស់ប្តូរ។ តម្លៃរបស់ពួកគាត់ - មិនថាសេដ្ឋកិច្ច សង្គមឬវប្បធម៌ - អាចជាបន្ទាន់ឬសក្តានុពល។ សូមមើល Muanpong Juntopas ( ខែកុម្ភៈឆ្នាំ 2010 )

[13] បានកែសម្រួលបន្ទាប់ពីក្រសួងបរិស្ថាន ( ឧសភា 2017a )

ប្រតិបត្តិការ និងការថែទាំ ការស្តារឡើងវិញ និងការផ្តល់ប្រព័ន្ធធានារ៉ាប់រង ។ ឧទាហរណ៍: គម្រោងប្រែប្រួលអាកាសធាតុដែលទាក់ទងនឹងហិរញ្ញវត្ថុ ត្រូវបានបង្ហាញក្នុងតារាងទី៣ខាងក្រោម។

គម្រោងទាំងនេះ មានសារសំខាន់ក្នុងការកសាងសមត្ថភាពបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន សម្រាប់អនុវត្ត និងវាស់វែងនូវភាពធន់នឹងអាកាសធាតុ។ ទោះបីជាយ៉ាងណាក៏ដោយ កង្វះខាតចំណេះដឹងបច្ចេកទេសក្នុងការតាក់តែង និងអនុវត្តគម្រោងវិនិយោគភាពធន់នឹងអាកាសធាតុ ត្រូវបានកំណត់ថា ជាកង្វល់មួយដ៏ធំ ដែលនាំឱ្យមានភាពយឺតយ៉ាវក្នុងការអនុវត្តគម្រោង ។

*តារាងទី៣- គម្រោងហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុសំខាន់ៗ (បានបញ្ចប់ កំពុងដំណើរការ និងបានរៀបចំសំណើរ)*

| |
|---|
| **កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ចាប់ពីឆ្នាំ ២០១៧ មានថវិកាប្រមាណ ៥២ លានដុល្លាសហរដ្ឋអាមេរិក** កម្មវិធីនេះមានគោលដៅ ធ្វើការសាកល្បងបច្ចេកទេស ដែលមានភាពធន់ទៅនឹងអាកាសធាតុតាមរយៈការច្នៃប្រឌិតសម្រាប់ប្រជាកសិករខ្នាតតូចក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះ មានគោលបំណងចំនួន៣ រួមមាន (១) បង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលប្រកបដោយចីរភាព (២) បន្សាំ និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និង (៣) កាត់បន្ថយ ឬបញ្ឈប់ការបំភាយនូវឧស្ម័នផ្ទះកញ្ចក់តាមដែលអាចធ្វើបាន។ |
| **មូលនិធិកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (The CCCA Trust Fund) ជំហានទី ១ ពីឆ្នាំ ២០១០-២០១៤ មានថវិកាប្រមាណ ១១ លានដុល្លាសហរដ្ឋអាមេរិក (ជាផ្នែកមួយនៃក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុនៅកម្ពុជា** CCFF) មូលនិធិនេះមានគោលដៅ គាំទ្រការអភិវឌ្ឍសមត្ថភាព និងការពង្រឹងស្ថាប័ន ដើម្បី ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ធានាឱ្យមានការដាក់បញ្ចូលនូវបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោង និងលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ |
| **មូលនិធិកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (The CCCA Trust Fund) ជំហានទី ២ ពីឆ្នាំ ២០១៤-២០១៩ មានថវិកាប្រមាណ ១៣ លានដុល្លាសហរដ្ឋអាមេរិក** មូលនិធិនេះបង្កើតឡើងក្នុងគោលដៅ ពង្រឹងអភិបាលកិច្ចនៃការប្រែប្រួលអាកាសធាតុ គាំទ្រការអនុវត្តគម្រោងយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងអភិវឌ្ឍធនធានមនុស្ស ឧបករណ៍ ការគ្រប់គ្រងចំណេះដឹងក្នុងការគាំទ្រភាពធន់នឹងការប្រែប្រួលអាកាសធាតុ ។ |
| **គម្រោងជំនួយដោយផ្ទាល់ (The Direct Aid Program - DAP) ពីឆ្នាំ២០១៦-២០១៨** ថវិកាស្ថិតក្នុងការពិគ្រោះយោបល់ (អនុវត្តដោយក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី ) DAP គឺជាកម្មវិធីជំនួយខ្នាតតូចអាចបត់បែនបាន គាំទ្រការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលធ្វើឡើងដោយបុគ្គល ក្រុមសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល។ |
| **កម្មវិធីបន្សាំនៅតាមសហគមន៍ក្នុងប្រទេសកម្ពុជា (CCBAP) ពីឆ្នាំ២០១០-២០១៥ មានថវិកាប្រមាណ ៩,៥ លានដុល្លាសហរដ្ឋអាមេរិក** សកម្មភាពសម្រាប់គម្រោងនេះរួមមាន ការជួសជុលប្រឡាយ អាងស្តុកទឹក ស្រះសហគមន៍ និងស្រះនៅតាមផ្ទះ ការសាងសង់អណ្តូង ផ្គត់ផ្គង់ទឹកសម្រាប់ប្រមូលផល ការចងក្រងក្រុមសន្សំប្រាក់ និងធនាគារស្រូវ។ មានគម្រោងសាកល្បងចំនួន៧ សម្រាប់បញ្ជ្រាបបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការថ្នាក់ក្រោមជាតិ ដែលត្រូវបានអនុវត្តក្រោមការគាំទ្រដោយ គ.ជ.អ.ប ។ |

| |
|---|
| **កម្មវិធីបង្កើនការប្រើប្រាស់ឡើងវិញនូវប្រព័ន្ធបច្ចេកវិទ្យាថាមពលក្នុងតំបន់ជនបទក្នុងប្រទេសកម្ពុជា (SRET) ពីឆ្នាំ២០១៧-២០២១ មានថវិកាប្រមាន ៥ លានដុល្លាសហរដ្ឋអាមេរិក**<br>កម្មវិធីនេះមានគោលបំណងលើកកម្ពស់ការប្រើប្រាស់ឡើងវិញនូវប្រព័ន្ធបច្ចេកវិទ្យាថាមពលក្នុងវិស័យកសិកម្ម ។ |
| **មូលនិធិអាកាសធាតុបៃតង (GCF Scale-up) ពីឆ្នាំ២០១៨-២០២២ ថវិកាស្ថិតក្រោមការពិភាក្សា**<br>(បង្កើតនូវសមាសភាគទទួលមូលនិធិដោយផ្ទាល់) អាស្រ័យទៅតាមជំនួយដែលមាន ថវិកាមកពី GCF អាចនឹងធ្វើការគាំទ្របានពី ៥០ ទៅ ៦០ស្រុកដែលអាស្រ័យទៅតាមសន្ទស្សន៍នៃភាពងាយរងគ្រោះដោយសារអាកាសធាតុដែលផ្តល់ដោយក្រសួងបរិស្ថាន តាមរយៈការប្រើប្រាស់ទិន្នន័យឃុំសង្កាត់ (CDB)។ |
| **មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) កំពុងរៀបចំសំណើ**<br>SNIF នឹងត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣កម្រិត (១) ថ្នាក់ខេត្ត (២)ថ្នាក់ស្រុក និងក្រុង និង(៣)ថ្នាក់ឃុំ និងសង្កាត់។ |

*ប្រភព: គ.ជ.អ.ប (ខែវិច្ឆិកា ឆ្នាំ២០១៧) សម្រាប់ព័ត៌មានលំអិតអំពីគម្រោងនីមួយៗ សូមពិនិត្យមើលឯកសារដើម*

ការវិភាគពីបទពិសោធរបស់កម្ពុជាមានភាពស្របគ្នាយ៉ាងខ្លាំងជាមួយនឹងការជជែក និងពិភាក្សានៅលើឆាកអន្តរជាតិ និងឯកសារស្រាវជ្រាវដែលមានស្រាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គម្រោងពាក់ព័ន្ធនឹងអាកាសធាតុក្នុងតំបន់។ ក្នុងការជជែកជាសកល មានកិច្ចព្រមព្រៀងទូទៅស្តីពីសសរស្តម្ភទាំង ៤ ដែលរួមចំណែកសម្រេចបានភាពជោគជ័យនៃក្របខ័ណ្ឌរបស់ប្រទេសនីមួយៗ (ហិរញ្ញវត្ថុ បច្ចេកទេស) ៖

***ក. បរិយាកាសជំរុញថ្នាក់ស្ថាប័នសម្រាប់ហិរញ្ញវត្ថុផ្នែកអាកាសធាតុ៖***

ស្វ័យភាព និងអំណាច ដែលស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ នឹងត្រូវបានកំណត់យ៉ាងទូលំទូលាយ ក្នុងក្របខ័ណ្ឌគោលនយោបាយរបស់កម្ពុជា និងវិមជ្ឈការតាមស្ថានភាពជាក់ស្តែង និងបែបបទរដ្ឋបាល។

***ខ. ធ្វើឱ្យប្រសើរឡើងនូវហិរញ្ញវត្ថុផ្នែកអាកាសធាតុ៖***

ការផ្ទេរហិរញ្ញវត្ថុក្នុងគោលដៅជាក់លាក់ណាមួយសម្រាប់គម្រោងប្រែប្រួលអាកាសធាតុគឺជាយុទ្ធសាស្ត្រមានប្រយោជន៍រយៈពេលខ្លី ដើម្បីលើកកម្ពស់ការយកចិត្តទុកដាក់លើការងារស្តីពីការប្រែប្រួលអាកាសធាតុនៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើការបញ្ជ្រាបបញ្ហានៃការប្រែប្រួលអាកាសធាតុទៅក្នុងការចំណាយទៅលើវិស័យពាក់ព័ន្ធនានា (ដូចជា កម្មវិធីអភិវឌ្ឍន៍ជនបទ ទឹកអនាម័យ និងកសិកម្ម) អាចនឹងនាំឱ្យមានផលប្រយោជន៍រយៈពេលយូរអង្វែង។

***គ. ការរៀបចំផែនការសកម្មភាព និងថវិកាប្រកបដោយប្រសិទ្ធភាព និងសមធម៌សម្រាប់គម្រោងអាកាសធាតុ***

ដំណោះស្រាយសម្រាប់បញ្ហាការប្រែប្រួលអាកាសធាតុនៅកម្រិតមូលដ្ឋានទាមទារអោយមានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធនានា: រដ្ឋបាលមូលដ្ឋាន មន្ទីរពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល។ ដូចគ្នានោះដែរសម្រាប់ស្ថាប័នជាតិ និងគ្រឹះស្ថានអប់រំមានតួនាទីផ្តល់ការណែនាំផ្នែកគោលនយោបាយ។ ការធានានូវការចូលរួមរបស់សហគមន៍ នៅក្នុងដំណើរការរៀបចំផែនការ អាចធ្វើឱ្យការឆ្លើយតបស្រប

គ្នាទៅនឹងតម្រូវការរបស់សហគមន៍ទាំងនោះ នេះគឺជាខ្លឹមសារដ៏សំខាន់នៃវិមជ្ឈការនយោបាយ។ ការរៀបផែនការហិរញ្ញវត្ថុ និងថវិកាប្រកបដោយតម្លាភាព ព្រមទាំងមានលក្ខណលម្អិតមានសារៈសំខាន់ក្នុងការជំរុញឲ្យមានការចូលរួម។

### *ឃ.ការត្រួតពិនិត្យ និងវាយតម្លៃផលប៉ះពាល់នៃហិរញ្ញវត្ថុផ្នែកអាកាសធាតុ៖*

ការបង្កើតក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃដ៏ល្អ ហើយនិងការបង្កើតដំណើរការចែករំលែកព័ត៌មានជាសាធារណៈ អាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដែលធ្វើឱ្យរដ្ឋបាលមូលដ្ឋានមានគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈ និងអាចរួមចំណែកក្នុងការសម្រេចលទ្ធផល។

ក្តីរំពឹងទុកគឺថាសសរស្តម្ភទាំង៤នេះនឹងដើរតួនាទីជាក្របខ័ណ្ឌសំខាន់ ដែលអាចត្រូវបានប្រើប្រាស់ក្នុងការចង្អុលបង្ហាញ និងផ្តល់នូវវិធីសាស្ត្រសមស្របមួយដែលនឹងធានាថា ហិរញ្ញវត្ថុត្រូវបានផ្ទេរ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិត។ ចំណុចនេះរួមទាំងការជំរុញ និងការធានាថា ការពិចារណាផ្នែកយេនឌ័រគឺជាសមាសធាតុសំខាន់នៃដំណើរការផែនការគម្រោងណាមួយ។ ទោះយ៉ាងណា (ដូចដែលបង្ហាញខាងក្រោម) សមត្ថភាពដែលមានស្រាប់ស្តីពីការប្រែប្រួលអាកាសធាតុនៅតែមានកម្រិតហើយអាចសន្និដ្ឋានបានថា ឧបសគ្គ និងឱកាសសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុអាចត្រូវបានគេមើលរំលង ឬព្រងើយកន្តើយ។

## *២.៩ ការប៉ាន់ប្រមាណតម្រូវការសមត្ថភាពស្ថាប័ន*

ការប៉ាន់ប្រមាណតម្រូវការសមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុត្រូវបានធ្វើដោយក្រសួងកិច្ចនារី (មន្ត្រីនៃគណៈកម្មការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាសកាសធាតុចំនួន ៣៨រូប) រួមជាមួយក្រសួងពាក់ព័ន្ធចំនួន៤ (មន្ត្រី១០រូបមកពីក្រសួងនីមួយៗ) រដ្ឋបាលខេត្តចំនួន២ (មន្ត្រី ១៦រូប ក្នុងមួយខេត្ត) និងតំណាងមកពីក្រសួងផែនការ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៦។ ការប៉ាន់ប្រមាណសមត្ថភាពត្រូវបានធ្វើ ទៅលើយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធបែបបទបុគ្គលិកជំនាញ និងការគាំទ្រ (S7)។ លើសពីនេះ ការប៉ាន់ប្រមាណសមត្ថភាពមួយទៀតត្រូវបានធ្វើក្នុងឆ្នាំ២០១៨ ជាមួយក្រសួងពាក់ព័ន្ធចំនួន៦ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។

**លទ្ធផលសំខាន់ៗនៃការប៉ាន់ប្រមាណទាំង ២ លើកមានដូចខាងក្រោម៖**

ក.កង្វះធនធានដែលចាំបាច់សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវផែនការសកម្មភាព និងការវិភាគក្នុងការបញ្ជ្រាបយេនឌ័រ។

ខ.កង្វះការយល់ដឹងពីរបៀបបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគថ្នាក់ឃុំ សង្កាត់ គួរតែត្រូវបានបញ្ចូលទៅក្នុងតួនាទី និងទំនួលខុសត្រូវរបស់មន្ត្រីនៅថ្នាក់ជាតិ និងក្រោមជាតិ

គ.ការផ្សព្វផ្សាយកាន់តែច្រើនពីការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពពាក់ព័ន្ធ ត្រូវបានវាយការណ៍ដោយអង្គការសង្គមស៊ីវិល។

ឃ.តម្រូវការអនុវត្តការស្រាវជ្រាវ និងសិក្សាពីសកម្មភាពដែលមានស្រាប់របស់អង្គការសង្គមស៊ីវិល និងវិមជ្ឈការបន្សាំការប្រែប្រួលអាកាសធាតុ ឬគម្រោងសាកល្បង ដើម្បីកំណត់វិធីសាស្ត្រប្រសើរជាងមុន និងការអនុវត្តល្អៗ សម្រាប់ការបញ្ជ្រាបយេនឌ័រ។

ង.តម្រូវការសម្រាប់ភាពបន្សុីកាន់តែប្រសើរឡើងរវាងវិស័យនានា និងការបន្សាំការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធ និងការវិនិយោគនៃការកាត់បន្ថយគ្រោះមហន្តរាយ ដើម្បីធ្វើឱ្យលទ្ធផលមានភាពប្រសើរ និងប្រកបដោយសមធម៌។

ច.តម្រូវការសម្រាប់ការប្រមូលទិន្នន័យត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីពិនិត្យសូចនាករដែលមានការបែងចែកយេនឌ័រដែលនឹងធានាថាការពិចារណាផ្នែកយេនឌ័រត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងផែនការសកម្មភាពដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ (ដូច្នេះនឹងបង្កើននូវប្រសិទ្ធផល និងសមធម៌នៃផែនការវិនិយោគសាធារណៈ)។

ឆ.តម្រូវការអភិវឌ្ឍន៍សមត្ថភាពតាមស្ថាប័នដើម្បីឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងធានានូវការបញ្ជ្រាបយេនឌ័រ នៅក្នុងការរៀបចំផែនការសកម្មភាពនិង ថវិកា ការអនុវត្តការត្រួត ពិនិត្យ និងការវាយតម្លៃនៃការប្រែប្រួលអាកាសធាតុ។

***រូបភាពទី៣***-*សមត្ថភាពរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងផែនការ និងក្រសួងកិច្ចការនារី នៅលើវិធាន៧S (របាយការណ៍ប៉ាន់ប្រមាណតម្រូវការសមត្ថភាព ក្រសួងកិច្ចការនារី ឆ្នាំ២០១៦)*



**សម្គាល់ ៖ យុទ្ធសាស្ត្រ**សំដៅដល់វិសាលភាពនៃការគាំទ្រយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងសម្របសម្រួលការខិតខំពង្រឹងសមត្ថភាពផ្នែកស្ថាប័ន ដើម្បីកំណត់ និងឆ្លើយតបយ៉ាងច្បាស់ចំពោះការប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ ស្រដៀងគ្នានោះដែរ **រចនាសម្ព័ន្ធ**សំដៅលើការគាំទ្ររចនាសម្ព័ន្ធបញ្ជ្រាបយេនឌ័រ និងសម្របសម្រួលការខិតខំពង្រឹងសមត្ថភាពផ្នែកស្ថាប័ន ដើម្បីកំណត់ និងឆ្លើយតបយ៉ាងច្បាស់ចំពោះការប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ **ប្រព័ន្ធ**សំដៅលើប្រព័ន្ធបញ្ជ្រាបយេនឌ័រដែលអាចអនុវត្តនីតិវិធី និងដំណើរការដើម្បីកំណត់ និងឆ្លើយតបចំពោះការប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ **បែបបទ** សំដៅលើរបៀបនៃការបញ្ជ្រាបយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ខ្លួនដែលមានការយល់ដឹងគ្រប់គ្រាន់ពីការប្រែប្រួលអាកាសធាតុ និងមានវិធីសាស្ត្រសមស្របដើម្បីឱ្យត្រូវនឹងភាពបន្ទាន់។ **បុគ្គលិក**សំដៅលើបុគ្គលិកបញ្ជ្រាបយេនឌ័រដែលមានទំនួលខុសត្រូវសម-ស្របចំពោះការប្រែប្រួលអាកាសធាតុ។ **ជំនាញ** សំដៅលើបុគ្គលិកបញ្ជ្រាបយេនឌ័រដែលមានជំនាញ និងបទពិសោធនៃភាពបន្ទាន់នឹងការប្រែប្រួលអាកាសធាតុគ្រប់គ្រាន់ ហើយ **ការគាំទ្រ**សំដៅលើ ស្ថាប័នដែលអាចទទួលបានការគាំទ្រគ្រប់គ្រាន់ រួមទាំងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ការវិនយោគ ក្នុងការប្រែប្រួលអាកាសធាតុរបស់ពួកគាត់។

ប្រអប់ទី៣- ទិន្នន័យបែងចែកតាមភេទគឺជាបទដ្ឋានអប្បរមាមួយសម្រាប់ការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃគំនិតផ្តួចផ្តើមទាំងអស់។ ប្រសិនបើទិន្នន័យដែលមានការបែងចែកតាមភេទមិនត្រូវបានប្រមូល និងវិភាគឱ្យបានស៊ីចង្វាក់ទេ គឺតម្រូវអោយមានការពន្យល់ឱ្យបានច្បាស់លាស់ពីមូលហេតុ ។

ព័ត៌មានបែងចែកតាមភេទ មានន័យថា ការបែងចែកទិន្នន័យបុរស និងស្ត្រីដោយឡែកពីគ្នានៅពេលប្រមូលព័ត៌មានអំពីសកម្មភាព និងផលប្រយោជន៍។ ទិន្នន័យដែលបែងចែកតាមភេទមានសារសំខាន់ពីព្រោះទិន្នន័យនេះជួយឱ្យធ្វើការប៉ាន់ប្រមាណថា តើគម្រោងវិនិយោគមួយបានទទួលជោគជ័យតាមគោលដៅ ហើយថាតើគម្រោងបានផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី បុរស កុមារី កុមារាតាមការគ្រោងទុកដែរឬទេ។ សូចនាករគួរតែបញ្ជាក់ថា ទិន្នន័យទាំងអស់អំពីក្រុមគោលដៅ និងអ្នកទទួលផល នឹងត្រូវបានបែងចែកតាមភេទ។ ព័ត៌មានក៏អាចត្រូវបានបែកចែកទៅតាមភេទដោយយោងទៅលើចំនុចសំខាន់ៗផ្សេងគ្នា ជាពិសេស អាស្រ័យទៅតាមប្រភេទនៃគម្រោង ក្រុមគោលដៅ និងបរិបទ ដូចជាៈ ក្រុមសេដ្ឋកិច្ចសង្គម អាយុ ជាតិសាសន៍ សាសនា ឬទីតាំង (ជនបទ ឬទីក្រុង)។

ប្រភព: J.Hunt ឆ្នាំ២០១១ ការណែនាំអំពីការត្រួតពិនិត្យ និងវាយតម្លៃអំពីភាពប្រែប្រួលនៃយេនឌ័រ។ អត្ថបទកំណត់សម្គាល់សម្រាប់ការបណ្តុះបណ្តាលដែលមិនបានបោះពុម្ព។

សមត្ថភាពបច្ចុប្បន្ន និងជាគោលដៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងផែនការ ក្រសួងកិច្ចការនារី ខេត្ត និងឃុំ គោលដៅ កំណត់ភាពខ្វះចន្លោះ និងតម្រូវការនានា ដើម្បីពង្រីកសមត្ថភាពស្ថាប័នសម្រាប់ការសម្របសម្រួលការកាត់បន្ថយភាពមិនស្មើភាព និងបង្កើនផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ស្របជាមួយនឹងកម្រិតផ្នែកសង្គម វប្បធម៌ បរិស្ថាន។ល។ គំនិតផ្តួចផ្តើមដោយមានការបែងចែកតាមភេទជួយឱ្យអ្នកដែលមានតួនាទីសម្រេចចិត្តក្នុងការបង្កើតគោលនយោបាយ កម្មវិធី និងគម្រោង។

នៅតំបន់អាស៊ាន សេដ្ឋកិច្ចអាចជំរុញផលទុនសរុបក្នុងស្រុកបានចំនួន ៣៧០ពាន់លាន ក្នុងមួយឆ្នាំត្រឹមឆ្នាំ២០២៥ ប្រសិនជាវិសមភាពយេនឌ័រត្រូវបានលុបបំបាត់ ដោយមិនរាប់បញ្ចូលប្រទេសប្រ៊ុយណេដារូសាឡឹម និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ។ ស្ត្រីនៅអាស៊ីខាងត្បូងបានរួមចំណែក៣៦,៤%នៃផលទុនសរុបក្នុងស្រុកនៃថ្នាក់តំបន់រួមគ្នា ។ ប៉ុន្តែភាគរយនេះមិនបានគិតពីសុខុមាលភាព និងសកម្មភាពសេដ្ឋកិច្ចសរុបរបស់ស្ត្រីក្នុងតំបន់នោះទេ ។ សមភាពយេនឌ័រក្នុងប្រទេសហ្វីលីពីន និងវៀតណាមហាក់ទាបជាងប្រទេសដទៃទៀតក្នុងតំបន់ (ធនាគារពិភពលោកឆ្នាំ២០១៨)។

## ២.១០.ចំណុចគន្លឹះនៃផែនការមេ

ផែនការមេផ្តោតទៅលើការកាត់បន្ថយគម្លាតនៃសមត្ថភាពរវាងបុរសនិងស្ត្រី ដូចមានក្នុងតារាងទី៤ ធ្វើឱ្យមានភាពប្រសើរឡើងទាំងផ្នែកសង្គម បរិស្ថាន និងសេដ្ឋកិច្ច។ បន្ថែមពីលើនេះទៅទៀត ផែនការមេផ្តោតសំខាន់លើការកំណត់គោលដៅ កម្មវត្ថុ និងសូចនាករ ។ ផែនការមេនេះបានការគាំទ្រដល់ក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីធ្វើការបញ្ជ្រាបយេនឌ័រគោលនយោបាយ កម្មវិធី និងគម្រោងវិនិយោគការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយ និងបង្ការគ្រោះមហន្តរាយក្នុងយន្តការផ្ទៃក្នុងរបស់ពួកគាត់។ ផែនការមេនេះគឺសំដៅធ្វើឱ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច និងកាត់បន្ថយការបាត់បង់នូវសេដ្ឋកិច្ចដ៏ធំធេង (ឯកសារយោងរូបភាពទី១ និងរូបភាពទី២)។

គោលបំណង និងគោលដៅគឺបន្សុីគ្នាជាមួយគោលនយោបាយ និងការកំណត់អាទិភាពរបស់រាជរដ្ឋាភិបាល។ គម្រោងនានានៃផែនការមេនេះ ផ្តោតជាចម្បងលើវិស័យៈ កសិកម្ម ធនធានទឹក សាធារណការ និងដឹកជញ្ជូន និងវិស័យសុខាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ វិស័យអាទិភាពដទៃទៀតដែលពាក់ព័ន្ធមានដូចជាៈ ថាមពល ការអប់រំ ការអភិវឌ្ឍទីប្រជុំជន ការអភិវឌ្ឍជនបទ និងការគ្រប់គ្រងគ្រោះមហន្តរាយនឹងមានបញ្ចូលទៅក្នុងផែនការមេសម្រាប់បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការសម្រេចលទ្ធផលរយៈពេលវែងប្រកបដោយចីរភាព។ បញ្ហាការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងភាពងាយរងគ្រោះដែលបណ្តាលមកពីអាកាសធាតុ ត្រូវតែដោះស្រាយទាំងនៅតំបន់ជនបទ និងទីប្រជុំជនក៏ដូចជាតំបន់ទីក្រុងដែលបាននឹងកំពុងអភិវឌ្ឍ។

*តារាងទី៤- សមត្ថភាពបែងចែកតាមភេទ នៅតាមវិស័យពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល (ប្រភព: សិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ រៀបចំដោយក្រសួងផែនការ ថ្ងៃទី២-៣ ខែសីហា ឆ្នាំ២០១៨ តម្រូវការការប៉ាន់ប្រមាណសមត្ថភាពរបស់អ្នករៀបចំគោលនយោបាយតាមវិស័យពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល)*

តារាងទី៤-សមត្ថភាពការបញ្ជ្រាបយេនឌ័រទៅក្នុងការវិនិយោគ CCA នៅតាមវិស័យពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល (ខែសីហា ឆ្នាំ២០១៨)

| | កសិកម្ម | | សុខភាព | | ហេដ្ឋារចនាសម្ព័ន្ធ | | ទឹក | | ថ្នាក់ក្រោមជាតិ | | ក្រុម CSO | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រី ក១ | បុរស ក២ | ស្ត្រី ខ១ | បុរស ខ២ | ស្ត្រី គ១ | បុរស គ២ | ស្ត្រី ឃ១ | បុរស ឃ២ | ស្ត្រី ង១ | បុរស ង២ | ស្ត្រី ច១ | បុរស ច២ |
| ការរៀបចំគម្រោង | ២៧% | ៣២% | ២៤% | ២៨% | ៣៥% | ៤១% | ២៩% | ៣៦% | ១៦% | ២១% | ៣៦% | ៤២% |
| ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុសម្រាប់ការធ្វើសេចក្តីសម្រេច | ២៩% | ៣៥% | ២៧% | ៣៥% | ២៦% | ៣៦% | ៣១% | ៤២% | ២០% | ២៩% | ៣៨% | ៤៥% |
| លក្ខណខុសប្លែកគ្នា និងការបង្កើតគម្រោង | ២៣% | ៣៤% | ២៣% | ៣៤% | ២៨% | ៣៨% | ៣០% | ៤២% | ១៨% | ២៤% | ៤៥% | ៥៥% |
| ការបញ្ជ្រាបយេនឌ័រក្នុងCCAI | ២៣% | ២៨% | ២៤% | ២៨% | ៣៤% | ៣៩% | ២៤% | ៣៣% | ១៩% | ២៤% | ៤៥% | ៥៧% |
| ការបញ្ជ្រាបយេនឌ័រ ក្នុងយុទ្ធសាស្ត្រ | ២៤% | ២៨% | ២៥% | ២៨% | ២២% | ៣០% | ២៣% | ៣៣% | ១៦% | ២២% | ៣៨% | ៥៧% |
| ការបញ្ជ្រាបយេនឌ័ក្នុងប្រព័ន្ធ | ២៥% | ២៨% | ២៤% | ២៨% | ២៣% | ៣៣% | ២២% | ៣២% | ១៦% | ២១% | ៣៦% | ៥៥% |
| បែបបទក្នុងការបញ្ជ្រាប យេនឌ័រ | ២២% | ២៤% | ២៣% | ២៩% | ២២% | ២៨% | ២៥% | ២៩% | ២៨% | ២២% | ៣៥% | ៥៣% |
| ការបញ្ជ្រាបយេនឌ័រក្នុងរចនាសម្ព័ន្ធ | ២៤% | ៣៥% | ២៧% | ៣៥% | ២៤% | ២៤% | ២៥% | ២៧% | ២៥% | ៣២% | ៣៦% | ៤៦% |
| បញ្ជ្រាបយេនឌ័រក្នុងបុគ្គលិក | ២៥% | ៣៣% | ២៧% | ៣៣% | ២៩% | ៣៤% | ២៥% | ៣៤% | ២២% | ២៩% | ៣៨% | ៣៣% |
| ការបញ្ជ្រាប យេនឌ័រក្នុងការគាំទ្រ | ២៤% | ៣៥% | ២៦% | ៣៥% | ២៥% | ៣៤% | ២៤% | ៣៥% | ២៤% | ៣៥% | ៣៥% | ៤៩% |
| ការបញ្ជ្រាបយេនឌ័រក្នុងជំនាញ | ២៦% | ៣៦% | ២៧% | ៣៦% | ២៣% | ៣៧% | ២៥% | ៣៥% | ១៦% | ២២% | ៣៥% | ៤៣% |
| កាការបញ្ជ្រាបយេនឌ័រក្នុងការតាមដាន និងវាយតម្លៃ | ២៧% | ៣៧% | ២៦% | ៣៧% | ២៥% | ៣៥% | ២៧% | ៣៨% | ២៦% | ៣៣% | ៣៧% | ៤៨% |

ផែនការមេនេះ មានទិសដៅគាំទ្រផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុដើម្បីបន្ថែមគុណតម្លៃដល់គម្រោងរបស់ក្រសួងពាក់ព័ន្ធ មន្ទីរនានា អង្គការសង្គមស៊ីវិល និងវិស័យឯកជន។ គម្រោងដែលបានស្នើចំនួន៧នឹងត្រូវបានអនុវត្តដោយក្រសួងកិច្ចការនារីនិងបន្ថែមគុណតម្លៃចំពោះការជំរុញស្ត្រី និងសហគ្រាសរបស់ស្ត្រីឱ្យផ្លាស់ប្តូរការអនុវត្ត ដែលមិនប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ ។ គម្រោងទាំងនេះនឹងគាំទ្រដល់ផែនការសកម្មភាពបន្សាំនិងការប្រែប្រួលអាកាសធាតុតាមក្រសួងពាក់ព័ន្ធ តាមរយៈការវិនិយោគក្នុងការបង្ការនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ការ វិនិយោគបែបនេះ នឹងជួយដោះស្រាយបញ្ហាអន្តរវិស័យសំខាន់ៗ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទីប្រជុំជន សុខភាព អប់រំ ។ល។ អង្គការសង្គមស៊ីវិល និងវិស័យឯកជនត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការកាត់បន្ថយហានិភ័យអាកាសធាតុ និងបង្កើនអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច។

ផែនការមេនេះ នឹងជម្រុញការវិនិយោគក្នុងការធ្វើឱ្យប្រសើរនូវឧបករណ៍ត្រួតពិនិត្យអាកាសធាតុ ដែលងាយប្រើ និងមិនសូវមានលក្ខណបច្ចេកវិទ្យាស្មុគស្មាញ ដូចជា ឧបករណ៍ព្យាករណ៍ធាតុអាកាស និងសូចនាករដែលអាចប្រើប្រាស់បានទាំងបុរស និងស្ត្រី ដែលជាអ្នកគ្រប់គ្រងគ្រួសារ។ ការងារនេះក៏នឹងវិនិយោគនៅក្នុងការបង្កើនសមត្ថភាពគ្រប់គ្រងរបស់អាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិដើម្បីគ្រប់គ្រងប្រតិបត្តិ និងរក្សានូវប្រព័ន្ធព័ត៌មានសំខាន់ៗក្នុងកំឡុងពេលអនុវត្តផែនការមេ និងលើសពីនេះ (ក្រោយឆ្នាំ២០៣០) ហើយស្របពេលគ្នាជាមួយការបញ្ជ្រាបការគិតគូរពីបញ្ហាយេនឌ័រទៅក្នុងការគ្រប់គ្រងប្រព័ន្ធនេះ។

អង្គការសង្គមស៊ីវិល ក្រុមស្ត្រីតាមសហគមន៍ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីអាចត្រូវបានប្រើជាកំលាំងស្នូលដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ស្ត្រី និងសហគមន៍របស់ពួកគាត់ដើម្បីឱ្យត្រៀមឆ្លើយតប និងកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ មណ្ឌលអភិវឌ្ឍន៍ស្ត្រីគួរជំរុញសេដ្ឋកិច្ចវិលជុំដែលមានមូលដ្ឋានលើបំណិនជីវិត ដើម្បីបង្កើនភាពធន់នៅកម្រិតសហគមន៍។ ចំណុចនេះអាចបន្សុីគ្នាជាមួយផែនការ និងការអនុវត្តការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ ដែលបានបញ្ចូលតំណាងភេទទាំងពីរក្នុងការរៀបចំផែនការ និងការអនុវត្តសកម្មភាព។ វិធីសាស្ត្រស្រដៀងនេះ និងការរៀបចំផែនការតាមមូលដ្ឋានអាចត្រូវបានប្រើដើម្បីជំរុញសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុនានា។

លើសពីនេះ ឱកាសសំខាន់ៗមានសម្រាប់ប្រជាពលរដ្ឋកម្ពុជាដើម្បីទាញយកប្រយោជន៍ពីបច្ចេកវិទ្យាច្នៃប្រឌិតថ្មីៗក្នុងការសន្សំសំចៃថាមពល និងថាមពលកកើតឡើងវិញនៅតាមផ្ទះនៅតំបន់ទីក្រុង និងជនបទ។ បច្ចេកវិទ្យានេះអាចនឹងជួយដល់ក្រុមគ្រួសារតាមជនបទ ដោយសារតែប្រព័ន្ធចែកចាយថាមពលបែបបុរាណមានតម្លៃថ្លៃ ឬមិនមាន។ ដោយមាននិយ័តករសមស្រប ការគាំទ្រផ្នែកទីផ្សារ និងការអភិវឌ្ឍសមត្ថភាពស្ត្រីជាសមាជិកសហគមន៍អាចទាញផលប្រយោជន៍ពីការផ្គត់ផ្គង់នេះ ដើម្បីធ្វើជាទីផ្សារ និងលក់ផលិតផលថាមពលកកើតឡើងវិញ ដូចជា ផ្ទាំងសូឡាខ្នាតតូច និងផ្តល់សេវាថែទាំ និងសេវាតាមដានជួសជុល។

សកម្មភាពសេដ្ឋកិច្ចដែលបញ្ចេញឧស្ម័នកាបូនិកទាប និងគិតគូរពីអាកាសធាតុ មានសារសំខាន់សម្រាប់ស្ត្រី ហើយអាចនឹងនាំឱ្យមានការផ្លាស់ប្តូរនូវរបៀបចម្អិនអាហារតាមផ្ទះ ឬការធ្វើក្អមឆ្នាំងពីដីឥដ្ឋដែលត្រូវបានអនុវត្តកាន់តែគិតគូរពីអាកាសធាតុ។ អាជីវកម្មនានាដែលមានស្ត្រីធ្វើការច្រើនតម្រូវអោយលើកកម្ពស់លក្ខខណ្ឌការងារ ការបន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងដំណើរការផលិតកម្ម និងកែច្នៃសម្ភារៈព្រមទាំងបង្ការការបំពុលដី និងទឹកពីទីតាំងអាជីវកម្មរបស់ខ្លួន។

ផែនការមេនឹងលើកកម្ពស់នូវការកំណត់ទម្រង់សមស្របនៃបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងដែលអាចជួយស្ត្រី ដែលធ្វើការក្នុងផ្នែកកសិកម្ម និងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំទាំងនៅទីក្រុង និងជនបទ។ ឧទាហរណ៍ជាក់លាក់មួយនៃការវិវត្តនៃបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង គឺកំណើននៃការប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ និងការពង្រីកវិសាលភាពបណ្តាញអ៊ីនធឺណេតពាសពេញប្រទេស។ បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យាបែបនេះអាចត្រូវបានប្រើដើម្បីចែកចាយទីផ្សារ ឬព័ត៌មានពីធាតុអាកាស ប្រធានបទអភិវឌ្ឍន៍អាជីវកម្ម និងសុខភាព ការជូនដំណឹង និងសេចក្តីណែនាំពាក់ព័ន្ធនឹងគ្រោះមហន្តរាយ ដោយរួមជាមួយស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធដែលគ្រប់គ្រងភាព

ត្រឹមត្រូវ និងការចែកចាយព័ត៌មានបែបនេះ។ បច្ចេកវិទ្យាទំនាក់ទំនាក់ព័ត៌មានក៏អាចត្រូវបានប្រើប្រាស់ដើម្បីជំរុញឱកាសជំនួញក្រៅពីកសិកម្មសម្រាប់ស្ត្រី តាមរយៈការធ្វើអោយប្រសើរឡើងនូវការទំនាក់ទំនង ដូចជា សមាគមជំនួញ និងបណ្តាញរបស់ស្ត្រី។ ការទំនាក់ទំនងដែលកាន់តែប្រសើរទាំងនេះអាចជួយភ្ជាប់តម្រូវការទីផ្សារ និងការផ្គត់ផ្គង់នូវទំនិញ និងសេវាកម្មពីក្រុមស្ត្រី។

ចុងក្រោយ ផែនការមេនឹងត្រួតពិនិត្យ និងរាយការណ៍ពីការវិវឌ្ឍដែលឆ្ពោះទៅការសម្រេចគោលបំណងទូទៅដែលឆ្លើយតបនឹងយេនឌ័រ ក៏ដូចជាវិស័យនីមួយៗតាមរយៈសូចនាករដែលបានកំណត់នៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិ។ ចំណុចនេះនឹងធានាថាយុទ្ធសាស្ត្រ និងផែនការសកម្មភាពថ្នាក់ជាតិត្រូវបានធ្វើបច្ចុប្បន្នភាពដោយទៀងទាត់ ជាមួយនឹងមេរៀនជាបទពិសោធ និងការអនុវត្តល្អៗដែលបានសង្កេតកន្លងមក ហើយត្រូវកែសម្រួលនៅពេលដែលចាំបាច់។ ដើម្បីគាំទ្រចំណុចនេះ ទិន្នន័យដែលមានបែងចែកភេទឆ្លើយតបនឹងយេនឌ័រនឹងត្រូវបានបង្កើតឡើងនៅវិទ្យាស្ថានជាតិស្ថិតិ ហើយវេទិកាពិភាក្សាពីការបញ្ជ្រាបយេនឌ័រ ក៏នឹងត្រូវបានបង្កើតដោយមានតំណាងមកពីរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន។

ជារួម ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្ពោះទៅការធ្វើឱ្យប្រសើរឡើងនូវបរិយាប័ន្ន ការគិតគូរអំពីយេនឌ័រ នៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានបន្ថែមគុណតម្លៃដ៏សន្ធឹកសន្ធាប់ចំពោះសកម្មភាពកាត់បន្ថយភាពក្រីក្រ។ ការផ្តោតទៅលើការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីដែលឆ្លើយតបនឹងយេនឌ័រនឹងរួមចំណែកឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

# ៣.ដំណើរការរៀបចំផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

## *៣.១.ការពិនិត្យមើលឯកសារពាក់ព័ន្ធផ្សេងៗ*

ក្រុមទីប្រឹក្សាបច្ចេកទេស និងតំណាងក្រុមការងារក្រសួងកិច្ចការនារីបានរៀបចំពិនិត្យមើលលើឯកសារពាក់ព័ន្ធនានា រួមមាន គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធរបស់ក្រសួងកិច្ចការនារី និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យពាក់ព័ន្ធផ្សេងៗ ទាំងក្នុងបរិបទប្រទេស ក្នុងតំបន់ និងក្នុងសាកលលោក។ ដើម្បីរៀបចំបង្កើតផែនការមេនេះឱ្យមានការគិតគូរ និងឆ្លើយតបនឹងយេនឌ័រទៅក្នុងការវិនិយោគក្នុងការប្រែប្រួលអាកាសធាតុ ក្រុមការងារបានសិក្សាលើផែនការសកម្មភាព និងកម្មវិធីផ្សេងៗជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការខ្វះខាតព័ត៌មាន និងទិន្នន័យតាមវិស័យនានា ដែលផែនការមេនេះទាមទារឱ្យមានការរៀបចំដាក់បញ្ចូលព័ត៌មាន និងទិន្នន័យឱ្យបានគ្រប់ជ្រុងជ្រោយ ហើយទាមទារនូវពេលវេលាមួយសមរម្យ។

## *៣.២.ការពិគ្រោះយោបល់*

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ត្រូវបានរៀបចំតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ចំនួន៤លើកផ្សេងគ្នា ដែលបានដឹកនាំ និងសម្របសម្រួលដោយក្រុមការងារក្រសួងកិច្ចការនារី និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការប្រជុំ និងពិគ្រោះយោបល់ក្នុងការរៀបចំផែនការមេមានរយៈពេល ១៥ ខែ។

## ៣.៣.ការទទួលស្គាល់ពីការចូលរួមចំណែកនៃគំនិតផ្តួចផ្តើមផ្សេងៗ

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ត្រូវបានរៀបចំដោយផ្អែកលើផែនការមេMPGCC (២០១៣-២០២២) ក្រោមការឧបត្ថម្ភគាំទ្រពីគម្រោង PPCR ដំណាក់កាលទី១។ ផែនការមេ MPGCC បានបង្ហាញពីការរីកចំរើនជាច្រើនពាក់ព័ន្ធនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) អាណត្តិរបស់ក្រុមប្រឹក្សាជាតិសម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព (NCSD) ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ (២០១៤-២០១៨) ផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុតាមវិស័យ (CCAPs) ព្រមទាំងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹង យេនឌ័រផ្សេងៗរបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ផែនការមេនេះ ក៏ដកស្រង់ពីវឌ្ឍនភាពដែលក្រសួងកិច្ចការនារីដឹកនាំ និងអនុវត្តគម្រោងនានាដែលទទួលបានការគាំទ្រពីមូលនិធិកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងបទពិសោធពីប្រទេសជិតខាងទាំងនៅថ្នាក់តំបន់ និងសកលលោក។

## ៣.៤. ការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍន៍សមត្ថភាព

ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគការប្រែប្រួលអាកាសធាតុមានវិធានផ្សេងៗគ្នា។ យោងទៅតាមទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រ គម្លាត និងតម្រូវការ ក៏ដូចជាឧបសគ្គ និងអនុសាសន៍សម្រាប់ធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយ និងយុទ្ធសាស្ត្រដែលឆ្លើយតបនឹងយេនឌ័រត្រូវបានកំណត់។

នៅក្នុងដំណាក់កាលចាប់ផ្តើម ក្រុមការងារបច្ចេកទេស GCCC (ក.ក.ន) បានរៀបចំសិក្ខាសាលារៀបចំផែនការមេ និងធ្វើការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍន៍សមត្ថភាពគ្រប់ជ្រុងជ្រោយក្នុងខែធ្នូ ឆ្នាំ២០១៦ នៅតាមវិស័យផ្សេងៗដូចជា (កសិកម្ម ទឹកស្អាត សុខភាព សាធារណៈការ និង អភិវឌ្ឍជនបទ ) ជាមួយអង្គការសង្គមស៊ីវិល អ្នកពាក់ព័ន្ធនានា សរុបចំនួន ១៣២ នាក់ (ស្ត្រី៧៧នាក់) មកពី GCCC ជនបង្គោលនៃក្រសួងពាក់ព័ន្ធ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គ.ជ.អ.ប និង ២៣នាក់មកពីមន្ទីរកិច្ចការនារីខេត្ត ដៃគូអភិវឌ្ឍន៍នានា (ADB UNDP និងGIZ) ។ លទ្ធផលនៃការវិភាគត្រូវបានបង្ហាញក្នុងតារាងទី ៥ ដូចខាងក្រោម:

*តារាងទី៥- ចំណុចចាប់ផ្តើមនៃការបញ្ជ្រាបយេនឌ័រ ទិន្នន័យបឋម និងគោលដៅតាមកម្រិតផ្សេងៗគ្នាបន្ទាប់ពីអនុវត្តប្រកបដោយជោគជ័យនូវគោលការណ៍ណែនាំ (យោងតាមផែនការសកម្មភាព CCAPs)*

| ចំណុចចាប់ផ្តើមក្នុងការបញ្ជ្រាបយេនឌ័រ | វិធាន | ហេតុផល | ទិន្នន័យបឋម និងគោលដៅ[14] (ជាមធ្យម) | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៦ | ២០១៨/១៩ | ២០២៣ | ២០២៨ | ២០៣០ |
| កម្រិតគោលនយោបាយ | | | | | | | |

[14] The targets are set based on the project, NSDP and SDG milestones i.e. 2016, represents baseline, 18-2019 study represents the interim progress during the project, 2023 indicates the progress at the end of upcoming NSDP period, 2028 and 2033 similarly follows the NSDP while 2030 follows the SDGs targets.

| ចំណុចចាប់ផ្ដើមក្នុងការបញ្ជ្រាបយេនឌ័រ | វិធាន | ហេតុផល | ទិន្នន័យបឋម និងគោលដៅ[14] (ជាមធ្យម) | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៦ | ២០១៨/១៩ | ២០២៣ | ២០២៨ | ២០៣០ |
| កម្រិតគោលនយោបាយតាមវិស័យ | វិភាគគោលនយោបាយ | វិភាគគោលនយោបាយ យុទ្ធសាស្ត្រ ការកំណត់តម្រូវការ និងចំណុចខ្វះខាត ព្រមទាំងឧបសគ្គ និងផ្ដល់អនុសាសន៍សម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ | ៥៥% | ៧០% | ៨០% | ៨៥% | ៩០% |
| ការកសាងសមត្ថភាពស្ថាប័ន | វិភាគ ៧S | យុទ្ធសាស្ត្រ ប្រព័ន្ធ បែបបទ រចនាសម្ព័ន្ធ មន្ត្រី ការគាំទ្រ និងជំនាញ ក្នុងការសម្រេចចិត្តក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ៤៥% | ៦៥% | ៧៥% | ៨៥% | ៩០% |
| កម្រិតកម្មវិធី | | | | | | | |
| កម្រិតកម្មវិធី និងគម្រោង | ការវាយតម្លៃតម្រូវការ និងទិន្នន័យបឋម | សមាជិកក្រុមការងារដែលមានសមភាពយេនឌ័រក្នុងការរៀបចំកម្មវិធី និងគម្រោង | ៤០% | ៦០% | ៧៣% | ៨០% | ៩០% |
| | | ផែនការអនុវត្តដែលគិតគូរពីយេនឌ័រ (ការចូលរួម ការពង្រឹងសមត្ថភាព ការអនុវត្តការតាមដាន និងវាយតម្លៃព្រមទាំងរាយការណ៍ និងការវាយតម្លៃលទ្ធផល កម្មវិធី និងគម្រោង) | ៤៥% | ៦០% | ៧៣% | ៨៥% | ៩០% |
| ការកសាងសមត្ថភាពស្ថាប័ន | វិភាគ ៧S | យុទ្ធសាស្ត្រ ប្រព័ន្ធ បែបបទ រចនាសម្ព័ន្ធ មន្ត្រី ការគាំទ្រ និងជំនាញ ក្នុងការសម្រេចចិត្តក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ៤៥% | ៦៥% | ៧៥% | ៨៥% | ៩០% |
| កម្រិតអ្នកទទួលផល | | | | | | | |
| ការអនុវត្ត (វឌ្ឍនភាពនៃការអនុវត្ត និងអ្នកទទួលផល) | ការវិភាគវឌ្ឍនភាព (កាតពិន្ទុ) | សមាជិកក្រុមការងារដែលមានសមភាពយេនឌ័រក្នុងការអនុវត្តកម្មវិធី និងគម្រោង | ៥០% | ៦៥% | ៧៥% | ៨៥% | ៩០% |

| ចំណុចចាប់ផ្ដើមក្នុងការបញ្ជ្រាបយេនឌ័រ | វិធាន | ហេតុផល | ទិន្នន័យបឋម និងគោលដៅ[14] (ជាមធ្យម) | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៦ | ២០១៨/១៩ | ២០២៣ | ២០២៨ | ២០៣០ |
| | | បញ្ជីសម្រាប់ត្រួតពិនិត្យការគិតគូរពីយេនឌ័រ | ៥៥% | ៦៥% | ៧៥% | ៨៥% | ៩៥% |
| | | វិភាគ និងផ្ដល់អនុសាសន៍សម្រាប់កែលំអ | ៥៥% | ៦៥% | ៧៥% | ៨៥% | ៩៥% |
| ការតាមដាន និងវាយតម្លៃលទ្ធផលគម្រោង និងកម្មវិធី | ការវាយតម្លៃលទ្ធផល (កាតពិន្ទុ) | សមាជិកក្រុមការងារដែលមានសមត្ថភាពយេនឌ័រក្នុងការអនុវត្តកម្មវិធី និងគម្រោង | ៤៥% | ៦៥% | ៧៥% | ៨៥% | ៩០% |
| | | បញ្ជីសម្រាប់ត្រួតពិនិត្យការគិតគូរពីយេនឌ័រ | ៥៥% | ៧០% | ៨៥% | ៩០% | ៩៥% |
| | | វិភាគ និងផ្ដល់អនុសាសន៍សម្រាប់កែលំអ | ៥៥% | ៧០% | ៨០% | ៨៥% | ៩០% |
| ការកសាងសមត្ថភាព | វិភាគ ៧S | យុទ្ធសាស្ត្រ ប្រព័ន្ធ បែបបទរចនាសម្ព័ន្ធ មន្ត្រី ការគាំទ្រ និងជំនាញ ក្នុងការសម្រេចចិត្តក្នុងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ | ៤៥% | ៦៥% | ៧៥% | ៨៥% | ៩០% |

កំណត់សម្គាល់:

- ២០១៦ ចងក្រងទិន្នន័យពីរបាយការណ៍វាយតម្លៃតម្រូវការកសាងសមត្ថភាព
- ២០១៨ ឬ ២០១៩ ធ្វើការប្រៀបធៀបទិន្នន័យនៅចុងបញ្ចប់នៃជំនួយបច្ចេកទេស
- ២០២៣ និង ២០២៨ នឹងធ្វើការចងក្រងទិន្នន័យវឌ្ឍនភាពតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ២០៣០ ធ្វើការឆ្លុះបញ្ចាំងទិន្នន័យផ្អែកលើវឌ្ឍនភាពនៃផែនការមេ គោលនយោបាយ និងផែនការតាមវិស័យ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ៣.៥.ធាតុចូលពីក្រសួងពាក់ព័ន្ធ ធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកពាក់ព័ន្ធនានា

ធនាគារអភិវឌ្ឍន៍អាស៊ីដែលជាដៃគូសំខាន់នៅក្នុងកម្មវិធីនេះ រួមជាមួយដៃគូពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលមួយចំនួនទៀតរួមមាន មូលនិធិណ័រឌីក (NDF) មូលនិធិវិនិយោគអាកាសធាតុ (CIF) និងវិទ្យាស្ថានសម្រាប់យុទ្ធសាស្ត្របរិស្ថានសកល (IGES) បានផ្ដល់ធាតុចូល និងសម្ភារៈបច្ចេកទេសដើម្បីឱ្យផែនការមេនេះមានលក្ខណៈទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ ។

# ៤. ទិសដៅជាយុទ្ធសាស្ត្រ

## ៤.១. ចក្ខុវិស័យ

ដើម្បីចូលរួមចំណែកកសាងកិច្ចអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព តាមរយៈសមធម៌សង្គម ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការរៀបចំស្ថាប័នក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងការបន្សាំនឹងការកាត់បន្ថយគ្រោះមហន្តរាយ និងការវិនិយោគនានា គឺជាភារកិច្ចចាំបាច់[15]។

## ៤.២. បេសកកម្ម

ការរៀបចំស្ថាប័នស្តីពីការរបញ្ជ្រាបយេនឌ័រក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះមហន្តរាយ ជាផ្នែកមួយនៃគោលនយោបាយវិនិយោគនៃការប្រែប្រួលអាកាសធាតុទូសាស្ត្រ កម្មវិធី និងគម្រោងវិនិយោគ ដើម្បីពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។]

## ៤.៣.គោលបំណងជាយុទ្ធសាស្ត្រ

ការរៀបចំស្ថាប័នស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគនឹងការប្រែប្រួលអាកាសធាតុ គឺដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្នុងន័យកាត់បន្ថយគម្លាតយេនឌ័រដែលជាតម្លៃបន្ថែមនៅក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

## ៤.៤. គោលបំណងជាក់លាក់

គោលដៅជាក់លាក់សម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះមហន្តរាយ ត្រូវបានរៀបចំដូចខាងក្រោម ៖

១-ពង្រឹងគោលនយោបាយ យុទ្ធសាស្ត្រឆ្លើយតបយេនឌ័រ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល និងវិស័យឯកជន។

២-ពង្រឹងសមត្ថភាពស្ថាប័នឱ្យឆ្លើយតបទៅនឹងយេនឌ័រ តាមយៈការរៀបចំយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធ បែបបទ ជំនាញ ការគាំទ្រ និងមន្ត្រី (ជំនាញជាយុទ្ធសាស្ត្រទាំ៧) ដើម្បីបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគនឹងការប្រែប្រួលអាកាសធាតុ និងតម្លៃបន្ថែមក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ។

៣-ដើម្បីបង្ហាញពីផលប៉ះពាល់នៃភាពខុសគ្នានៃទំនាក់ទំនងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងសារប្រយោជន៍នៃការវិនិយោគលើគំនិតផ្តួចផ្តើមស្តីពីការឆ្លើយតបនឹងយេនឌ័រ (គម្រោងសាកល្បងនានា)។

៤- លើកកម្ពស់ការរៀបចំទុកជាមុន ក្នុងពេលកើតមានគ្រោះមហន្តរាយនានាដូចជា ការថែទាំសុខភាពបឋម ការផ្តល់សម្ភារៈសង្គ្រោះបន្ទាន់ក្នុងស្ថានការណ៍ដែលបណ្តាលមកពីកាប្រែប្រួល

[15] Institutionalization សំដៅលើ (ប៉ុន្តែមិនត្រូវបានកំណត់) ការពង្រឹងសមត្ថភាព, ការអភិវឌ្ឍនូវទិន្នន័យបែងចែកតាមភេទសម្រាប់កម្មវិធីទាំងអស់នៃការវិនិយោគ ការប្រែប្រួលអាកាសធាតុ, ការវិភាគការបែងចែកយេនឌ័រនៃដំណើរការរយៈពេលខ្លី, ការធ្វើបច្ចុប្បន្នភាពជាទៀងទាត់សម្រាប់ផែនការសកម្មភាពជាតិ, ការពិនិត្យឡើងវិញនៅសកម្មភាពពាក់កណ្តាលត្រីមាស ២០២៣, ការពង្រឹងវិស័យនៃ CCAPs, ការវិនិយោគក្នុងអង្គការសង្គមស៊ីវិល និងការផ្សារភ្ជាប់វិស័យឯកជន, ការអភិវឌ្ឍនិងការអនុវត្តការបន្សាំនឹងការប្រែប្រួលអាកាសធាតុ, គម្រោងវិនិយោគការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការផ្សព្វផ្សាយពីបទពិសោធន៍ ការអនុវត្តល្អៗពីគម្រោងស្នើសុំទាំងប្រាំពីរ។

អាកាសធាតុ និងកសាងសមត្ថភាពដើម្បីលើកកម្ពស់ភាពធន់ចំពោះប្រជាពលរដ្ឋដែលមានហានិភ័យខ្ពស់ ។

៥-លើកកម្ពស់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដែលមានហានិភ័យខ្ពស់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ តាមរយៈក្របខ័ណ្ឌផ្តល់នវានុវត្តហិរញ្ញវត្ថុ ដូចជាការធានារ៉ាប់រងខ្នាតតូច មូលនិធិសហគមន៍ ការផ្តល់ពូជ និងការធានារ៉ាប់រងសុខភាពជាដើម។

៦-សម្របសម្រួលការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការសកម្មភាពស្តីពី ការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដែលជាតម្លៃបន្ថែមក្នុងការសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

៧-ប្រើប្រាស់ក្របខ័ណ្ឌ ស្តីពីលទ្ធផលយេនឌ័រ និងបរិយាប័ន្ន ដើម្បីតាមដានផលប៉ះពាល់យេនឌ័រ (ស្របតាមវិទ្យាស្ថានជាតិស្ថិតិ និងក្របខ័ណ្ឌតាមដាន និងវាយតម្លៃពីយេនឌ័ររបស់ក្រសួងផែនការ) ដែលអនុវត្តដោយគម្រោងវិនិយោគស្តីពីការប្រែប្រួលអាកាសធាតុ និងចែករំលែកជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹង និងស្វែងរកការគាំទ្រមតិ។

៨-រៀបចំបង្កើតកិច្ចសន្ទនាស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងវេទិកាពិភាក្សាស្តីពី ការវិនិយោគលើការប្រែប្រួលអាកាសធាតុ ដើម្បីបង្កើនចំណេះដឹង និងអភិវឌ្ឍន៍សមត្ថភាព ដល់អ្នកពាក់ព័ន្ធតាមក្រសួង ស្ថាប័ន សង្គមស៊ីវិល និងវិស័យឯកជននៅក្នុងប្រទេសកម្ពុជា ទាំងកម្រិតតំបន់ និងសកលលោក។

*ផែនការមេនឹងត្រូវអនុវត្តតាមជំហាន៣ ក្នុងកំឡុងពេលខុសៗគ្នាដូចខាងក្រោម ៖*

| កំឡុងពេល | គោលដៅ |
|---|---|
| រយៈពេលខ្លី (២០១៨-២០១៩) | គោលដៅរយៈពេលខ្លី ផ្តោតលើសកម្មភាពជាអាទិភាពនានាដែលបានប្តេជ្ញាអនុវត្តក្នុង កំឡុងពេលមានគម្រោងជំនួយបច្ចេកទេស តាមរយៈក្រសួងកិច្ចការនារី |
| រយៈពេលមធ្យម (២០១៩-២០២៣) | គោលដៅរយៈពេលមធ្យម ផ្តោតលើពេលវេលាកម្មវិធីអភិវឌ្ឍន៍របស់ព្រះរាជាណាចក្រកម្ពុជា ឧ.ដែលមានភាពស៊ីចង្វាក់នឹងវដ្តនៃការអនុវត្តនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិព្រមទាំងបន្តការគាំទ្រការផ្តួចផ្តើមនៃផែនការសកម្មភាពអាទិភាពនានា ក្នុងគោលដៅរយៈពេលខ្លី។ បន្ថែមពីនេះទៀត ការផ្តួចផ្តើមពេលវេលានានា នឹងរៀបចំតាមរយៈការសិក្សាស្រាវជ្រាវ ការបង្កើនចំណេះដឹងជាសាធារណៈ ការចងក្រង និងចែករំលែកសកម្មភាពចំណេះដឹងស្តីពីការបញ្ជ្រាបយេនឌ័រ និងការវិនិយោគក្នុងការប្រែប្រួលអាកាសធាតុតាមក្រសួង ស្ថាប័នពាក់ព័ន្ធ របាយការណ៍ការតាមដាន និងការវាយតម្លៃ ការផ្សព្វផ្សាយគម្រោងសំខាន់ៗនានា រៀបចំបង្កើតផែនការសកម្មភាពស្តីពីការបញ្ជ្រាបយេនឌ័រនិងការប្រែប្រួលអាកាសធាតុតាមវិស័យ គាំទ្រគម្រោងពាក់ព័ន្ធនឹងយេនឌ័រក្នុងផែនការសកម្មភាពនៅថ្នាក់ក្រោមជាតិ ការអនុវត្ត និងផែនការហិរញ្ញវត្ថុតាមរយៈគម្រោងអនុវត្តហិរញ្ញប្បទាន ពង្រឹងការសម្របសម្រួល និងសមត្ថភាពស្ថាប័នសម្រាប់ការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិត។ |

| | |
|---|---|
| រយៈពេលវែង (២០២៣-២០៣០) | គោលដៅរយៈពេលវែងផ្តោតលើការស្រាវជ្រាវស៊ីជម្រៅ ការរៀនសូត្រនិងចែករំលែកវឌ្ឍនភាព វិភាគពីតម្រូវការនិងបញ្ហាប្រឈម និងផ្តល់យោបល់ពីវិធីសាស្ត្រជាក់លាក់ក្នុងការទប់ស្កាត់នឹងទម្រង់ថ្មីៗនៃភាពងាយរងគ្រោះពីផលប៉ះពាល់អាកាសធាតុ និងដោះស្រាយហានិភ័យគ្រោះមហន្តរាយនានា។ ផ្អែកលើការវិភាគអនុសាសន៍ជាក់លាក់ នឹងត្រូវធ្វើឡើងដើម្បីបង្កើនការចងក្រងការអនុវត្តល្អៗសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គំនិតផ្តួចផ្តើមនេះនឹងបំពេញបន្ថែមលើគោលដៅនានារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបំពេញនូវការប្តេជ្ញាចិត្តក្នុង ការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ ហើយចូលរួមចំណែកដោយផ្ទាល់ទៅក្នុងផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមមាន គោលដៅទី៥ស្តីពីសមភាពយេនឌ័រ គោលដៅទី១៣ ស្តីពីៈសកម្មភាពបរិស្ថាន គោលដៅទី១ ស្តីពីៈមិនមានភាពក្រីក្រ គោលដៅទី២ ស្តីពីៈការលុបបំបាត់ភាពអត់ឃ្លានឱ្យស្មើសូន្យ គោលដៅទី៦ ស្តីពីៈទឹកស្អាតនិងអនាម័យ ។ល។ |

ដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០៣០ ការគាំទ្រតម្រូវការរបស់សហគមន៍ដែលងាយរងគ្រោះជាងគេ ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ចំណុចអាទិភាព និងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ ផែនការមេអនុម័តដោយអ្នកណា? (ស្ថាប័នណា?) គួរធ្វើអ្វី? (គោលដៅ) និងនៅពេលណា? (ពេលវេលាកំណត់រយៈពេលខ្លី មធ្យម និងវែង) ដែលមាននៅ GCCC ក្រសួងដែលមានភារៈកិច្ចក្នុងវិស័យនេះ អង្គការសង្គមស៊ីវិលបណ្តាញរបស់ខ្លួន និងវិស័យឯកជន(សូមមើលតារាងខាងក្រោមដែលបង្ហាញពីការសន្ទត់សំខាន់ៗសម្រាប់បញ្ហាជាក់លាក់នីមួយៗ ដែលឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្នជាមូលដ្ឋាន និងបញ្ហាប្រឈមចំពោះការសម្រេចគោលដៅ)។

*តារាងទី៦-គោលដៅយុទ្ធសាស្ត្រសម្រាប់ក្រសួងកិច្ចការនារី ក្រសួងតាមវិស័យ សង្គមស៊ីវិល និងវិស័យឯកជន*

| GCCC នៃ ក្រសួងកិច្ចការនារី | ក្រសួងតាមវិស័យ | អង្គការសង្គមស៊ីវិល | វិស័យឯកជន | ការសន្ទត់ |
|---|---|---|---|---|
| **គោលដៅរយៈពេលខ្លី (២០១៨-២០១៩)** | | | | |
| ១-MPGCCត្រូវបានបោះពុម្ពផ្សាយ<br>២-GMGMសម្រាប់វិស័យផ្សេងៗត្រូវបានបោះពុម្ពផ្សាយ<br>៣-G-CCAPត្រូវបានបង្កើតឡើង<br>៤-ការវិភាគសេដ្ឋកិច្ចនៃការបញ្ជ្រាបយេនឌ័រក្នុងCCAត្រូវបានលើកឡើង<br>៥-CSOដែលធ្វើការលើការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគក្នុងCCត្រូវបានពង្រឹងសមត្ថភាព | ១-ការយល់ដឹង និងសមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រក្នុងCCIs ត្រូវបានលើកកម្ពស់<br>២-G-CCAPត្រូវបានអភិវឌ្ឍន៍ឡើង និងអនុវត្ត | ១-ការយល់ដឹងនិងសមត្ថភាពសម្រាប់អ្នកតំណាងCSO តាមវិស័យ ត្រូវបានលើកកម្ពស់<br>២-ក្រុមការងារបច្ចេកទេសតាមវិស័យ (TWG) សម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងCCIsត្រូវបានបង្កើតឡើង | ១-សមាជិកសភាពាណិជ្ជកម្ម ឬក្រុមហ៊ុននានាបានចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងCCIs<br>២-គំនិតផ្តួចផ្តើមដែលគិតគូរពីការបញ្ជ្រាបយេនឌ័របានបង្កើតឡើង | ១-មន្ត្រីបច្ចេកទេសនៅក្នុងក្រសួងនៃរាជរដ្ឋាភិបាលមានពេលតិចតួចក្នុងការចូលរួម២- CSO និងអ្នកតំណាងវិស័យឯកជនមិនទាន់បានចូលរួមនៅក្នុងដំណើរការនៅឡើយ |

| GCCC នៃ ក្រសួងកិច្ចការនារី | ក្រសួងតាមវិស័យ | អង្គការសង្គមស៊ីវិល | វិស័យឯកជន | ការសន្មត់ |
|---|---|---|---|---|
| **គោលដៅរយៈពេលមធ្យម (២០១៩-២០២៣)** | | | | |
| ១-GCCC ក្រសួងតាមវិស័យ CSO ដែលបានអនុវត្ត ឬចាប់ផ្តើម អនុវត្តផែនការសកម្មភាពអាទិភាពទាំង៧ និងពិនិត្យឡើងវិញនៃវឌ្ឍនភាព MPGCC<br>២-G-CCAP នៅតាមវិស័យ CSO និងវិស័យឯកជន និង GCCC បានដាក់អោយដំណើរការនូវគម្រោងនានាតាមរយៈ: ការផ្តល់នូវធនធានបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រសួងតាមវិស័យ CSO និងវិស័យឯកជន សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុ<br>៣-ការវិភាគផ្សេងៗគ្នា ត្រូវបានរៀបចំ និងចងក្រងឡើង។ | ១-G-CCAPs បានប្រតិបត្តិការ<br>២-ការអនុវត្ត G-CCAP ត្រូវបានពិនិត្យឡើងវិញ<br>៣-ទិសដៅទៅថ្ងៃអនាគត (សកម្មភាពទាក់ទងនឹងយេនឌ័រ) ត្រូវបានកំណត់ ។ | ១-CSO ជាសមាជិកក្រុមការងារបច្ចេកទេសតាមវិស័យ<br>២-ការវិនិយោគក្នុងការបន្សុាំ ការកាត់បន្ថយ និងការបង្ការគ្រោះមហន្តរាយត្រូវបានគិតគូរពី យេនឌ័រ<br>៣-វេទិការពិភាក្សារវាង CSO រាជរដ្ឋាភិបាល និងវិស័យឯកជន មានដំណើរការ។ | ១-សមាជិកសភាពាណិជ្ជកម្ម ឬក្រុមហ៊ុននានាបានអភិវឌ្ឍគោលនយោបាយបញ្ជ្រាបយេនឌ័រក្នុងការ វិនិយោគ និងអាជីវកម្មព្រមទាំងនីតិវិធីការងារ | ធនធានបច្ចេកទេស និងហិរញ្ញវត្ថុនៅមានកម្រិតសម្រាប់រាជរដ្ឋាភិបាល CSO និងវិស័យឯកជន |

| GCCC នៃ ក្រសួងកិច្ចការនារី | ក្រសួងតាមវិស័យ | អង្គការសង្គមស៊ីវិល | វិស័យឯកជន | ការសន្មត់ |
|---|---|---|---|---|
| **គោលដៅរយៈពេលវែង (២០២៣-២០៣០)** | | | | |
| ១- ផែនការសកម្មភាពអាទិភាពត្រូវបានអនុវត្ត<br>២-អនុសាសន៍ស្តីពីការពិនិត្យឡើងវិញវឌ្ឍនភាពត្រូវបានវិភាគ ហើយទិសដៅទៅថ្ងៃខាងមុខត្រូវបានកំណត់<br>៣-ការវិភាគសេដ្ឋកិច្ច និងការផ្លាស់ប្តូរត្រូវបានធ្វើឡើង ផែនការមេថ្មីត្រូវបានកំណត់។ | ១-ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងនៅក្នុងក្រសួងតាមវិស័យ<br>២-ការបញ្ជ្រាបយេនឌ័រក្នុងគម្រោងប្រែប្រួលអាកាសធាតុបានក្លាយជារបៀបវារៈរួម<br>៣-វិស័យនានាបានធ្វើការវិភាគពីវឌ្ឍនភាព<br>៤-ការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគតាមវិស័យក្លាយជារបៀបវារៈអចិន្ត្រៃយ៍។ | ១-ក្រុមការងារបច្ចេកទេសសម្រាប់ CSO ដើរតួជាមជ្ឈមណ្ឌលធនធានសម្រាប់ CSO ទាំងអស់<br>២-វេទិកាពិភាក្សាមានដំណើរការល្អ<br>៣-ការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគរបស់ CSO ប្រែក្លាយជារបៀបវារៈអចិន្ត្រៃយ៍។ | ១-សមាជិកសភាពាណិជ្ជកម្ម ឬក្រុមហ៊ុននានាបានបង្កើតក្រុមការងារបច្ចេកទេសបញ្ជ្រាបយេនឌ័រក្នុងគម្រោងប្រែប្រួលអាកាសធាតុរបស់គេ<br>២-វិស័យឯកជនបានផ្តល់ធនធានគ្រប់គ្រាន់ ហើយការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគប្រែក្លាយជារបៀបវារៈអចិន្ត្រៃយ៍។ | ១-កង្វះខាតគោលនយោបាយគាំទ្រ<br>២-ធនធានមិនគ្រប់គ្រាន់ បន្ថយល្បឿនដំណើរការនៃការអភិវឌ្ឍ។ |

### ៤.៥ . គោលការណ៍ណែនាំ

គោលការណ៍ណែនាំខាងក្រោមនេះ ត្រូវបានអនុវត្តសម្រាប់ដំណើរការផែនការនេះ ។

- ការបន្ស៊ីជាមួយគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា[16]
- ការបន្ស៊ីជាមួយតម្រូវការនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ពង្រឹងភាពធន់នឹងអាកាសធាតុ[17]
- ការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុទាំងអស់[18]
- ការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់បែងចែកតាមភេទដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

## ៥. ការធ្វើឱ្យការបញ្ជ្រាបយេនឌ័រក្លាយជារបៀបវារៈក្នុងការអភិវឌ្ឍប្រកបដោយចីរភាព

### ៥.១ គោលនយោបាយជាតិ និងផែនការ

ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគក្នុងការបន្ស៊ាំ ការកាត់បន្ថយ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងការប្រែប្រួលអាកាសធាតុ អាចត្រូវបានចាត់ទុកថាជាជំហានចម្បងក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី និងបុរសដើម្បីឈានដល់គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា និងបំពេញបន្ថែមនូវតម្រូវការសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទទួលស្គាល់នូវតម្រូវការ និងបង្ហាញពីដំណើរឆ្ពោះទៅមុខក្នុងការបញ្ជ្រាបយេនឌ័រនិងការប្រែប្រួលអាកាសធាតុ។ យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ កង្វះខាតក្នុងការបញ្ជ្រាបយេនឌ័រនៅតាមបណ្តាខេត្ត ព្រមទាំងធនធានថវិកា និងសម្ភារៈមិនគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយអំពីគោលនយោបាយ និងច្បាប់នានាដែលទាក់ទងនឹងសមធម៌រវាងកម្មករនិយោជិតជាបុរស និងស្ត្រី ទាំងនៅក្នុងទីផ្សារការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាភាពចន្លោះប្រហោង២ ដ៏សំខាន់បំផុត។

ការពង្រឹងការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នរដ្ឋ និងស្ថាប័នក្រៅរដ្ឋាភិបាល ដើម្បីធ្វើការបញ្ជ្រាបយេនឌ័រដូចជា ទៅក្នុងកម្មវិធីបរិស្ថាននិងគោលនយោបាយប្រែប្រួលអាកាសធាតុ ផែនការសកម្មភាពជាតិស្តីពីបរិស្ថានគឺជាមូលដ្ឋានគ្រឹះ ដើម្បីបញ្ជ្រាបយេនឌ័រក្នុងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទោះជាយ៉ាងណាក៏ដោយទិដ្ឋភាពគោលនយោបាយតម្រូវឱ្យមានការគាំទ្រយ៉ាងពេញទំហឹង។ ដូច្នេះសកម្មភាពមួយចំនួនដូចជា ការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងសេដ្ឋកិច្ច តាមរយៈការពង្រឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយធ្វើការបំពាក់បំប៉ននូវជំនាញបច្ចេកទេសនិងសហគ្រិនភាព ក៏ដូចជា

---

[16] យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៨ និងពង្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៤ នារីរតនៈទី៤ និងពង្រាងនារីរតនៈទី៥ ផែនការយុទ្ធសាស្ត្រសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤ ដល់ ឆ្នាំ២០២៣ ផែនការសកម្មភាពជាតិសម្រាប់គម្រោងបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ។ល។

[17] SDG13 សកម្មភាពបន្ទាន់សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

[18] គម្រោង និងកម្មវិធីទាំងអស់នៃ SPCR គម្រោងដែលស្នើសុំក្នុងផែនការមេ និងគម្រោងបន្ស៊ាំនានាក្នុងប្រទេសកម្ពុជា។

លើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យសាធារណៈ តាមរយៈការបង្កើនសមាមាត្រស្ត្រីនៅតាមបណ្តាក្រសួងពាក់ព័ន្ធ រួមជាមួយនឹងការពង្រឹងសមត្ថភាពក្នុងការបន្តភាពជាអ្នកដឹកនាំ ការធានាឱ្យបាននូវគោលនយោបាយនិងយុទ្ធសាស្ត្រដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គួរត្រូវបានអនុវត្ត និងធានានូវការអភិវឌ្ឍបៃតង ហើយការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ ការបង្កើនកិច្ចខិតខំប្រឹងប្រែង ការទប់ទល់នឹងការប្រែប្រួលអាកាសធាតុនៅតាមកម្រិត សហគមន៍ ជាពិសេសសម្រាប់ស្ត្រីនិងកុមារី ការបង្កើតគំនិតផ្តួចផ្តើមសមស្របសម្រាប់កាត់បន្ថយផលប៉ះពាល់លើសុខភាពរបស់ស្ត្រីនិងកុមារ ជាពិសេសនៅក្នុងអំឡុងពេលគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ការបង្កើនចំណេះដឹងដល់ស្ត្រីពីរបៀបនៃការកាត់បន្ថយហានិភ័យ ដើម្បីធានានិរន្តរភាពធនធានធម្មជាតិនិងការការពារបរិស្ថានប្រកបដោយចីរភាព។ល។

ឯកសារគោលនយោបាយស្តីពី សមភាពយេនឌ័រនិងការផ្តល់ភាពអង់អាចដល់ស្ត្រី យល់ថាសមភាពយេនឌ័រជាកត្តាជំរុញនៃការផ្លាស់ប្តូរហើយបានក្លាយទៅជាមូលដ្ឋានគ្រឹះសម្រាប់សម្រេចបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។ ហេតុដូច្នេះការបញ្ជ្រាបយេនឌ័រជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅគ្រប់ទម្រង់នៃការវិនិយោគការប្រែប្រួលអាកាសធាតុ ដែលជាគ្រឹះនៃការកសាងសហគមន៍ធន់នឹងអាកាសធាតុនៅកម្ពុជា។

## *៥.២ ការគិតគូរពីការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគការប្រែប្រួលអាកាសធាតុ*

ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈដោយបរិយាប័ន្នយេនឌ័រ និងយុទ្ធសាស្ត្រនានារបស់ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល គឺបានចូលរួមយ៉ាងសកម្ម ដើម្បីដោះស្រាយបញ្ហាសមភាពយេនឌ័រនៅប្រទេសកម្ពុជា។

ការរីកចម្រើនគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឡើងតាមរយៈការបង្ហាញនៅតាមវិស័យនានាដូចជាៈ ច្បាប់ គោលនយោបាយ កម្មវិធី និងគម្រោងនានាដែលបានឆ្លើយតបនឹងយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី វឌ្ឍនភាពឆ្ពោះទៅរកការលុបបំបាត់ពល់ទម្រង់នៃការរើសអើងក៏ដូចជាប្រឆាំងនឹងស្ត្រី ការចូលរួមរបស់ស្ត្រីនិងកុមារីនៅក្នុងការអប់រំ សីល-ធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ ក៏ដូចជាការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត។ សមិទ្ធផលទាំងនេះគឺជាគ្រឹះដ៏រឹងមាំសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា។

ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុ ត្រូវបានចាត់ទុកថាជាដំណើរការមានលក្ខណៈជាប្រព័ន្ធ ឧទាហរណ៍ ជាលក្ខណៈម្តងមួយជំហានៗនៃសកម្មភាពដែលធានាថា ការប្រឹងប្រែងក្នុងការបញ្ជ្រាបយេនឌ័រប្រកបដោយនិរន្តភាព និងត្រូវបានវាយតម្លៃខ្ពស់ចំពោះគោលនយោបាយ គោលដៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ សៀវភៅណែនាំការបញ្ជ្រាបយេនឌ័របានកំណត់ជាប្រាំដំណាក់កាល សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងការការវិនិយោគបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនានា ។ កិច្ចការនេះអាចដើរតួនាទីជាគំរូសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយផងដែរ។

*តារាងទី ៧- ដំណើរការ និងបញ្ហាប្រឈមសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា*

| ប្រធានបទ | ដំណើរការ | បញ្ហាប្រឈម |
|---|---|---|
| ការយល់ដឹងអំពីបញ្ហានៃការបញ្ជ្រាបសមភាពយេនឌ័រ | មានកម្រិតនៃការយល់ដឹង និងគំនិតផ្តួចផ្តើមមួយចំនួនដែលត្រូវបានគេយកទៅធ្វើការបញ្ជ្រាបសមភាពយេនឌ័រនៅក្នុងវិស័យផ្សេងៗគ្នា។ ឧ. ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុ គឺជាប្រធានបទថ្មីសម្រាប់បណ្តាក្រសួង អង្គការសង្គមស៊ីវិល និងវិស័យដទៃទៀត |
| សមត្ថភាពស្ថាប័ននិងសហគមន៍និងការសម្របសម្រួលតាមវិស័យ ដែលផ្តោតទៅលើតួនាទីរបស់ស្ត្រីក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ ផែនការនារីរតនៈ ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុគឺជាវិស័យ និងជាឯកសារគោលនយោបាយជាក់លាក់ ។ ក្រុមការងារសម្របសម្រួល PPCR និង TWG កំពុងពង្រឹងសមត្ថភាពស្ថាប័ន និងមានវិធានការសម្របសម្រួលអន្តរវិស័យ។ គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCC) ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលការបញ្ជ្រាបយេនឌ័រក្នុងគំនិតផ្តួចផ្តើមនៃការវិនិយោគលើការប្រែប្រួលអាកាសធាតុ | ធនធានបច្ចេកទេស និងហិរញ្ញវត្ថុមានកម្រិតបានរិតត្បិតដល់ផែនការដែលបានផ្តួចផ្តើមឡើង។ ការបញ្ជ្រាបយេនឌ័រនៅក្នុងការផ្តួចផ្តើមការវិនិយោគលើការប្រែប្រួលអាកាសធាតុមិនទាន់ក្លាយជាផ្នែកមួយនៃផែនការដែលមាននិរន្តភាពនៅឡើយទេ។ កង្វះតួនាទីដែលបានកំណត់នៅក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យ |
| ការបញ្ជ្រាបយេនឌ័រនៅក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុនឹងក្លាយជាផ្នែកមួយនៃការអភិវឌ្ឍរបៀបវារៈ | រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាបញ្ហាយេនឌ័រគឺជាផ្នែកមួយនៃគ្រប់ការអភិវឌ្ឍទាំងអស់។ | មិនទាន់មានការផ្តួចផ្តើមជាក់លាក់ណាមួយដើម្បីបញ្ចូលការបញ្ជ្រាបយេនឌ័រ នៅក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុដែលជាផ្នែកមួយនៃផែនការដែលមាននិរន្តភាពនៅឡើយទេ។ |
| វេទិកាពិភាក្សារវាងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជន | មានទំនាក់ទំនងផ្សេងគ្នា ដូចជាទំនាក់ទំនងយេនឌ័រ និងការអភិវឌ្ឍបាននឹងកំពុងតែដំណើរការ | មិនមានវេទិកាពិភាក្សាសម្រាប់ភាគីរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកជំនាញការ សម្រាប់ធ្វើការបង្កើតគោលនយោបាយជាតិ ដើម្បីដោះស្រាយការបញ្ជ្រាបយេនឌ័រនៅក្នុងការ ប្រែប្រួលអាកាសធាតុ និងវិស័យសេដ្ឋកិច្ចនៅឡើយទេ |

( យោងតាមសៀវភៅណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ របស់ក្រសួងកិច្ចការនារី ឆ្នាំ២០១៧ )

### ៥.៣ ទិន្នន័យ និងលទ្ធផលស្តីពីសមភាពយេនឌ័រ

ដោយផ្អែកលើសូចនាករស្តីពីយេនឌ័រនិងភាពធន់នឹងអាកាសធាតុនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCC) នៃក្រសួងកិច្ចការនារី និងក្រសួងផែនការ មានបំណងរក្សាទិន្នន័យបែងចែកតាមភេទ ដែលបានធ្វើបច្ចុប្បន្នភាពដោយវិទ្យាស្ថានជាតិស្ថិតិ និងធ្វើការសហការគ្នាដើម្បីតាមដាន រាយការណ៍ និងវាយតម្លៃផលប៉ះពាល់លើយេនឌ័រ ដែលធ្វើឡើងដោយគម្រោងវិនិយោគលើការប្រែប្រួលអាកាសធាតុ ។

## ៦.ប្រតិបត្តិការរបស់ផែនការមេ

### ៦.១ ប្រតិបត្តិការរបស់ផែនការមេ (បុរេលក្ខណៈ)

មានតម្រូវការដើម្បីបង្កើតឱ្យមានបរិយាកាសបង្ករលក្ខណៈងាយស្រួលសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុ ។ បុរេលក្ខណៈខាងក្រោមមួយចំនួនឈានទៅរកការធ្វើប្រតិបត្តិការប្រកបដោយជោគជ័យសម្រាប់ក្រុមការងារ MPGCC ៖

១- ការផ្សព្វផ្សាយ ការស្វែងរកការគាំទ្រមតិ ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពសម្រាប់ក្រុមការងារ MPGCC ជាការចាំបាច់សម្រាប់គ្រប់វិស័យ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងភ្នាក់ងារវិស័យឯកជននានា។ ក្រុមការងារ GCCC គួរតែមានការគាំទ្រអ្នក ពាក់ព័ន្ធ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីបង្កើតភាពងាយស្រួលក្នុងការប្រតិបត្តិ ផែនការមេនេះ ។

២-រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងភ្នាក់ងារអនុវត្តនានា គួរពិចារណាអំពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងការវិនិយោគការបន្សាំ ការកាត់បន្ថយ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងរបៀបវារៈអចិន្ត្រៃយ៍របស់ពួកគាត់។

៣-ក្រសួងតាមវិស័យ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា គួរតែចូលរួមអោយទូលំទូលាយ និងមានគំនិតផ្តួចផ្តើមជាអាទិភាពសម្រាប់ផែនការមេនេះ។

### ៦.២ ការផ្តួចផ្តើមគាំទ្រលើចំណុចអាទិភាពរបស់ក្រសួងកិច្ចការនារី

គម្រោងជាអាទិភាពចំនួន៧ ត្រូវបានកំណត់ ដោយផ្អែកលើការពិនិត្យឡើងវិញ ការប៉ាន់ប្រមាណពីតម្រូវការនៃការសាងសមត្ថភាព ការពិគ្រោះយោបល់ និងការផ្តល់ព័ត៌មានត្រឡប់ពីការប្រជុំ សិក្ខាសាលា និងការពិគ្រោះយោបល់នៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិនានា ដែលធ្វើឡើងនៅក្នុងឆ្នាំ២០១៦-២០១៨។

ផ្អែកលើធនធាននិងឱកាសដែលមានស្រាប់ GCCC មានគោលបំណងអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជាអាទិភាព។ លើសពីនេះទៅទៀត GCCC សូមស្វាគមន៍ចំពោះកិច្ចសហការក្នុងការចូលរួមអនុវត្តគម្រោងអាទិភាពដែលបានស្នើសុំក្នុងផែនការមេនេះ។ តារាងទី៨ ជាបញ្ជីចំណាត់ថ្នាក់ផែនការសកម្មភាពជាអាទិភាពតាមវិស័យដែលគេបានកំណត់ ខណៈពេលដែលធនធានថវិកានៅមានកម្រិតឬបញ្ហាផ្សេងទៀត ការអនុវត្តផែនការសកម្មភាពអាទិភាពក្នុងផែនការមេនេះអាចនឹងមានភាពយឺតយ៉ាវសម្រាប់រយៈពេលខ្លី (ឆ្នាំ២០១៨-២០១៩)។

*តារាងទី៨- វិស័យអាទិភាពក្នុងការបញ្ជ្រាបយេនឌ័រ និងគម្រោងដែលបានស្នើសុំ*

| **គម្រោងទី១-** ការពង្រឹងសមត្ថភាពស្ថាប័នស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងការផ្តួចផ្តើមការវិនិយោគលើការប្រែប្រួលអាកាសធាតុនៅកម្ពុជា | |
|---|---|
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១- ប៉ាន់ប្រមាណតម្រូវការផ្នែកស្ថាប័នរបស់ភាគីពាក់ព័ន្ធសំខាន់ៗលើការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគលើការប្រែប្រួលអាកាសធាតុ | ១- ការប៉ាន់ប្រមាណតម្រូវការសមត្ថភាពរបស់ស្ថាប័នការផ្តួចផ្តើមកសាងសមត្ថភាព ដែលត្រូវធ្វើឡើងសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ |
| ២- ការពង្រឹងសមត្ថភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗស្តីពីការគិតគូរពីការបញ្ជ្រាបយេនឌ័រ | ២- ការផ្តួចផ្តើមបង្កើនការយល់ដឹង ការបណ្តុះបណ្តាល និងបណ្តុះបណ្តាលគ្រូបង្គោល។ល។ ដែលត្រូវធ្វើឡើងសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗស្តីពីការបារម្ភចំពោះការបញ្ជ្រាបយេនឌ័រ |
| ការអនុវត្ត: គម្រោងវិនិយោគ SPCR ដែលអនុវត្តដោយ MAFF, MoWRAM, MoPWT និង MoH | |
| ថេរៈវេលា: ៣ឆ្នាំ | |
| ថវិកា: | |
| **គម្រោងទី២-** ការពង្រឹងការសម្របសម្រួលស្ថាប័នជាមួយក្រសួងវិស័យ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអន្តរវិស័យក្នុងការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគ ឃុំ សង្កាត់ | |
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១- ពង្រឹងយន្តការសម្របសម្រួលការបញ្ជ្រាបយេនឌ័រត្រូវបានបង្កើតថ្មីជាមួយក្រសួងវិស័យសង្គមស៊ីវិល និងវិស័យឯកជន។ | ១- យន្តការសម្របសម្រួលបញ្ជ្រាបយេនឌ័រដែលដំណើរការបានល្អត្រូវបានបង្កើតឡើង |
| ២- ផ្តួចផ្តើមឱ្យមានផែនការស្វែងរកការគាំទ្រមតិ បង្កើនការយល់ដឹង និងចែករំលែកបទពិសោធន៍ការអនុវត្តល្អៗ ដល់អ្នកពាក់ព័ន្ធ | ២- ផែនការស្វែងរកការគាំទ្រមតិ បង្កើនការយល់ដឹង ចែករំលែកបទពិសោធន៍ និងការអនុវត្តបានល្អៗ ដល់អ្នកពាក់ព័ន្ធត្រូវបានអនុវត្ត |
| ការអនុវត្ត: គម្រោងវិនិយោគ SPCR ដែលអនុវត្តដោយ MAFF, MoWRAM, MoPWT និង MoH | |
| ថវិកា: | |
| **គម្រោងទី៣-** ការសាកល្បងគម្រោងគ្រប់គ្រងធនធានទឹកដែលគិតគូរពីយេនឌ័រសម្រាប់លើកកម្ពស់ភាពធន់របស់សហគមន៍សម្រាប់ការប្រើប្រាស់ទឹក ការងារកសិកម្ម សុខភាព និងហេដ្ឋារចនាសម្ព័ន្ធជនបទ | |
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១-ប៉ាន់ប្រមាណស្ថានភាពភាពអង់អាចរបស់ស្ត្រីបែងចែកតាមភេទ លទ្ធភាពទទួលបានព័ត៌មាន ការធ្វើការសម្រេចចិត្ត ការរួមចំណែកសកម្មភាពជីវភាពរស់នៅតាមបែបអាកាសធាតុមេត្រីប្រកបដោយចីរភាព | ១-ស្ថានភាពសមាមាត្រយេនឌ័រលើការផ្តល់ភាពអង់អាចរបស់ស្ត្រី លទ្ធភាពទទួលបានព័ត៌មាន ការធ្វើការសម្រេចចិត្ត ការរួមចំណែកសកម្មភាពជីវភាពរស់នៅតាមបែបអាកាសធាតុមេត្រីប្រកបដោយចីរភាព ត្រូវបានសម្របសម្រួល ។ល។ |
| ២-បញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងបន្សាំសាកល្បងនានា ជាមួយនិងតួនាទី និងការទទួលខុសត្រូវដែលបានកំណត់ | ២-គម្រោងបន្សាំសាកល្បងនានា ជាមួយនិងតួនាទីដែលបានកំណត់ ចំពោះបុរសនិងស្ត្រី ត្រូវបានបញ្ជ្រាប |

| | |
|---|---|
| ៣-ប៉ាន់ប្រមាណការបញ្ជ្រាបយេនឌ័រដែលមានប្រយោជន៍ដល់ការផ្តល់ភាពអង់អាច លទ្ធភាពទទួលបានព័ត៌មាន ការធ្វើសេចក្តីសម្រេច ការរួមចំណែកសកម្មភាពជីវភាពរស់នៅដែលគិតគូរពីការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាព ។ល។ | ៣-ការសម្រេចបាននូវការបញ្ជ្រាបយេនឌ័រ និងបញ្ហាប្រឈមចំពោះការផ្តល់ភាពអង់អាច លទ្ធភាពទទួលបានព័ត៌មាន ការធ្វើសេចក្តីសម្រេច ការរួមចំណែកសកម្មភាពជីវភាពរស់នៅដែលគិតគូរពីការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាព ត្រូវបានពង្រឹង ។ល។ |
| ៤-ធ្វើការវិភាគតម្លៃសេដ្ឋកិច្ចលើការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគបន្សាំ | ៤-ការសិក្សាទូលំទូលាយនិងប្រៀបធៀបត្រូវបានធ្វើឡើងនៅក្នុងតំបន់សាកល្បងទាំង៤ ស្តីពីអត្ថប្រយោជន៍សេដ្ឋកិច្ចនៃការនៃបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគបន្សាំ |
| ការអនុវត្តៈ បាត់ដំបង កំពត កំពង់ធំ និងព្រៃវែង ជាតំបន់ងាយរងគ្រោះដែលត្រូវបានជ្រើសរើស | |
| ថវិកាៈ | ១២០ ០០០ ដុល្លារអាមេរិក |
| **គម្រោងទី៤-** ការបញ្ជ្រាបយេនឌ័រនៅក្នុងការបន្សាំ ការបង្ការ និងការកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិផ្តួចផ្តើមនៅកម្រិតគោលនយោបាយថ្នាក់ក្រោមជាតិ កម្មវិធី និងគម្រោង | |
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១-ធ្វើការសិក្សាពីស្ថានភាពនិងវិធីសាស្ត្របច្ចុប្បន្នលើការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំផែនការថ្នាក់ក្រោមជាតិ | ១-ស្ថានភាពនិងវិធីសាស្ត្របច្ចុប្បន្ន លើការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំផែនការថ្នាក់ក្រោមជាតិត្រូវបានសិក្សាឡើង |
| ២-បញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងឯកសារមគ្គុទេសដែលមានស្រាប់សម្រាប់ដំណើរការធ្វើផែនការថ្នាក់ក្រោមជាតិ | ២-បញ្ហាបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងឯកសារមគ្គុទេសដែលមានស្រាប់សម្រាប់ដំណើរការធ្វើផែនការថ្នាក់ក្រោមជាតិ ដោយមានការសហការជាមួយនឹង NCDDS |
| ៣-អនុវត្តផែនការសកម្មភាពស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីដែលមានស្រាប់ | ៣-ផែនការសកម្មភាពបញ្ជ្រាបបញ្ហាយេនឌ័រ (គម្រោងសាកល្បង) នៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ត្រូវបានរៀបចំ និងអនុវត្ត |
| ការអនុវត្តៈ សាលាខេត្ត ក្រុង ស្រុក ខណ្ឌ គ្រប់ឃុំ សង្កាត់ក្រោមឪវាទ NCDD-S និង SPCR | |
| ថវិកាៈ | |
| **គម្រោងទី ៥-** ប្រព័ន្ធទិន្នន័យបែងចែកតាមភេទសម្រាប់ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងវិទ្យាស្ថានជាតិស្ថិតិ (NIS) | |
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១-ធ្វើការប៉ាន់ប្រមាណស្ថានភាពបច្ចុប្បន្នរបស់ NIS ឈរលើទស្សនៈដែលឆ្លើយតបនឹងយេនឌ័រ | ១-ស្ថានភាពបច្ចុប្បន្នរបស់ NIS ឈរលើទស្សនៈដែលឆ្លើយតបនឹងយេនឌ័រត្រូវបានធ្វើការប៉ាន់ប្រមាណ |
| ២-អភិវឌ្ឍន៍តួនាទីយុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងប្រព័ន្ធទិន្នន័យរបស់ NIS | ២-ជំហរយុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបដែលឆ្លើយតបនិងប្រព័ន្ធទិន្នន័យយេនឌ័ររបស់ NIS ត្រូវបានរៀបចំ |
| ៣-អនុវត្តប្រព័ន្ធទិន្នន័យយេនឌ័ររបស់ NIS ដែលនិងលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព | ៣-ប្រព័ន្ធទិន្នន័យឆ្លើយតបនឹងយេនឌ័ររបស់ NIS ត្រូវបានរៀបចំឡើង |
| ការអនុវត្តៈ NIS និង ស្ថាប័ន ឬដៃគូរបស់ខ្លួន | |
| ថវិកាៈ | |

| | |
|---|---|
| **គម្រោងទី៦-** សូចនាករបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុត្រូវបានកំណត់នៅក្នុងប្រព័ន្ធតាមដាន, រំលឹកឡើងវិញ និងវាយតម្លៃថ្នាក់ជាតិ M,R &E | |
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១-ធ្វើការប៉ាន់ប្រមាណ ស្ថានភាពប្រព័ន្ធ តាមដាន រាយការណ៍ និងវាយតម្លៃ (Monitoring, Report and Evaluation) ដោយឈរលើមូលដ្ឋានទស្សនៈការបញ្ជ្រាបយេនឌ័រ | ១-ស្ថានភាពប្រព័ន្ធតាមដាន រាយការណ៍ និងវាយតម្លៃដោយឈរលើមូលដ្ឋានទស្សនការបញ្ជ្រាបយេនឌ័រត្រូវបានប៉ាន់ប្រមាណ |
| ២-អភិវឌ្ឍន៍តួនាទីយុទ្ធសាស្ត្រដើម្បីឆ្លើយតបនឹងការបញ្ជ្រាបយេនឌ័រ ក្នុងប្រព័ន្ធតាមដាន រាយការណ៍ និងវាយតម្លៃ | ២-តួនាទីយុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបប្រព័ន្ធតាមដាន រាយការណ៍ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រដែលបានបង្កើតឡើង |
| ៣-អនុវត្តប្រព័ន្ធ M,R&E ឆ្លើយតបនិងការ បញ្ជ្រាបយេនឌ័រ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព | ៣-ប្រព័ន្ធ M,R&E ឆ្លើយតបនិងការបញ្ជ្រាបយេនឌ័រលើការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានបង្កើត និងធ្វើឲ្យប្រសើរឡើង |
| ការអនុវត្តៈ ប្រព័ន្ធតាមដាន រាយការណ៍ និងវាយតម្លៃថ្នាក់ជាតិរបស់ក្រសួងផែនការ | |
| ថវិកាៈ | |
| **គម្រោងទី៧-** វេទិកាពិភាក្សាការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ សម្រាប់ការបំពេញបន្ថែមលើការប្តេជ្ញាចិត្តបញ្ជ្រាបយេនឌ័ររបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) | |
| *គោលបំណង* | *លទ្ធផលរំពឹងទុក* |
| ១-ធ្វើការវិភាគអ្នកពាក់ព័ន្ធស្តីពី វេទិកាពិភាក្សាការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ | ១-ការវិភាគអ្នកពាក់ព័ន្ធស្តីពី វេទិកាពិភាក្សាស្តីពីការបញ្ជ្រាបយេនឌ័រ ត្រូវបានធ្វើឡើង |
| ២-ធ្វើការអភិវឌ្ឍតួនាទីជាយុទ្ធសាស្ត្រសម្រាប់ការបង្កើតវេទិកាពិភាក្សាស្តីពីការបញ្ជ្រាបយេនឌ័រនិងការប្រែប្រួលអាកាសធាតុ | ២-តួនាទីជាយុទ្ធសាស្ត្រនិងនិរន្តរភាពវេទិកាពិភាក្សាការបញ្ជ្រាបយេនឌ័រ ត្រូវបានធ្វើឡើង |
| ៣-ធ្វើការសម្របសម្រួលការអនុវត្តវេទិកាពិភាក្សាការបញ្ជ្រាបយេនឌ័រនឹងការប្រែប្រួលអាកាសធាតុ | ៣-វេទិកាពិភាក្សាការបញ្ជ្រាបយេនឌ័រត្រូវបានប្រតិបត្តិ |
| ការអនុវត្តៈ រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន(អង្គការសង្គមស៊ីវិល ភ្នាក់ងារដែលមានសមត្ថភាពអាចដឹកនាំវេទិកានេះបាន) | |
| ថវិកាៈ | |

## ៦.៣ ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍

ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍វឌ្ឍនភាពនៃសកម្មភាពបញ្ជ្រាបយេនឌ័រ ត្រូវតែស្របតាមរបៀបវារៈនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ គឺជាអាទិភាពចម្បងនៃអភិបាលកិច្ចល្អក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព គណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្តក្នុងការសម្រេចបាននូវសមធម៌ និងលទ្ធផលនៃការអភិវឌ្ឍដែលឆ្លើយតបនឹងយេនឌ័រសម្រាប់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។

អង្គការសង្គមស៊ីវិល និងវិស័យពាក់ព័ន្ធនានា អាចពិចារណាលើសូចនាករបន្ថែមទៀត ដោយផ្អែកលើអាទិភាព និងគោលបំណងរបស់គម្រោង។ សូចនាករតាមដានការឆ្លើយតបទៅនឹងយេនឌ័រត្រូវបានរៀបរាប់ដូចខាងក្រោមនៅក្នុងតារាងទី ៩ ៖

*តារាងទី៩- សូចនាករតាមដានឆ្លើយតបទៅនឹងយេនឌ័រ*

| **សូចនាករ** | **ភាពសមស្រប** |
| --- | --- |
| ១- ចំនួននិងភាគរយ ស្ត្រី និងបុរសដែលចូលរួមពេញលេញក្នុងសកម្មភាពនានា ការបណ្តុះបណ្តាល និងការប្រជុំ | ឆ្លុះបញ្ចាំងពីស្ត្រី និងបុរសដែលមានលទ្ធភាពចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា និងកិច្ចពិភាក្សានានាក្នុងការធ្វើសេចក្តីសម្រេចចិត្ត |
| ២- ចំនួននិងភាគរយ ស្ត្រី និងបុរសដែលបានប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការរៀនសូត្រក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ ដែលបានពីការបណ្តុះបណ្តាល ឬកិច្ចប្រជុំនានា | ឆ្លុះបញ្ចាំងពីចំនួនស្ត្រី និងបុរសដែលបានប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការរៀនសូត្រក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ |
| ៣- ចំនួនស្ត្រី និងបុរស ដែលបានទទួលផលប្រយោជន៍ពីគម្រោង | ឆ្លុះបញ្ចាំងចំនួនស្ត្រី និងបុរសដែលបានទទួលផលប្រយោជន៍ពីគម្រោង |
| ៤- ចំនួននិងភាគរយរបស់ស្ត្រី និងបុរស ត្រូវបានកាត់បន្ថយនូវហានិភ័យផ្នែកសុខភាព និងបានទទួលអត្ថប្រយោជន៍ផ្នែកសុខភាពពីគម្រោង | ឆ្លុះបញ្ចាំងពីចំនួននិងភាគរយនៃស្ត្រីនិងបុរសទទួលបានអត្ថប្រយោជន៍ផ្នែកសុខភាពពីគម្រោង |
| ៥- ចំនួនស្ត្រី និងបុរស ដែលបង្ហាញពីភាពជាអ្នកដឹកនាំពេលអនុវត្តសកម្មភាពគម្រោង | ឆ្លុះបញ្ចាំងចំនួនស្ត្រី និងបុរសដែលបង្ហាញពីភាពជាអ្នកដឹកនាំមានការកើនឡើង |
| ៦- ចំនួននិងភាគរយរបស់ស្ត្រីដែលមានចំណូលកើនឡើង | ឆ្លុះបញ្ចាំងពីរបៀបដែលគម្រោងវិនិយោគលើការប្រែប្រួលអាកាសធាតុបានរួមចំណែកបង្កើនប្រាក់ចំណូល |
| ៧- ចំនួនការងារដែលបានបង្កើតឡើងសម្រាប់ ស្ត្រី និងបុរស | ឆ្លុះបញ្ចាំងពីការងារថ្មីដែលបានបង្កើតសម្រាប់ស្ត្រី និងបុរស |
| ៨- ការផ្លាស់ប្តូរវិសមភាពប្រាក់ចំណូលរវាងស្ត្រី និងបុរស (គម្លាតប្រាក់ខែ) | ឆ្លុះបញ្ចាំងពីការកាត់បន្ថយគម្លាតប្រាក់ចំណូល |
| ៩- ក្រសួង វិស័យ អង្គការសង្គមស៊ីវិល និងវិស័យ | ការបង្កើតស្ថាប័ន ក្រុមការងារបញ្ជ្រាបយេនឌ័រនៅក្នុង |

| សូចនាករ | ភាពសមស្រប |
|---|---|
| ឯកជន បានរៀបចំវេទិកាប្រចាំឆ្នាំបម្រុងទុកសម្រាប់ការអនុវត្តការបញ្ជ្រាបយេនឌ័រក្នុង CCI ។ | CCI ដែលត្រូវបានដាក់បញ្ចូលក្នុងរបៀបវារៈ អចិន្ត្រៃយ៍ |
| ១០- ការផ្តួចផ្តើមនានាក្នុងការសម្របសម្រួលជាមួយវិស័យផ្សេងៗ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ត្រូវបានធ្វើឡើងជាប្រចាំ | គំនិតផ្តួចផ្តើមសម្របសម្រួលយ៉ាងហោចណាស់ធ្វើឡើងម្តងក្នុងមួយឆ្នាំដើម្បីរក្សាវិធីសាស្ត្រឱ្យមានភាពរស់រវើកសម្រាប់បញ្ហាបញ្ជ្រាបយេនឌ័រទៅក្នុង CCIs ។ |
| CCI – ការវិនិយោគលើការប្រែប្រួលអាកាសធាតុ CSO – អង្គការសង្គមស៊ីវិល | |

*ឯកសារយោង សូចនាករស្នូលរបស់ PPCR, NR-IV ក្របខណ្ឌការងារតាមដានយេនឌ័ររបស់ក្រសួងផែនការ និងតាមដានលើការប្រែប្រួលអាកាសធាតុរបស់សក្រសួងសេដ្ឋកិច្ច*

## ៧.សេចក្តីបញ្ចប់

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (MPGCC) ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយមួយជាមួយតំណាងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានដោយមានការចូលរួមយ៉ាងសកម្មពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងតំណាងអង្គការសង្គមស៊ីវិល នៅក្នុងដំណើរការពិគ្រោះយោបល់នេះ។ ចក្ខុវិស័យ បេសកកម្ម និងគោលបំណងជាយុទ្ធសាស្ត្រនៃផែនការនេះគឺស្របជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) បច្ចុប្បន្នឆ្នាំ២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ឆ្នាំ២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៣-២០២៣ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ដែលឆ្លើយតបទៅនឹងយេនឌ័រ ។ ផែនការនេះគឺស្របគ្នាជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ឆ្នាំ២០១៩-២០២៣។ បេសកកម្មនៃផែនការមេនេះ " *គឺដើម្បីធ្វើឱ្យមានការបញ្ជ្រាបយេនឌ័រក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (CCA) ការបង្ការការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) ដែលជាផ្នែកមួយនៃរបៀបវារៈទូទៅនៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងវិនិយោគការប្រែប្រួលអាកាសធាតុក្នុងស្ថាប័នសម្រាប់ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) នៅក្នុងប្រទេសកម្ពុជា* "។

ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (MPGCC) ផ្តោតលើបញ្ហាប្រឈមនៃការកសាងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ក្រុង និងថ្នាក់ឃុំ សង្កាត់ ដើម្បីគាំទ្រដល់ការបញ្ជ្រាបយេនឌ័រក្នុងការបន្សាំនឹងការផ្លាស់ប្តូរអាកាសធាតុ ការបង្ការ និងគំនិតផ្តួចផ្តើមក្នុងការវិនិយោគ

លើការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់ប្រទេសកម្ពុជាសម្រាប់រយៈពេល ១២ឆ្នាំ គឺឆ្នាំ២០១៨ ដល់ឆ្នាំ២០៣០។ ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (MPGCC) អំពាវនាវដល់ក្រសួងស្ថាប័នពាក់ពន្ធ័នៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រ ក្នុងរបៀបវារៈអចិន្ត្រៃយ៍របស់ពួកគាត់ដើម្បីដោះស្រាយឲ្យស្របគ្នានឹងគម្រោងវិនិយោគលើការប្រែប្រួលអាកាសធាតុ។

លទ្ធផលរួមដែលចេញពីកិច្ចខិតខំប្រឹងប្រែងក្រោមផែនការមេនេះ នឹងគាំទ្រដល់ផែនការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈបន្ថែមនូវគុណតម្លៃចំពោះការអនុវត្តរបស់ក្រសួងពាក់ព័ន្ធ។ គម្រោងដែលបានស្នើទាំង៧នេះ ផ្តល់នូវតម្លៃបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងនៃការបញ្ជ្រាបយេនឌ័រ ដោយលើកទឹកចិត្តដល់ស្ត្រីវិវត្តន៍ទៅរកការសន្សំសំចៃ ទទួលអនាម័យ ថាមពលកកើតឡើងវិញ ក៏ដូចជាការគាំទ្រដល់សហគ្រាសដែលប្រើប្រាស់ថាមពលដោយបង្កើតឡើងដោយស្ត្រី។ ផែនការសកម្មភាពបន្សុាំតាមវិស័យនឹងត្រូវបានផ្តល់ព័ត៌មាន និងត្រូវបានពង្រឹងតាមរយៈការផ្តល់ការវិនិយោគក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងភាពធន់ ។ ការវិនិយោគបែបនេះនឹងដោះស្រាយនូវបញ្ហាអន្តរវិស័យដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ សុខភាព ការអប់រំ និងវិស័យដទៃទៀត។

# សេចក្តីយោង និងឯកសារ


- សៀវភៅណែនាំ: ប្រទេសដែលដឹកនាំដោយយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ក្រសួងការបរទេស (ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិអភិវឌ្ឍន៍ណ័រឌីក ឆ្នាំ២០១៥)
- សៀវភៅណែនាំស្តីពីការវិភាគសេដ្ឋកិច្ចសង្គម និងយេនឌ័រ: ឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍ (ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ឆ្នាំ១៩៩៥)
- Alston M (ឆ្នាំ២០១២)ការធ្វើអត្តឃាតរបស់បុរសជនបទនៅប្រទេសអូស្ត្រាលី។ វិទ្យាសាស្ត្រសង្គម និងវេជ្ជសាស្ត្រសាកល ៧៤ (៤) ៖ ៥១៥-៥២២
- Alston M (ឆ្នាំ២០១៥) ស្ត្រី និងការប្រែប្រួលអាកាសធាតុនៅប្រទេសបង់ក្លាដែស (ក្រុមហ៊ុន បោះពុម្ព Routledge ទីក្រុងញូវយ៉ក)
- ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ គណៈកម្មាធិការប្រែប្រួលអាកាសធាតុជាតិ (ក្រសួងសេដ្ឋកិច្ច ឆ្នាំ ២០១៤)
- ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៣-២០២៣ ដោយក្រសួងកិច្ចការនារី ឆ្នាំ២០១៣
- ការការពារអាកាសធាតុ: វិធីសាស្ត្រផ្អែកលើហានិភ័យចំពោះការបន្សាំ ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០៥។
- Dankelman I, et al. (ឆ្នាំ ២០០៨) យេនឌ័រ ការប្រែប្រួលអាកាសធាតុ និងសុវត្ថិភាពមនុស្សជាតិ: មេរៀនពីប្រទេសបង់ក្លាដែស ហ្គាណា និងសេនីហ្គាល់ (សមាគមបរិស្ថាននិងអភិវឌ្ឍន៍របស់ស្ត្រី និងអង្គការ ABANTU)
- អង្គការសម្ព័ន្ធភាពយេនឌ័រនិងទឹក និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) (ឆ្នាំ២០០៦) ការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងទឹក
- ការរៀបចំចរិកាទាក់ទងនឹងយេនឌ័រ: ព័ត៌មាននិងទំនាក់ទំនងបរទេស (ហូល្លង់ ឆ្នាំ ២០០២)
- ផែនការប្រតិបត្តិការពង្រឹងភាពអង់អាចដល់ស្ត្រី និងសមភាពយេនឌ័រឆ្នាំ២០១៣-២០២០: ការបន្តរបៀបវារៈ ឆ្ពោះទៅមុខនៅអាស៊ី និងប៉ាស៊ីហ្វិក (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៦)
- ការបញ្ជ្រាបយេនឌ័រ យេនឌ័រនិងការប្រែប្រួលអាកាសធាតុនៅក្នុងក្រសួងពាក់ព័ន្ធនឹងវិស័យនានា (ក្រសួងកិច្ចការនារី ឆ្នាំ២០១៤)
- អង្គការ GIZ (ឆ្នាំ២០១៣) យេនឌ័រ និងការអភិវឌ្ឍជនបទ: ទិដ្ឋភាព វិធីសាស្ត្រ និងការអនុវត្តល្អ (ទីក្រុង ប៊ន)
- មូលនិធិបរិស្ថានសកល (ឆ្នាំ២០១៣) ការពិនិត្យឡើងវិញនូវមូលនិធិបរិស្ថានសកល (GEF) ស្តីពីការការពារបរិស្ថាន និងសង្គម និងការបញ្ជ្រាបយេនឌ័រ (ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី)
- រដ្ឋាភិបាលហ្គាណា (ឆ្នាំ២០១០) យុទ្ធសាស្ត្រយេនឌ័រ និងកសិកម្ម (រដ្ឋធានី អាក្រា)
- រដ្ឋាភិបាលអ៊ូហ្គាន់ដា (ឆ្នាំ២០១០) យុទ្ធសាស្ត្រយេនឌ័រ វិស័យធនធានទឹក និងអនាម័យ (ឆ្នាំ២០១០-១៥) (រដ្ឋធានីកាំប៉ាឡា)

- មូលនិធិអាកាសធាតុបៃតង (ឆ្នាំ២០១៨) ការវាយតម្លៃយេនឌ័រ FP076: គម្រោងខ្សែសង្វាក់ផលិតកម្មកសិពាណិជ្ជកម្មដែលមានលក្ខណៈអំណោយផលដល់អាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ី រាជធានីភ្នំពេញ
- សៀវភៅណែនាំៈការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ (ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិអភិវឌ្ឍន៍ណ័រឌីក ឆ្នាំ២០១៦)
- គោលការណ៍ណែនាំៈ ការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅក្នុងការរៀបចំផែនការ ការរៀបចំថវិកា និងការអនុវត្តរបស់ក្រសួងពាក់ព័ន្ធនឹងវិស័យនានា (គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៃក្រសួងកិច្ចការនារី ឆ្នាំ២០១៦)
- Hepworth N (ឆ្នាំ២០១០) ភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ និងការត្រៀមខ្លួនការបន្សាំនឹងអាកាសធាតុនៅប្រទេសអ៊ូហ្គាន់ដា (តំបន់ Heinrich Böll Stiftung East & Horn of Africa ទីក្រុង ណៃរ៉ូប៊ី)
- L. Aguilar Revelo សៀវភៅណែនាំការបណ្តុះបណ្តាលស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ទីក្រុងសានចូស ប្រទេសកូស្តារីកា ឆ្នាំ២០០៩
- UN Women (ឆ្នាំ២០១៦) ការប្រើប្រាស់ផលប្រយោជន៍រួមរវាងសមភាពយេនឌ័រ និងសកម្មភាពអាកាសធាតុសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ការពិចារណាពីការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងការប្រែប្រួលអាកាសធាតុ (អង្គការសហប្រជាជាតិដើម្បីសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ឆ្នាំ២០១៦)
- MacPhail. F. (ឆ្នាំ២០១៥) ការលើកកម្ពស់ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងប្រទេសកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីឡា
- Meryl James-Sebro ការបង្ហាញពីអំណាចនៃការបញ្ជ្រាបយេនឌ័រ: ការលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់អង្គការក្រៅរដ្ឋាភិបាលនៅអាហ្វ្រិក (ទីក្រុង វ៉ាស៊ីនតោន ឌីស៊ីៈ អង្គការ Inter Action ឆ្នាំ២០០៥)
- ក្រសួងផែនការ ឆ្នាំ២០១៦ គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ការវាយតម្លៃផ្តោតលើសមភាព និងឆ្លើយតបនឹងយេនឌ័រ (EFGRE) នៃគោលនយោបាយ និងកម្មវិធី
- ផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រជីវចម្រុះ ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព
- ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ឆ្នាំ២០១៤-១៨ ក្រសួងកិច្ចការនារី សមភាពយេនឌ័រនិងការផ្តល់ភាពអង់អាច ដល់ស្ត្រី (ក្រសួងកិច្ចការនារី ឆ្នាំ២០១៤)
- វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៣របាយការណ៍ចុងក្រោយស្តីពីអង្កេតចន្លោះជំរឿនប្រជាពលរដ្ឋកម្ពុជាឆ្នាំ២០១៣ ក្រសួងផែនការ រាជធានីភ្នំពេញ
- វិទ្យាស្ថានជាតិស្ថិតិ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៧

- អង្គការOxfam GB ពិនិត្យមើល: https://policy-practice.oxfam.org.uk/publications/cambodia-case-study-women-flourish-in-disaster-risk-reduction-leadership-roles-227176
- អង្គការ Oxfam (ឆ្នាំ២០១២) ករណីសិក្សានៅកម្ពុជា: ស្ត្រីរីកចម្រើនក្នុងតួនាទីជាអ្នកដឹកនាំក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- Pendleton J, Mellish M, Sapuwa H, Irani L (ឆ្នាំ២០១៥) គោលនយោបាយយេនឌ័រ និងសុខភាពបន្តពូជនៅក្នុងប្រទេសម៉ាឡាវី (ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍ
- អន្តរជាតិ (USAID) និងគម្រោងគោលនយោបាយសុខភាព)
- Pettengell C (ឆ្នាំ២០១០) ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ: ការផ្តល់លទ្ធភាពឱ្យប្រជាជនដែលកំពុងរស់នៅក្នុងភាពក្រីក្រអាចបន្សុាំ (អង្គការ Oxfam ចក្រភពអង់គ្លេស)
- ធនធានស្តីពីសមាហរណកម្ម/ការបញ្ជ្រាបយេនឌ័រ៖ ឧបករណ៍ប្រើប្រាស់ សៀវភៅណែនាំការវាយតម្លៃ មេរៀនដែលបានសិក្សា និងការអនុវត្តល្អបំផុត (ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)  ឆ្នាំ២០១២)
- សហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (ឆ្នាំ២០១១) គោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រសម្រាប់មេរោគអេដស៍ និងជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ (ទីក្រុងហ្គាបូរ៉ូណេ)
- សហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (ឆ្នាំ២០១៥) ការបញ្ជ្រាបយេនឌ័រក្នុងវិស័យថាមពលសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (សហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង ទីក្រុងហ្គាបូរ៉ូណេ)
- យុទ្ធសាស្ត្រឆ្នាំ២០២០ ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី
- Thomas, T. et al (ឆ្នាំ២០១៣), កសិកម្មកម្ពុជា: ការបន្សុាំទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ IFPRI ឯកសារពិភាក្សា 01285 វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ រាជធានីភ្នំពេញ
- UNESCAP(គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក) http://data.unescap.org/escap_stat/#data/ accessed 16th August 2018
- ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (UNISDR) (ឆ្នាំ២០០៩) គោលនយោបាយរបស់ការិយាល័យ អង្គការសហប្រជាជាតិ សម្រាប់ការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ (UNISDR) ស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ
- អង្គការអភិវឌ្ឍន៍ឧស្សាហកម្មអង្គការសហប្រជាជាតិ អង្គការសហប្រជាជាតិដើម្បីសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (UN WOMEN) (ឆ្នាំ២០១៣) ថាមពលចីរភាពសម្រាប់ទាំងអស់គ្នា: គម្លាតយេនឌ័រ
- ធនាគារពិភពលោក(ឆ្នាំ២០១៨) http://www.worldbank.org/en/country/cambodia/overview, ចូលមើលនៅថ្ងៃទី១២ ខែឧសភាឆ្នាំ២០១៨
- កម្មវិធីទឹក និងអនាម័យរបស់ធនាគារពិភពលោក (ឆ្នាំ២០១០) យេនឌ័រនៅក្នុងកម្មវិធីទឹកនិងអនាម័យ (ទីក្រុង ណៃរ៉ូប៊ី)

## *ឧបសម្ព័ន្ធទី១- ពាក្យបច្ចេកទេស*

ពាក្យបច្ចេកទេសខាងក្រោម គឺចេញពីចំណេះដឹងខុសៗគ្នារបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលបានបោះពុម្ពផ្សាយក្នុងពេលខុសៗគ្នា។

ការបន្សាំ សំដៅលើ *"ដំណើរការនៃការសម្របទៅនឹងអាកាសធាតុជាក់ស្តែង ឬរំពឹងទុក និងផលប៉ះពាល់របស់វា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ឬកែច្នៃយកឱកាសដែលជាផលប្រយោជន៍"*។ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុមានបំណងកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះនាពេលបច្ចុប្បន្ន ដែលអាចរំពឹងទុកដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ ចំពោះគម្រោងដែលត្រូវបានរាប់បញ្ចូលក្នុងហិរញ្ញវត្ថុសម្រាប់ការបន្សាំរបស់ធនាគារអភិវឌ្ឍន៍ពហុភាគី (MDB) ត្រូវតែ: ក. កំណត់បរិបទភាពងាយរងគ្រោះដោយសារអាកាសធាតុរបស់គម្រោង ខ.ធ្វើសេចក្តីថ្លែងការណ៍ពីគោលបំណងច្បាស់លាស់ ដើម្បីដោះស្រាយភាពងាយរងគ្រោះដោយសារអាកាសធាតុដែលជាផ្នែកមួយនៃគម្រោង និង គ.បង្ហាញឱ្យឃើញនូវទំនាក់ទំនងច្បាស់លាស់ និងដោយផ្ទាល់រវាងបរិបទភាពងាយរងគ្រោះដោយសារអាកាសធាតុ និងសកម្មភាពគម្រោងជាក់លាក់។

ការប្រែប្រួលអាកាសធាតុ មានន័យថា *"ការប្រែប្រួលនូវអាកាសធាតុដែលត្រូវបានកំណត់ដោយផ្ទាល់ឬដោយប្រយោលចំពោះសកម្មភាពមនុស្ស ដែលផ្លាស់ប្តូរសមាសធាតុនៃបរិយាកាសសាកល និងដែលបន្ថែមលើការប្រែប្រួលអាកាសធាតុធម្មជាតិដែលបានសង្កេតក្នុងអំឡុងពេលប្រហែលគ្នា"*។

យេនឌ័រ សំដៅលើ *"ភាពខុសគ្នាផ្នែកសង្គមរវាងស្ត្រី និងបុរស ដែលត្រូវបានសិក្សា គឺអាចផ្លាស់ប្តូរតាមពេលវេលា និងមានការប្រែប្រួលធំទូលាយ ទាំងនៅក្នុងនិងរវាងវប្បធម៌នានា"*។ យេនឌ័របង្កើតនូវតួនាទី សិទ្ធិ ទំនាក់ទំនង និងការទទួលខុសត្រូវដែលត្រូវបានផ្តល់ឱ្យស្ត្រី និងបុរសក្នុងសង្គម និងបរិបទវប្បធម៌ជាក់លាក់។ យេនឌ័រសំដៅលើទាំងស្ត្រី និងបុរស។

ការវិភាគយេនឌ័រ គឺជា *"ការសិក្សាពីភាពខុសគ្នានៅក្នុងលក្ខខណ្ឌនានា តម្រូវការ អត្រាចូលរួម សិទ្ធិទទួលបានធនធាននិងការអភិវឌ្ឍ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តជាដើមរវាងស្ត្រី និងបុរសលើតួនាទីយេនឌ័រដែលត្រូវបានកំណត់មកលើពួកគាត់"*។

សមភាពយេនឌ័រ សំដៅលើ សិទ្ធិ ការទទួលខុសត្រូវ និងកាលានុវត្តភាពស្មើគ្នារបស់ស្ត្រីនិងបុរស ក្មេងស្រី និងក្មេងប្រុស។ នេះគឺជា *"គោលគំនិតដែលមនុស្សទាំងអស់មានសិទ្ធិសេរីភាពក្នុងការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគាត់ និងធ្វើការជ្រើសរើសដោយគ្មានដែនកំណត់ ដែលកំណត់ដោយតួនាទីយេនឌ័រតឹងរឹង ឡើយ។ អាកប្បកិរិយា គោលបំណង និងតម្រូវការខុសៗគ្នារបស់បុរស និងស្ត្រីត្រូវបានពិចារណា ឱ្យតម្លៃ និង គាំទ្រស្មើភាពគ្នា"*។ *"សមភាពយេនឌ័រមិនមែនមានន័យថា ស្ត្រី និងបុរសត្រូវតែមានលក្ខណដូចគ្នានោះទេ ប៉ុន្តែមិនគួរមានភាពខុសគ្នានៅក្នុងសិទ្ធិ ការទទួលខុសត្រូវ និងឱកាសរបស់បុគ្គលនីមួយៗឡើយ"*។

សមធម៌យេនឌ័រ គឺជា *"ដំណើរការនៃភាពស្មើគ្នាចំពោះស្ត្រី បុរស ក្មេងប្រុសនិងក្មេងស្រី។ សំដៅលើការប្រព្រឹត្តខុសគ្នាដែលមានភាពស្មើគ្នា និងដោះស្រាយដោយវិជ្ជមាននូវភាពលំអៀង ឬគុណវិបត្តិដែលត្រូវបានបង្កឡើងដោយតួនាទីឬបទដ្ឋានយេនឌ័រ ឬភាពខុសគ្នារវាងភេទ"*។ ដើម្បីធានាបាននូវសមធម៌ គោលនយោបាយនានាត្រូវផ្តល់កាត់បន្ថយនូវការរើសអើងជាប្រពៃណី និងក្នុងសង្គម

ដែលធ្វើឱ្យស្ត្រីមានការលំបាកក្នុងការទទួលបានប្រាក់ចំណូល និងធនធាន។ សមធម៌យេនឌ័ររួមបញ្ចូលទាំង *"ភាពស្មើគ្នាចំពោះសិទ្ធិទទួលបានធនធានសេដ្ឋកិច្ចសង្គមរបស់ស្ត្រី និងបុរស"* ។ សមធម៌យេនឌ័រនាំឱ្យមានសមភាពយេនឌ័រ។

ការបញ្ជ្រាបយេនឌ័រ សំដៅដល់ការដាក់បញ្ចូលនូវទស្សនសមភាពយេឌ័រនៅគ្រប់ដំណាក់កាល និងគ្រប់កម្រិតគោលនយោបាយ កម្មវិធី និងគម្រោងនានា។ ស្ត្រី និង បុរស មានតម្រូវការ លក្ខខណ្ឌនៃការរស់នៅ និងស្ថានភាពផ្សេងៗពីគ្នា រាប់បញ្ចូលទាំងភាពមិនស្មើគ្នាក្នុងការទទួលបានការគ្រប់គ្រងអំណាច ធនធាន សិទ្ធិ និងស្ថាប័ននានារាប់ទាំងប្រព័ន្ធយុត្តិធម៌។ ស្ថានភាពរបស់ស្ត្រី និងបុរស ខុសគ្នាអាស្រ័យលើប្រទេស សាសនា អាយុ ជាតិសាសន៍ ឬដើមកំណើត និងកត្តាដទៃផ្សេងទៀត។ គោលបំណងនៃការបញ្ជ្រាបយេនឌ័រ គឺជាការយកចិត្តទុកដាក់លើភាពខុសគ្នាទាំងអស់នេះ នៅរាល់ពេលតាក់តែង អនុវត្ត និងវាយតម្លៃគោលនយោបាយ កម្មវិធី និងគម្រោងនានា ដើម្បីធានាទាំងស្ត្រីនិងបុរសទទួលបានប្រយោជន៍ ពីគោលនយោបាយ កម្មវិធី និងគម្រោងទាំងនោះ និងមិនបង្កើនឱ្យមានវិសមភាព ប៉ុន្តែគឺលើកកម្ពស់សមភាពយេនឌ័រ។ ការបញ្ជ្រាបយេនឌ័រ មានគោលបំណងដោះស្រាយនូវបញ្ហាវិសមភាពយេនឌ័រដែលពេលខ្លះបញ្ហាទាំងនេះមិនត្រូវបានរំលេចឡើង។ដូច្នេះវាគឺជាឧបករណ៍មួយដើម្បីសម្រេចបាននូវសមភាពយេនឌ័។ ការបញ្ជ្រាបយេនឌ័រគឺជាយុទ្ធសាស្ត្ររយៈពេលវែង ដែលដើរស្របគ្នានឹងគោលនយោបាយជាក់លាក់ ដើម្បីលើកកម្ពស់ស្ត្រី។ ដូច្នេះការបញ្ជ្រាបយេនឌ័រត្រូវបានពិចារណាថាជាសមាសធាតុដ៏ចំបងនៃផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ គ្រប់ជំហាននៃការធ្វើសមាហរណកម្មឬការបញ្ជ្រាបយេនឌ័រត្រូវបានគិតគូរដើម្បីឆ្ពោះទៅរកការផ្លាស់ប្តូរនូវវិធីសាស្ត្រក្នុងការធ្វើគោលនយោបាយ។
(ប្រភព: https://www.coe.int/en/web/genderequality/what-is-gender-mainstreaming)

ទិន្នន័យបែងចែកតាមភេទ គឺជាការប្រមូល និងបំបែកព័ត៌មានរបស់មនុស្សស្រី និងមនុស្សប្រុសដើម្បីកំណត់អំពីវិសមភាពសម្រាប់ការវិភាគយេនឌ័រប្រកបដោយប្រសិទ្ធភាព។

ភេទផ្ទុយពីយេនឌ័រ សំដៅលើ *"លក្ខណៈជីវសាស្ត្រដែលបែងចែកមនុស្សថាជាស្រី ឬប្រុស"*។

ការអភិវឌ្ឍប្រកបដោយចីរភាព គឺជា *"ការអភិវឌ្ឍដែលបំពេញតាមតម្រូវការបច្ចុប្បន្នដោយមិនមានធ្វើឱ្យខូចខាតដល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ឡើយ"។ ការអភិវឌ្ឍប្រកបដោយចីរភាពអំពាវនាវឱ្យមានការលើកកម្ពស់គុណភាពជីវិតសម្រាប់ប្រជាជនទាំងអស់នៅលើពិភពលោកដោយមិនបង្កើនការប្រើប្រាស់ធនធានធម្មជាតិហួសសមត្ថភាពផលិតក្នុងពិភពលោកឡើយ។ ការប្រឹងប្រែង កសាងផ្លូវជីវិតដែលមានចីរភាពយ៉ាងពិតប្រាកដ ទាមទារឱ្យមានការធ្វើសមាហរណកម្មនូវសកម្មភាពក្នុងវិស័យសំខាន់ៗចំនួន៣។"* ទាំងនេះគឺសមធម៌និងកំណើនសេដ្ឋកិច្ច ការអភិរក្សធនធានធម្មជាតិនិងបរិស្ថាន និងការអភិវឌ្ឍសង្គម។

ការផ្តល់ភាពអង់អាចដល់ស្ត្រី គឺជាចំណុចស្នូលក្នុងការសម្រេចបាននូវសមភាព។ ការផ្តល់ភាពអង់អាច មានន័យថា ការដកចេញនូវអតុល្យភាពអំណាច និងការផ្តល់ឱ្យស្ត្រីនូវលទ្ធភាពកាន់តែច្រើនជាងមុនក្នុងការប្រើប្រាស់ធនធាន និងគ្រប់គ្រងជីវិតរបស់ពួកគាត់ដោយគ្មានការបង្ខិតបង្ខំដោយភេទ ឬយេនឌ័រឡើយ។

## *ឧបសម្ព័ន្ធ ២- វិស័យ និងខេត្តជាអាទិភាពសម្រាប់ការអនុវត្តផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ*

### លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស

ការវិភាគសម្រាប់ការជ្រើសរើសខេត្ត វិស័យ និងបញ្ហា ត្រូវបានធ្វើឡើងបន្ទាប់ពីការពិគ្រោះយោបល់ដែលបានរៀបចំដោយក្រសួងបរិស្ថាន ជាមួយក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលដែលត្រូវបានអនុវត្តគម្រោង វិនិយោគ SPCR ក្នុងអំឡុងពេលចាប់ផ្តើមគម្រោង។ តារាងទី១០ បានចំលងចេញពីរបាយការណ៍ចាប់ផ្តើមគម្រោងក្នុងតារាងទី១២។ វាកំណត់ពីមូលហេតុនៃភាពងាយរងគ្រោះនៃខេត្ត និងវិស័យដែលរងផលប៉ះពាល់ ។ ហើយក្រុមការងារបច្ចេកទេសបានកំណត់ពីជំហានទំហំនៃដំណើរការជ្រើសរើស។ ក្រោមលក្ខណវិនិច្ឆ័យនេះ ការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ផលប៉ះពាល់ពីទន្លេសាប ឬ មេគង្គ តំបន់ឆ្នេរសមុទ្រ និងខេត្តគោលដៅរបស់ SPCR ដែលត្រូវបានគេយកមកពិចារណា។

កិច្ចពិភាក្សាបន្ថែមទៀតត្រូវបានធ្វើឡើងជាមួយក្រសួងកិច្ចការនារី ដែលជាភ្នាក់ងារអនុវត្ត នៃគម្រោងសាកល្បងរបស់នៃសមាសភាគកញ្ចប់ (គ) ដោយមានខេត្តគោលដៅដូចជា: ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ចាម កំពង់ធំ កំពត និងព្រៃវែង ។

*តារាងទី១០- ការជ្រើសរើសខេត្តគោលដៅសម្រាប់ក្រសួងកិច្ចការនារី*

| វិស័យងាយរងគ្រោះនិងរងផលប៉ះពាល់ | ខេត្តដែលរងផលប៉ះពាល់ | អនុសាសន៍ |
|---|---|---|
| ការប្រែប្រួលអាកាសធាតុ និងវិស័យធនធានទឹក កសិកម្ម សុខភាព និង ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដែលរងការប៉ះពាល់ | ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ស្ពឺ ព្រៃវែង កំពង់ធំ កំពត ស្ទឹងត្រែង សៀមរាប ។ ល ។ | ១- ខេត្តបាត់ដំបងនិងខេត្តពោធិ៍សាត់ជួបប្រទះនឹងហានិភ័យគ្រប់ទម្រង់ដែលបង្កឡើងពីការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ពីទន្លេសាប ផ្ទុះបាញ់ ។ ល ។<br>២- ខេត្តកំពង់ធំនិងកំពង់ចាមគឺងាយរងគ្រោះដោយសារតែការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ពីទន្លេសាប ឬ ទន្លេមេគង្គ ។ល។<br>៣- ខេត្តកំពត និងកោះកុងជួបប្រទះនឹងហានិភ័យដែលបង្កឡើងដោយ ការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ការ |
| គ្រោះរាំងស្ងួត វិស័យធនធានទឹក កសិកម្ម សុខភាព និងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដែលរងការប៉ះពាល់ | ខេត្តបាត់ដំបង ពោធិ៍សាត់ ព្រៃវែង កំពង់ស្ពឺ កំពង់ធំ កំពត ស្ទឹងត្រែង សៀមរាប ។ ល ។ | |
| គ្រោះទឹកជំនន់ និងវិស័យធនធានទឹក កសិកម្ម សុខភាព និងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដែលរងការប៉ះពាល់ | ខេត្តបាត់ដំបង់ ពោធិ៍សាត់ ព្រៃវែង កំពង់ធំ កំពត ស្ទឹងត្រែង សៀមរាប ។ ល ។ | |

<table>
<tr><td>ផលប៉ះពាល់ពីទន្លេសាប ឬ ទន្លេមេគង្គ និងវិស័យ ធនធានទឹក កសិកម្ម សុខភាព និងហេដ្ឋារចនាសម្ព័ន្ធ ក្នុងតំបន់ដែលរងការប៉ះពាល់</td><td>ខេត្តបាត់ដំបង ពោធិ៍សាត់ ព្រៃវែង កំពង់ធំ កំពត ស្ទឹងត្រែង សៀមរាប ។ ល ។</td><td rowspan="2">ហូរចូលទឹកសមុទ្រ ។<br>៤- ខេត្តព្រៃវែងជួបប្រទះនឹង ហានិភ័យដែលបង្កឡើងដោយ ការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ រន្ទះបាញ់។</td></tr>
<tr><td>តំបន់ឆ្នេរសមុទ្រ និង វិស័យធនធានទឹក កសិកម្ម និង សុខភាព ដែលរងការ ប៉ះពាល់</td><td>ខេត្តកំពត កោះកុង</td></tr>
<tr><td colspan="3">ដោយផ្អែកលើភាពប្រែប្រួលនៃអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយ ខេត្តគោលដៅរបស់ SPCR គឺខេត្តបាត់ដំបង ពោធិ៍សាត់ ព្រៃវែង កំពង់ធំ និងកំពង់ឆ្នាំង។<br>ដោយផ្អែកលើភាពចម្រុះគ្នានៃទីតាំងភូមិសាស្ត្រ ខេត្តបាត់ដំបង ព្រៃវែង កំពង់ធំ និងកំពត គឺជាខេត្តគោលដៅរបស់ក្រសួងកិច្ចការនារី ត្រូវបានណែនាំអោយជ្រើសរើសជាខេត្តគោលដៅសម្រាប់អនុវត្តគម្រោងសាកល្បងនៃផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។</td></tr>
<tr><td colspan="3">កំណត់សម្គាល់៖<br>• ខេត្តដែលបានស្នើឡើងចំនួន ៤ បង្ហាញពីតំបន់អេកូឡូស៊ីសំខាន់ចំនួនប្រាំ (ឧទាហរណ៍ ភ្នំ ខ្ពង់រាប ឆ្នេរសមុទ្រ ដីសណ្តរ និងទន្លេសាប)<br>• ខេត្តទាំងនេះមានចំណាត់ថ្នាក់ក្រីក្រខ្ពស់ (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៤)<br>• ខេត្តទាំងនោះមានជីវចម្រុះដុះលើដីដែលមានតម្លៃ (គ្របដណ្តប់ដោយព្រៃឈើ)</td></tr>
</table>

## *ឧបសម្ព័ន្ធ ៣- ការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការសកម្មភាពនៃការវិនិយោគលើការប្រែប្រួលអាកាសធាតុ តាមវិស័យ (២០១៤-២០១៨)*

គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជនបង្គោលតាមវិស័យ និងជនបង្គោលបម្រុងមកពីភ្នាក់ងារតាមផ្នែករៀងៗខ្លួន រួមជាមួយដៃគូអភិវឌ្ឍ និងតំណាងអង្គការសង្គមស៊ីវិល នឹងបង្កើតផែនការសកម្មភាពប្រចាំឆ្នាំរៀងៗខ្លួនរបស់ពួកគាត់ ស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុស្របតាមកម្មវិធី CCAP ស្ដីពីការបញ្ជ្រាបយេនឌ័រ ។

វិសាលភាពនៃផែនការសកម្មភាពត្រូវបានបែងចែកជា ៣កម្រិតដោយមានសូចនាករដូចខាងក្រោម ៖

- ការបញ្ជ្រាបយេនឌ័រនៅកម្រិតគោលនយោបាយ និងស្ថាប័ន: គោលនយោបាយគាំទ្រតាមវិស័យ ដែលឆ្លើយតបនឹងយេនឌ័រ និងការបង្កើតក្របខ័ណ្ឌ បរិបទ និងការបែងចែកធនធានរបស់រាជរដ្ឋាភិបាលឱ្យបានគ្រប់ជ្រុងជ្រោយ ។
- ការបញ្ជ្រាបយេនឌ័រនៅកម្រិតកម្មវិធី: កម្មវិធីឆ្លើយតបទៅនឹងយេនឌ័រត្រូវបានបង្កើត និងគាំទ្រការចូលរួម ការអនុវត្ត ការបែងចែកតារាងពេលវេលា និងការបែងចែកធនធានដែលឆ្លើយតបទៅនឹងយេនឌ័រ។ ល ។
- ការបញ្ជ្រាបយេនឌ័រនៅកម្រិតអនុវត្តគម្រោង: ការវាយតម្លៃមុនគម្រោង ការប្រមូលទិន្នន័យបឋម ការតាក់តែងគម្រោង អនុវត្ត តាមដាននិងវាយតម្លៃ និងវាយតម្លៃក្រោយបញ្ចប់គម្រោង។ ល ។

តារាងទី១១ ខាងក្រោមរៀបរាប់ពីការដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាពនៃការ ប្រែប្រួលអាកាសធាតុតាមវិស័យមួយចំនួន ដោយប្រៀបធៀបពីធាតុផ្សំគោលនយោបាយបច្ចុប្បន្ន និងធាតុផ្សំគោលនយោបាយនាពេលអនាគត។

តារាងទី១១- ធាតុផ្សំគោលនយោបាយបច្ចុប្បន្ននិងធាតុផ្សំគោលនយោបាយឆ្លើយតបទៅនឹងយេនឌ័រដែលបានបានគ្រោងទុកសម្រាប់ផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យសំខាន់ៗ

| សេចក្ដីយោងរបស់ CCAP តាមវិស័យ | ធាតុផ្សំគោលនយោបាយបច្ចុប្បន្ន | ធាតុផ្សំគោលនយោបាយដែលបានគ្រោងទុក |
|---|---|---|
| **វិស័យកសិកម្ម** | | |
| សកម្មភាព លេខ៨ ទំព័រ២៤ | ការអភិវឌ្ឍសមត្ថភាពស្ថាប័ន សម្រាប់ការសម្របសម្រួល និង អន្តរាគមន៍គ្រោះធម្មជាតិ | ការអភិវឌ្ឍសមត្ថភាពស្ថាប័នសម្រាប់ការសម្របសម្រួលគ្រោះធម្មជាតិ និងការអន្តរាគមន៍ ***ដែលពិចារណា និងគិតគូរពីយេនឌ័រ*** |

| សេចក្តីយោង របស់ CCAP តាមវិស័យ | ធាតុផ្សំគោលនយោបាយ បច្ចុប្បន្ន | ធាតុផ្សំគោលនយោបាយដែលបានគ្រោងទុក |
|---|---|---|
| សកម្មភាពលេខ ៩ ទំព័រ២៥ | ការពង្រឹងសមត្ថភាពរបស់សហគ្រិនក្នុងការអភិវឌ្ឍលើវិស័យកសិកម្ម កសិឧស្សាហកម្ម និងសហគមន៍កសិកម្មនៅក្នុងការអភិវឌ្ឍការបំភាយឧស្ម័នពុលកម្រិតទាប | ការពង្រឹងសមត្ថភាពរបស់សហគ្រិនក្នុងការអភិវឌ្ឍលើផ្នែកកសិកម្ម កសិឧស្សាហកម្ម និងការពិចារណារបស់សហគមន៍កសិកម្ម*ដែលផ្តោតលើបញ្ហាយេនឌ័រ*នៅក្នុងការបំភាយឧស្ម័នពុលកម្រិតទាប |
| សូចនាករសម្រាប់ផែនការ CCAP របស់ក្រសួងកសិកម្ម ទំព័រ៣២ | សូចនាករត្រៀមជាស្រេចសម្រាប់ស្ថាប័ន ៖<br>១-សមត្ថភាពសម្រាប់កាបញ្ជ្រាបការប្រែប្រួលអាកាសធាតុ<br>២-លទ្ធភាពអាចរកបាន និងការប្រើប្រាស់ទិន្នន័យ និងព័ត៌មាន | សូចនាករត្រៀមខ្លួនជាស្រេចសម្រាប់ស្ថាប័ន៖<br>១-សមត្ថភាពសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ<br>២-លទ្ធភាពអាចរកបាន និងការប្រើប្រាស់ទិន្នន័យ និងព័ត៌មាន<br>៣-សូចនាករដែលបានបែងចែកតាមភេទ |
| ដាក់ស្នើដើម្បីបន្ថែម | | លើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម តាមរយៈការសាងសង់ទំនប់ទឹកប្រៃនៅតាមតំបន់ឆ្នេរសមុទ្រ |
| **វិស័យសុខាភិបាល** | | |
| យុទ្ធសាស្ត្រទី១ ទំព័រ iii ក្រោមសេចក្តីសង្ខេប | បង្កើនសមត្ថភាពធន់របស់ប្រជាពលរដ្ឋក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងតាមភ្នាក់ងារ និងជំងឺឆ្លងតាមទឹក ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ | បង្កើនសមត្ថភាពទ្រទ្រង់របស់ប្រជាជនក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងតាមភ្នាក់ងារ និងជំងឺឆ្លងតាមទឹក ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ *ដោយពិចារណាទៅលើយេនឌ័រ* |
| យុទ្ធសាស្ត្រទី១ ទំព័រ iii ក្រោមសេចក្តីសង្ខេប | ការបង្កើត និងអនុវត្តកម្មវិធីទប់ស្កាត់ជំងឺគ្រុនឈាមនៅក្នុងខេត្តដែលមានការប្រែប្រួលអាកាសធាតុ និងហានិភ័យខ្ពស់ | ការបង្កើត និងអនុវត្តកម្មវិធីទប់ស្កាត់ជំងឺគ្រុនឈាមនៅក្នុងខេត្តដែលមានការប្រែប្រួលអាកាសធាតុ និងហានិភ័យខ្ពស់ *ដោយពិចារណាទៅលើយេនឌ័រ* |

| សេចក្ដីយោងរបស់ CCAP តាមវិស័យ | ធាតុផ្សំគោលនយោបាយបច្ចុប្បន្ន | ធាតុផ្សំគោលនយោបាយដែលបានគ្រោងទុក |
|---|---|---|
| យុទ្ធសាស្ត្រទី២ ទំព័រ iv សេចក្ដីសង្ខេប | ការបង្កើត និងអនុវត្តប្រព័ន្ធប្រមូលទិន្នន័យលើលទ្ធផលសុខភាពដែលបណ្ដាលមកពីគ្រោះធម្មជាតិ និងបញ្ហាពាក់ព័ន្ធនានា | ការបង្កើត និងអនុវត្តប្រព័ន្ធទិន្នន័យ ***បែងចែកតាមភេទ***នៅលើលទ្ធផលសុខភាពដែលបណ្ដាលមកពីគ្រោះធម្មជាតិ |
| យុទ្ធសាស្ត្រទី៣ ទំព័រ iv សេចក្ដីសង្ខេប | កសាងចំណេះដឹងរបស់ប្រជាពលរដ្ឋ និងបុគ្គលិកសុខាភិបាល ដើម្បីដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ | កសាងចំណេះដឹងរបស់ប្រជាជន និងបុគ្គលិកសុខាភិបាល ដើម្បីដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ***ដោយពិចារណាទៅលើយេនឌ័រ*** |
| យុទ្ធសាស្ត្រទី៣ ទំព័រ iv សេចក្ដីសង្ខេប | ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យសុខាភិបាលជាមួយនឹងការបញ្ចូលភាពផ្សេងគ្នានៃការប្រែប្រួលអាកាសធាតុ និងបញ្ហាពាក់ព័ន្ធនានា | ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យសុខាភិបាល ***បែងចែកតាមភេទ*** ជាមួយនឹងការបញ្ចូលភាពផ្សេងគ្នានៃការប្រែប្រួលអាកាសធាតុ និងបញ្ហាពាក់ព័ន្ធនានា |
| យុទ្ធសាស្ត្រទី៣ ទំព័រ iv សេចក្ដីសង្ខេប | ផលប៉ះពាល់សុខភាព ការពិនិត្យ ថែទាំ និងការវាយតម្លៃការបណ្ដុះបណ្ដាលដែលមានមូលដ្ឋានផ្អែកលើការស្រាវជ្រាវ | ផលប៉ះពាល់សុខភាព ***ដែលបានបែងចែកភេទ*** ការពិនិត្យថែទាំ និងការវាយតម្លៃការបណ្ដុះបណ្ដាលដែលមានមូលដ្ឋានផ្អែកលើការស្រាវជ្រាវ |
| **វិស័យសាធារណៈការ និង ដឹកជញ្ជូន** | | |
| យុទ្ធសាស្ត្រទី៤ ទំព័រ ២៣ | គោលបំណង: សមត្ថភាពរបស់មន្ត្រីក្រសួង អង្គការសង្គមស៊ីវិល និងវិស័យឯកជននឹងត្រូវបានពង្រឹង ដើម្បីឆ្លើយតបនឹងបញ្ហានៃ ការប្រែប្រួលអាកាសធាតុ | គោលបំណង: សមត្ថភាពរបស់មន្ត្រីក្រសួង អង្គការសង្គមស៊ីវិល និងវិស័យឯកជននឹងបានពង្រឹងដោយ ***ពិចារណាទៅលើកង្វល់ពាក់ព័ន្ធនឹងយេនឌ័រ*** |

| សេចក្ដីយោងរបស់ CCAP តាមវិស័យ | ធាតុផ្សំគោលនយោបាយបច្ចុប្បន្ន | ធាតុផ្សំគោលនយោបាយដែលបានគ្រោងទុក |
|---|---|---|
| ទំព័រ ៣២ | យុទ្ធសាស្ត្រទី១- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុដែលបណ្ដាលមកពីការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយ វិស័យដឹកជញ្ជូន | យុទ្ធសាស្ត្រ ១- លើកកម្ពស់ការយល់ដឹងជាសាធារណៈ*ដែលឆ្លើយតបនឹងយេនឌ័រ*អំពីការប្រែប្រួលអាកាសធាតុដែលបណ្ដាលមកពីការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយវិស័យដឹកជញ្ជូន |
| **វិស័យធនធានទឹក** | | |
| យុទ្ធសាស្ត្រសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទំព័រ ៦ | ១-ការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិកបច្ចេកទេសរបស់ក្រសួង និងសម្រាប់កសិករក្នុងប្រធានបទដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ១-ការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិកបច្ចេកទេសរបស់ក្រសួង និងសម្រាប់កសិករក្នុងប្រធានបទដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ*ដោយពិចារណាទៅលើយេនឌ័រ* |
| ៣.១ ផែនការសកម្មភាព ទំព័រ ៧ | | |
| ការងារពាក់ព័ន្ធនឹងធារាសាស្ត្រ | ការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការស្តារឡើងវិញនូវហេដ្ឋារចនា សម្ព័ន្ធខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ | ការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការស្តារឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចខ្នាតមធ្យម និងខ្នាតធំ*ដោយពិចារណាទៅលើយេនឌ័រ* |
| បន្ថែមសម្រាប់ផ្នែកនេះ | | *ការវាយតម្លៃលើផលប៉ះពាល់សក្តានុពលនៃការកើនឡើងកម្ពស់ទឹកសមុទ្រ និងការហូរចូលទឹកប្រៃនៅក្នុងតំបន់ឆ្នេរ និងបណ្ដោយឆ្នេរសមុទ្រ* |
| | | *លើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់នៃការកើនឡើងកម្ពស់ទឹកសមុទ្រដែលមានសក្ដានុពលនៅតាមតំបន់ឆ្នេរ និងបណ្ដោយឆ្នេរសមុទ្រ ជាពិសេសលើស្ត្រី និងកុមារ ក៏ដូចជាកសិករទូទៅ និងភាគីពាក់ព័ន្ធផងដែរ* |